ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## របាយការណ៍ឆ្លើយតបនឹងសំណួររបស់ការិយាល័យ តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្តីពីអំពើហិង្សាលើកុមារនៅកម្ពុជា

ឆ្នាំ២០០៦-២០១១

រៀបចំដោយ: ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# មាតិកា

**ទំព័រ**


សេចក្តីផ្តើម......................................................................................................................................១

សំណួរទូទៅៈការប៉ាន់ប្រមាណជាទូទៅលើការអនុវត្តអនុសាសន៍នៃការសិក្សារបស់អង្គការសហប្រជាជាតិ-----------១

អនុសាសន៍ទី១ : ពង្រឹងការប្តេជ្ញាចិត្តនិងសកម្មភាពនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន ----------------------------------------------- ៥

អនុសាសន៍ទី២ : ការហាមឃាត់ដោយច្បាប់នូវគ្រប់អំពើហិង្សាលើកុមារ ------------------------------------------------------------- ១៥

អនុសាសន៍ទី៣ : ផ្តល់អាទិភាពដល់ការបង្ការទប់ស្កាត់ ------------------------------------------------------------------------------------៣០

អនុសាសន៍ទី៤ : លើកស្ទួយតម្លៃអំពើអហិង្សា និងការលើកកម្ពស់ការយល់ដឹង ----------------------------------------------- ៣២

អនុសាសន៍ទី៥ : បង្កើនសមត្ថភាពរបស់អ្នកទាំងអស់ដែលធ្វើការជាមួយនិងសម្រាប់កុមារ--------------------------------៣៤

អនុសាសន៍ទី៦ : ផ្តល់សេវាផ្នែកស្តារ និងសេវាសមាហរណកម្មសង្គម------------------------------------------------------------ ៣៨

អនុសាសន៍ទី៧ : ធានាការចូលរួមរបស់កុមារ ----------------------------------------------------------------------------------------------------៤២

អនុសាសន៍ទី៨ : បង្កើតប្រព័ន្ធរាយការណ៍ និងសេវាដែលអាចទទួលបាន និងមានលក្ខណៈកុមារមេត្រី -------------------៤៤

អនុសាសន៍ទី៩ : ធានាឱ្យមានការទទួលខុសត្រូវ និងបញ្ឈប់និទណ្ឌភាព (ភាពរួចផុតពីទោស) --------------------------៤៩

អនុសាសន៍ទី១០: ដោះស្រាយទិដ្ឋភាពយេនឌ័រនៃអំពើហិង្សាលើកុមារ ------------------------------------------------------------ ៥១

អនុសាសន៍ទី១១: អភិវឌ្ឍ និងអនុវត្តការប្រមូលទិន្នន័យថ្នាក់ជាតិជាប្រព័ន្ធ និងកិច្ចខិតខំប្រឹងស្រាវជ្រាវ ----------------- ៥៣

អនុសាសន៍ទី១២: ពង្រឹងការប្តេជ្ញាចិត្តជាអន្តរជាតិ ---------------------------------------------------------------------------------------៥៨

សន្និដ្ឋាន -----------------------------------------------------------------------------------------------------------------------------------------៦១

Bibliography -------------------------------------------------------------------------------------------------------------------------------------៦២

Annexes ------------------------------------------------------------------------------------------------------------------------------------------- ៦៤

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ និងពិធីសារបន្ថែមនៅឆ្នាំ២០០២ ដោយពុំមានដាក់ខបម្រុង។ អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣ ។

ព្រះរាជាណាចក្រកម្ពុជាមានប្រជាជនសរុបចំនួន ១៣ ៣៩៥ ៦៨២នាក់ នៅឆ្នាំ២០០៨ ស្រីមានចំនួន ៦ ៨៧៩ ៦២៨ និងប្រុស ៦ ៥១៦ ០៥៤នាក់ ក្នុងនោះកុមារអាយុក្រោម១៨ឆ្នាំមានចំនួន ៥ ៤៨៧ ៧០៨ នាក់។ កម្ពុជាជាប្រទេសមួយមានប្រជាពលរដ្ឋវ័យក្មេងច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ យោងតាមជំរឿនទូទៅនូវប្រជារាស្ត្រប្រទេសកម្ពុជាឆ្នាំ២០០៨ បង្ហាញថា ៤១% នៃប្រជាពលរដ្ឋកម្ពុជាមានអាយុក្រោម១៨ឆ្នាំ ។ អត្រាមរណៈរបស់ទារកបានថយចុះពី៩៥ នៅឆ្នាំ២០០០ មកត្រឹម ៦៦ នៅឆ្នាំ២០០៥ និងឆ្នាំ២០១០ មកត្រឹម៤៥ ក្នុង1000កំណើត ហើយអត្រាមរណៈរបស់កុមារអាយុក្រោម ៥ឆ្នាំ បានថយចុះពី១២៤ នៅឆ្នាំ ២០០០ មកត្រឹម៨៣ នៅឆ្នាំ២០០៥ និងឆ្នាំ២០១០ មកត្រឹម៥៤ ក្នុង1000កំណើត។[១]

របាយការណ៍នេះត្រូវបានរៀបចំឡើងយោងតាមការពិនិត្យឡើងវិញលើឯកសារច្បាប់ លិខិតបទដ្ឋាន គោលនយោបាយ និងផែនការដែលបានរៀបចំដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងការពិនិត្យឡើងវិញយ៉ាងទូលំទូលាយលើអត្ថបទរបាយការណ៍នានា ដែលបានបោះពុម្ពផ្សព្វផ្សាយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងសង្គមស៊ីវិល ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតក្រុមការងារដើម្បីសរសេររបាយការណ៍ ដែលមានសមាសភាពមកពីក្រសួងជំនាញនិងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ។ របាយការណ៍នេះ ត្រូវបានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការពិគ្រោះយោបល់ដើម្បីស្វែងរកការផ្តល់មតិបន្ថែមពីអ្នកពាក់ព័ន្ធ រួមមានតំណាងកុមារផងដែរ តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ។ មតិយោបល់របស់កុមារនិងអ្នកធ្វើការងារពាក់ព័ន្ធ ត្រូវបានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារយកមកពិចារណាយ៉ាងល្អិតល្អន់ក្នុងការធ្វើរបាយការណ៍នេះ។

របាយការណ៍ស្តីពីអំពើហិង្សាលើកុមារនេះ មិនមានព័ត៌មានច្រំដែល ដែលបានបញ្ជូនរួចហើយនោះទេ ជារបាយការណ៍ដែលមានព័ត៌មានថ្មីៗ និងមានពង្រីកព័ត៌មានបន្ថែមទៀតនៅក្នុងករណីមានព័ត៌មានស្ទួនគ្នា ។ ព័ត៌មានលម្អិតមានដាក់នៅក្នុងឧបសម្ព័ន្ធ ។

**សំណួរទូទៅ ៖ ការប៉ាន់ប្រមាណជាទូទៅលើការអនុវត្តអនុសាសន៍នៃការសិក្សារបស់អង្គការសហប្រជាជាតិ**

**១. នៅក្នុងដំណើរការនៃការអនុវត្តអនុសាសន៍នៃការសិក្សារបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសរបស់អ្នក តើអ្វីខ្លះដែលអ្នកគិតថាជាការអនុវត្តសំខាន់បំផុត ?**

**ចម្លើយ** :

ចាប់តាំងពីឆ្នាំ២០០៦ ព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនយ៉ាងច្រើននៅក្នុងការបង្កើតយន្តការនានាដើម្បីការពារកុមារពីអំពើហិង្សា ដូចមានភស្តុតាងស្រាប់ក្នុងរបាយការណ៍នានា ដែលរាជរដ្ឋាភិបាលបាន ផ្ញើជូនស្ថាប័នពាក់ព័ន្ធនៃអង្គការសហប្រជាជាតិ រួមមាន ៖

[១] អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ២០១០

- នៅឆ្នាំ២០០៩ បានបញ្ជូនរបាយការណ៍ជាតិលើកទី២និងទី៣ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឆ្នាំ២០០០-២០០៧
- នៅឆ្នាំ២០១០ បានបញ្ជូនរបាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចនៃអង្គការសហប្រជាជាតិ ស្តីពីការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងជាតិ និងអន្តរជាតិ ដើម្បីកំណែទម្រង់យុត្តិធម៌កុមារ
- នៅឆ្នាំ២០១១ បានបញ្ជូនរបាយការណ៍ឆ្លើយតបចំពោះបញ្ជីសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍លើកទី២និងទី៣ របស់កម្ពុជា ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ
- នៅឆ្នាំ២០១១ បានបញ្ជូនរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ឆ្នាំ២០០២-២០១០ និងរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឆ្នាំ២០០២- ២០១០ ។ល។

ការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានផ្លាស់ប្តូរតាមរយៈក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដែលបានកំណត់អាណត្តិដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្តក្រុង ស្រុកខណ្ឌឆ្នាំ២០០៨ ។ ច្បាប់នេះបានបង្កើតរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពផ្សេងៗ ដែលទទួលការចាត់តាំងឱ្យធ្វើការងារក្នុងការត្រួតពិនិត្យលើការងារវិស័យសុខុមាលភាពសង្គម រួមមាន គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធឡើងវិញតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ដែលមានរចនាសម្ព័ន្ធដល់រាជធានីខេត្ត និងក្រុមការងារដើម្បីកុមារនៅតាមក្រសួង និងស្ថាប័ន ដើម្បីឱ្យស្របនឹងស្ថានភាពរីកចម្រើននៃការអនុវត្តសិទ្ធិកុមារនៅកម្ពុជា និងធានាថាបណ្តាញការពារកុមារបានផ្សព្វផ្សាយតាមរយៈខ្សែបណ្តោយពីថ្នាក់ជាតិ រហូតដល់២៤ រាជធានី ខេត្ត ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ចប់នូវកម្មវិធីកំណែទម្រង់ច្បាប់ ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ ច្បាប់ទាំងនោះ រួមមាន៖

- ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាស៊ីដខ្លាំង ឆ្នាំ២០១១
- ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
- ច្បាប់ស្តីពីទេសចរណ៍ ឆ្នាំ២០០៩
- ច្បាប់ស្តីពីសុំកូនអន្តរប្រទេស ឆ្នាំ២០០៩
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
- ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

- ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
- ច្បាប់ស្តីការអប់រំ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
- ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាលើគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ។ល។

ច្បាប់ទាំងនេះមានបញ្ចូលគោលការណ៍នានានៃអនុសញ្ញាសិទ្ធិកុមារ ។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន បាននិងកំពុងពិនិត្យដោយក្រុមជំនាញបច្ចេកទេសនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ការវិភាគលើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការការពារកុមារ ដើម្បីស្វែងរកភាពខ្វះចន្លោះជាជំហានទៅមុខដ៏មានសារៈសំខាន់មួយ ក្នុងការធ្វើឱ្យមានភាពច្បាស់លាស់នូវការរៀបចំកំណែទម្រង់គោលនយោបាយដែលទាមទារដើម្បីបង្កើតប្រព័ន្ធការពារកុមារជាក់លាក់ក្នុងប្រទេស ដែលនាំឱ្យមានការអនុវត្តយ៉ាងពេញលេញតាមអនុសញ្ញាសិទ្ធិកុមារ និងបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធដទៃទៀត ។

ការអនុវត្តច្បាប់ថ្មីៗ ត្រូវបានអនុវត្តតាមរយៈប្រកាស គោលការណ៍ណែនាំ និងការបណ្តុះបណ្តាលដែលដឹកនាំដោយក្រសួងនានា និងដោយមានការសហការជាមួយនឹងសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ដែលបានកំណត់ការកាត់បន្ថយភាពក្រីក្រ ជាយាន្តនាំមុខសម្រាប់ការផ្តួចផ្តើមអភិវឌ្ឍផ្សេងៗទៀត។ ផែនការនេះ តម្រូវឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បញ្ចូលទៅក្នុងយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ។ ក្នុងការអនុវត្តជាក់ស្តែង ទីភ្នាក់ងារនានាកំពុងតែធ្វើការរួមគ្នា រួមមានផ្នែកប្រឆាំងការជួញដូរកំពុងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ទាក់ទងនឹងការធ្វើសមាហរណកម្មជនរងគ្រោះដោយសារការជួញដូរ ដែលត្រូវបានសង្គ្រោះដោយនគរបាល និងធ្វើការយ៉ាងជិតស្និទ្ធជាមួយទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌអំពីបទដ្ឋាននៃភស្តុតាងនៃបទល្មើស។[២] រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតក្រុមការងារចម្រុះ ដើម្បីដឹកនាំយុទ្ធសាស្ត្រដោះស្រាយ ដែលមានការចូលរួមពីគ្រប់ទិដ្ឋភាពនៃកិច្ចការពារកុមារ រួមមានក្រុមប្រឆាំងនឹងការជួញដូរ ក្រុមការងារផ្នែកយេនឌ័រ ក្រុមអប់រំថែទាំចិញ្ចឹមបីបាច់កុមារ ក្រុមធ្វើការជាមួយកុមារកំព្រា ក្រុមធ្វើការជាមួយកុមារផ្ទុកមេរោគអេដស៍ ក្រុមធ្វើការទាក់ទងនឹងកន្លែងឃុំឃាំង ក្រុមធ្វើការទាក់ទងនឹងកន្លែងថែទាំតាមមណ្ឌល និងក្រុមធ្វើការខាងផ្នែកយុត្តិធម៌អនីតិជន។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកដំណោះស្រាយរួមគ្នានេះទៅធ្វើនៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិតាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី ថ្នាក់តំបន់ស្តីពីវិធានការប្រឆាំងនឹងការជួញដូរ។

**២. តើអ្វីខ្លះជាភាពខ្វះចន្លោះខ្លាំងនិងការប្រឈមមុខដែលនៅតែមាន? តើអ្នកប្រមើលមើលថាពុះពារនូវបញ្ហាទាំងនេះយ៉ាងដូចម្តេច ?**

**ចម្លើយ** :

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានការព្រួយបារម្ភអំពីភាពខ្វះខាតទិន្នន័យដែលអាចយក

[២] លោកស្រី Kim, Jane, ការប៉ាន់ប្រមាណអំពីគម្រោងការអនុវត្តច្បាប់ប្រឆាំងនឹងការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរកុមារ *(LEASETC)*, ខែកក្កដា ឆ្នាំ២០១០

ជាផ្លូវការបានទាក់ទងនឹងអំពើហិង្សាលើកុមារ ។ ទន្ទឹមនឹងការសិក្សាជាច្រើនកំពុងតែធ្វើឡើងទិន្នន័យដែលអាចយកជាផ្លូវការបាននៃអំពើហិង្សាលើកុមារនៅកម្ពុជានៅតែមានកម្រិត ។ ភាគច្រើននៃការសិក្សាផ្តោតជាសំខាន់អំពីបញ្ហាការរំលោភសេពសន្ថវៈលើកុមារ ការរួមភេទដោយបង្ខំ ។ ការសិក្សាជាច្រើនក៏សន្មត់ផងដែរថាភាគច្រើនជនរងគ្រោះជាស្ត្រីនិងជនល្មើសជាយុវជនដោយមិនបានពិចារណាដល់កុមារា ក៏អាចជាជនរងគ្រោះផងដែរ និងជាក់ស្តែងកុមារ និងយុវជនក៏អាចជាជនល្មើសនៃអំពើរំលោភបំពានផ្លូវភេទផងដែរ ។ ការសិក្សាមានព័ត៌មានខ្លីៗបង្ហាញពីទស្សនៈផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវ ធ្វើឡើងដោយយកក្រុមតូចៗជាគំរូ និងមានព័ត៌មានអំពីភាពជាក់ស្តែងតិចតួចក្នុងសង្គម ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានឹងដោះស្រាយបញ្ហានេះ តាមរយៈការចូលរួមនៅក្នុងគម្រោងស្រាវជ្រាវថ្នាក់តំបន់អំពីអំពើហិង្សាលើកុមារ ដើម្បីទទួលបានទិន្នន័យមូលដ្ឋានសម្រាប់ការវាស់វែងដែលអាចចាត់ទុកជាផ្លូវការបាន ។ ការរកឃើញនៅក្នុងការស្រាវជ្រាវនេះ នឹងជួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើផែនការយុទ្ធសាស្ត្រ បទអន្តរាគមន៍ និងអាចជួយផងដែរក្នុងការឆ្លើយតបរួមគ្នានៅថ្នាក់តំបន់ ។

អំពើហិង្សាផ្លូវភេទនិងអំពើហិង្សាដោយសារយេនឌ័រនៅតែជាបញ្ហាសំខាន់នៅព្រះរាជាណាចក្រកម្ពុជា។ អំពើហិង្សានេះក៏ធ្វើឱ្យមានការព្រួយបារម្ភផងដែរអំពីទិដ្ឋភាពអំពើហិង្សាពីជំនាន់មួយទៅជំនាន់មួយ ដោយសារមានចំនួនកុមាររងគ្រោះ ឬសាក្សីជាច្រើនចំពោះអំពើហិង្សានេះ ។ នៅឆ្នាំ២០០៩ មានចំនួន ៥៥ភាគរយនៃចំនួនករណីសរុប៣៦៤នៃការរំលោភសេពសន្ថវៈ និងប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលនគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនទទួលបានពាក់ព័ន្ធនឹងជនរងគ្រោះមានអាយុក្រោម១៨ឆ្នាំភាគច្រើន។

ការជះទឹកអាស៊ីដជាបញ្ហាដែលលេចឡើងនៅក្នុងអំពើហិង្សាដោយសារយេនឌ័រនៅកម្ពុជា។ ការជះទឹកអាស៊ីដជាទូទៅកើតឡើងដោយសារការសងសឹកដោយសារជម្លោះក្នុងគ្រួសារ ឬបញ្ហាពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងផ្ទាល់ខ្លួន ។ ជនគោលដៅនៃការជះទឹកអាស៊ីដទាំងនេះគឺភាគច្រើនជាស្ត្រី ប៉ុន្តែត្រូវបានប្រព្រឹត្តដោយទាំងបុរសនិងស្ត្រី។[៣] ឆ្នាំ២០១១នេះ ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាស៊ីដខ្លាំង ត្រូវបានអនុម័តដោយរដ្ឋសភា ។ ច្បាប់នេះមានគោលដៅកំណត់ពីការប្រើប្រាស់ទឹកអាស៊ីដ និងការផ្តន្ទាទោសចំពោះជនល្មើសដែលប្រើប្រាស់ទឹកអាស៊ីដសម្រាប់វាយប្រហារគូបក្សជិបក្សឬការសងសឹក ព្រមទាំងការជួយសង្គ្រោះ និងការស្តារនីតិសម្បទាជនរងគ្រោះ ។

ការធ្លាក់ចុះសេដ្ឋកិច្ចថ្មីៗ ធ្វើឱ្យមានការរីកចម្រើនតិចតួចក្នុងការសម្រេចតាមគោលដៅអភិវឌ្ឍសហវត្សរ៍ និងការកាត់បន្ថយភាពក្រីក្រ ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានកាត់បន្ថយភាពក្រីក្រមកនៅត្រឹម៣០ភាគរយនៅឆ្នាំ២០០៧ និងថយចុះមកត្រឹម ២៥,៨ភាគរយនៅឆ្នាំ២០១០ ។

ការធ្លាក់ចុះសេដ្ឋកិច្ច ប៉ះពាល់ដល់កុមារមកពីគ្រួសារក្រីក្រដែលភាគច្រើនប្រឈមទៅនឹងការកេងប្រវ័ញ្ចពលកម្មកុមារ ទេសន្តរប្រវេសន៍គ្មានសុវត្ថិភាព និងការជួញដូរជាដើម ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ការងារប្រកបដោយគ្រោះថ្នាក់ដល់កុមារជា១៦ប្រភេទ ដែលមានទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅក្នុងប្រទេស ។

[៣] "ប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាដោយអាស៊ីដ នៅបង់ក្លាដេស ឥណ្ឌា និងកម្ពុជា" មជ្ឈមណ្ឌលសាកល Avon សម្រាប់ស្ត្រី និងយុត្តិធម៌ នៅសាលាច្បាប់ Cornell និងគណៈមេធាវីរបស់ទីក្រុងញ៉ូយក។

សង្គ្រាមស៊ីវិលជាង ២ ទសវត្សរ៍ បានបន្សល់ទុកឱ្យព្រះរាជាណាចក្រកម្ពុជានូវធនធានមនុស្សតិចតួច ក្នុងពាក់កណ្ដាលទសវត្សរ៍ទី៩០ ។ ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីដែលទទួលបានការបណ្ដុះបណ្ដាលនៅតែមានចំនួនតិច។ ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាមិនទាន់មានបំពាក់សម្ភារៈដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ ដែលពាក់ព័ន្ធនឹងច្បាប់ដូចជា ជនរងគ្រោះ សាក្សី ឬជនល្មើសជាដើម ។ នៅឆ្នាំ២០១១ មានចៅក្រមនិងព្រះរាជអាជ្ញាចំនួន ២៩៨នាក់ និងមេធាវីកំពុងប្រកបវិជ្ជាជីវៈមានចំនួន ៦៩០នាក់ប៉ុណ្ណោះ នៅទូទាំងប្រទេស ។

មន្ត្រីសង្គមកិច្ចមានចំនួនតិចដើម្បីបំពេញតម្រូវការរបស់ប្រទេស និងការបណ្ដុះបណ្ដាលអំពីការងារសង្គមកិច្ចស្ថិតក្នុងដំណាក់កាលដំបូង ដែលជាហេតុធ្វើឱ្យមន្ត្រីសង្គមកិច្ចមានជំនាញចម្រុះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការដ៏ស្មុគស្មាញនៃការងាររបស់ខ្លួន ។ សេវាផ្សេងៗ ត្រូវបានផ្ដល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដែលសេវាទាំងនោះមានភាពសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជា ប៉ុន្តែសេវាទាំងនោះមិនផ្ដល់ឱ្យគ្រប់ទៅតាមតម្រូវការនៅឡើយ ។ ដើម្បីបង្កើនចំនួនមន្ត្រីសង្គមកិច្ចដែលបានទទួលការបណ្ដុះបណ្ដាលសម្រាប់ជួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការដឹកនាំផ្ដល់សេវានានា ដូច្នេះរាជរដ្ឋាភិបាលបានស្នើសុំឱ្យដាក់កម្មវិធីការបង្កើនសមត្ថភាព ជាកម្មវិធីធំទៅក្នុងកម្មវិធីប្រចាំប្រទេសរបស់អង្គការយូនីសេហ្វឆ្នាំ២០១១-២០១៥ ។ ឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច ដើម្បីបណ្ដុះបណ្ដាលមន្ត្រី និងនិស្សិត លើវិស័យសង្គមកិច្ច ។

ភាពជាដៃគូនឹងត្រូវបង្កើតឡើងជាមួយនឹងសាកលវិទ្យាល័យនានា ដើម្បីបង្កើនចំនួនមន្ត្រីសង្គមកិច្ចដែលមានជំនាញវិជ្ជាជីវៈអាចជួយផ្ដល់ការគាំទ្រផ្នែកសុខុមាលភាពនៅថ្នាក់មូលដ្ឋាន ។ បន្ថែមពីលើនេះ ក្រសួងនានា នឹងទទួលបានការជួយគាំទ្រដើម្បីអភិវឌ្ឍនិងអនុវត្តផែនការការងារ ដែលមានបញ្ចូលសេវាសុខុមាលភាព និងធ្វើស្រដៀងគ្នានេះដែរចំពោះមន្ត្រីអនុវត្តច្បាប់និងមន្ត្រីយុត្តិធម៌។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត) កុមារបានរងនូវអំពើហិង្សា ហើយបច្ចុប្បន្នពួកគេក្លាយជាឪពុក ម្ដាយ ឬ ជាជីដូនជីតា ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តលើកស្ទួយតម្លៃទំនៀមទម្លាប់ខ្មែរតាមរយៈដាក់ការចិញ្ចឹមបីបាច់ថែរក្សាអប់រំគ្រួសារនៅក្នុងមូលដ្ឋានសហគមន៍ ។ នៅថ្នាក់មូលដ្ឋាន រចនាសម្ព័ន្ធប្រព័ន្ធរដ្ឋបាលទទួលភារកិច្ចឱ្យផ្ដល់ការអប់រំទទួលខុសត្រូវត្រួតពិនិត្យលើកុមារ ដែលទទួលការថែទាំជំនួស និងមានកាតព្វកិច្ចជាវិជ្ជមានដើម្បីអន្តរាគមន៍និងបង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ។

## អនុសាសន៍ទី១: ពង្រឹងការប្ដេជ្ញាចិត្តនិងសកម្មភាពនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន

***សំណួរទូទៅ***

១. សូមផ្ដល់ក្របខ័ណ្ឌការងារគោលនយោបាយនៃប្រទេសរបស់អ្នកដើម្បីបង្ការទប់ស្កាត់និងដោះស្រាយចំពោះឧប្បត្តិហេតុនៃអំពើហិង្សាលើកុមារ។

**ចម្លើយ** :

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានគោលនយោបាយគោល ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ ។ ផែនការនេះ បង្ហាញពីការប្ដេជ្ញាចិត្តយ៉ាងខ្លាំង

ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើកុមារ ដែលមានការវិភាគពីសិទ្ធិកុមារនៅក្នុងផ្នែកជាច្រើន និងលើកយកចំណុចសំខាន់ជាបញ្ហាពហុវិស័យពាក់ព័ន្ធ ។

ក្រសួងនានាបានបញ្ចូលគោលការណ៍ និងបទប្បញ្ញត្តិនានានៃអនុសញ្ញាសិទ្ធិកុមារទៅក្នុងគ្រប់ផែនការការងារនិងយុទ្ធសាស្ត្ររបស់ខ្លួន ។ មានចំណុចស្ទួនគ្នាមួយចំនួននៅក្នុងផ្នែកប្រតិបត្តិ និងផែនការខ្លះអនុវត្តនៅកន្លែងផ្សេងៗគ្នា ។ ផែនការយុទ្ធសាស្ត្របច្ចុប្បន្ន ដែលទាក់ទងនឹងកិច្ចការពារកុមារ រួមមាន ៖

- ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣ -២០១៥
- ផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៣ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់វិស័យអប់រំ ឆ្នាំ២០០៦-២០១០
- គោលនយោបាយសាលាកុមារមេត្រី និងផែនការមេ ឆ្នាំ២០០៧
- សារាចរណែនាំលេខ០០៩ ស.អ.យ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០០៧
- គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៅកម្ពុជា ឆ្នាំ២០០៧
- ផែនការយុទ្ធសាស្ត្រឆ្នាំ២០០៧-២០០៩ ស្តីពីការលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដើម្បីទប់ស្កាត់ការជួញដូរកុមារ និងស្ត្រីក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ និងកម្លាំងពលកម្ម នៅក្នុងឧស្សាហកម្មទេសចរណ៍កម្ពុជា
- គោលនយោបាយស្តីពីការអប់រំសម្រាប់កុមារពិការ ឆ្នាំ២០០៨
- ផែនការយុទ្ធសាស្ត្រ ឆ្នាំ២០០៨-២០១៣ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ
- ផែនការសកម្មភាពជាតិអំពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០០៨ -២០១២
- កម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០០៨ -២០១៣
- គោលនយោបាយ ឆ្នាំ២០០៦ និងបទដ្ឋានអប្បបរមាឆ្នាំ២០០៨ ស្តីពីការថែទាំជំនួសចំពោះកុមារ
- ផែនការសកម្មភាពជាតិសម្រាប់ជនពិការ ឆ្នាំ២០០៩
- ផែនការសកម្មភាពជាតិសម្រាប់ដោះស្រាយបញ្ហាជនអានាថា ឆ្នាំ២០០៩
- ផែនការសកម្មភាពជាតិដើម្បីបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០០៩ -២០១៣
- គោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឆ្នាំ២០០៩
- ការអនុវត្តច្បាប់ដោយលើកកម្ពស់កិច្ចការពារកុមារនិងជនងាយរងគ្រោះ ៖ ក្របខណ្ឌការងារជាយុទ្ធសាស្ត្រ ខែកញ្ញា ឆ្នាំ២០១១ -២០១៥
- ផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រា និងកុមារងាយរងគ្រោះ ឆ្នាំ២០១១ -២០១៥
- យុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រនិងជនងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ ។ល។

ជាពិសេសគោលដៅអាទិភាពទី២ ក្នុងចំណោមគោលដៅទាំង៦នៃកម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺពង្រឹងនិងពង្រីកសេវាសុខុមាលភាពកុមារ និងស្តារនីតិសម្បទា។

២. សូមពិពណ៌នាពីគំនិតផ្តួចផ្តើមចម្បងៗដែលត្រូវបានលើកស្ទួយ និងពីវិធីសាស្ត្រដែលគំនិតផ្តួចផ្តើមទាំងនោះដោះស្រាយអំពើហិង្សាលើកុមារ។

**ចម្លើយ** :

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អាទិភាពលើការធ្វើបច្ចុប្បន្នភាពក្របខណ្ឌច្បាប់ ស្តីពីកិច្ចការពារកុមារ និងបង្កើនការផ្តល់សេវាទូទាំងប្រទេស ។ គម្លាតនៃការអភិវឌ្ឍនៅតាមជនបទនិងទីប្រជុំជនត្រូវបានកត់សម្គាល់ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតយន្តការដើម្បីផ្តល់សេវាឱ្យទៅដល់គ្រប់កុមារ ។ វិមជ្ឈការ ជាមួយនឹងបណ្តាញការពារកុមារថ្មី នៅថ្នាក់ឃុំសង្កាត់ ជួយជំរុញឱ្យការផ្តល់សេវាអប់រំកាន់តែមានប្រសិទ្ធភាព ការត្រួតពិនិត្យតាមដានលើការទុកដាក់កុមារតាមការថែទាំជំនួស និងការអន្តរាគមន៍នៅក្នុងករណីអំពើហិង្សាលើកុមារ ដោយសារករណីអំពើហិង្សាក្នុងគ្រួសារ។

ចាប់តាំងពីឆ្នាំ២០០៦ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការកែទម្រង់កម្មវិធីច្បាប់យ៉ាងទូលំទូលាយដែលដោះស្រាយអំពើហិង្សានៅកន្លែងភាគច្រើន ។ កំណែទម្រង់នេះ ជាលទ្ធផលដែលសម្រេចបានដ៏សំខាន់នៃការពិនិត្យឡើងវិញលើច្បាប់ និងការធ្វើសេចក្តីព្រាងគោលការណ៍ណែនាំសម្រាប់ការអនុវត្តតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការអន្តរក្រសួងទូលំទូលាយ និងឱ្យស្របទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣ និងគោលដៅអភិបាលកិច្ចល្អនៃយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ ។ កិច្ចសហប្រតិបត្តិការនេះ បានផ្តល់ទីកន្លែងដែលកំពុងធ្វើការងារ និងភ្នាក់ងារដែលមានជំនាញរបស់កម្ពុជានូវឱកាសដើម្បីអភិវឌ្ឍការអនុវត្តពហុវិស័យ ដូចជាការផ្តួចផ្តើមដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទកុមារ។ ការផ្តួចផ្តើមនេះ រួមបញ្ចូលទាំងក្រុមការងារថ្នាក់ជាតិ ការសម្របសម្រួលការប្រតិបត្តិរបស់នគរបាល ព្រះរាជអាជ្ញា និងមន្ត្រីសង្គមកិច្ច ក៏ដូចជាកិច្ចព្រមព្រៀងទ្វេភាគី ថ្នាក់តំបន់ និងសកម្មភាពបង្ការទប់ស្កាត់រួមគ្នា។ ដំណោះស្រាយពហុវិស័យនេះមានរួមបញ្ចូលទាំងក្រសួងទេសចរណ៍ ដែលទទួលបាននូវការប្តេជ្ញាចិត្តរបស់សមាគមសណ្ឋាគារកម្ពុជា ភ្នាក់ងារទេសចរណ៍ និងអ្នកធ្វើការខាងវិស័យទេសចរណ៍ ដើម្បីរាយការណ៍អំពីការជួញដូរ និង ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ និងក្រុមហ៊ុនទូរគមនាគមន៍ដែលផ្តល់ប្រព័ន្ធទូរស័ព្ទដោយមិនយកកម្រៃសម្រាប់ទូរស័ព្ទប្រចាំការពិសេស ២៤ម៉ោងលើ២៤ម៉ោង។

៣. សូមបញ្ចូលព័ត៌មានអំពីការសម្របសម្រួលដែលមានការផ្តួចផ្តើមសំខាន់ៗរបស់សង្គមស៊ីវិលដែលដោះស្រាយអំពើហិង្សាលើកុមារ នៅក្នុងប្រទេសរបស់អ្នក ក្នុងនោះរួមមានប្រភេទស្ថាប័នដែលបានចូលរួមពាក់ព័ន្ធ និងថាតើរដ្ឋាភិបាលរបស់អ្នកបានផ្តល់ការគាំទ្រចំពោះសកម្មភាពទាំងនេះឬទេ ?

**ចម្លើយ** :

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតអង្គភាពថ្មីៗ ដើម្បីសម្របសម្រួលលើការលុបបំបាត់អំពើហិង្សាលើកុមារ ។ អង្គភាពទាំងនេះ មានក្រុមការងារចម្រុះដែលផ្តល់នូវទំនាក់ទំនង ជាផ្លូវការរវាងរាជរដ្ឋាភិបាល និងសកម្មភាពសង្គមស៊ីវិល ។ ក្រុមការងារទាំងនេះមានគោលបំណងផ្តោតលើបញ្ហាតែមួយ រួមមាន ៖

- គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស

និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ដែលមានក្រុមការងារបច្ចេកទេសចម្រុះស្ថាប័នចំនួន ០៦

- ក្រុមការងារជាតិពហុវិស័យស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ
- ក្រុមការងារបច្ចេកទេសស្តីពីយេនឌ័រ
- គណៈកម្មាធិការជាតិស្តីពីសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ
- យន្តការជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម និងការប្រព្រឹត្តដែលឃោរឃៅ អមនុស្សធម៌ដទៃទៀត និងការផ្តន្ទាទោស ដើម្បីធានាការគោរពសិទ្ធិមូលដ្ឋានរបស់ជនដែលត្រូវបានដកហូតសេរីភាព
- គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអានាថា
- ក្រុមការងារអន្តរក្រសួងស្តីពីយុត្តិធម៌កុមារ
- គណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានីខេត្តនិងក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន
- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំសង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ។

**៨. សូមមេត្តាផ្តល់ព័ត៌មាន ប្រសិនបើមាន អំពីខូបសគ្គកំពុងតែមានទាក់ទងនឹងការអនុម័ត និងការអនុវត្តនូវវិធានការដើម្បីដោះស្រាយ អំពើហិង្សាលើកុមារ និងអំពីវិធានការដែលបានប្រកាន់យក ឬវិធានការដែលបានប្រមើលមើល ដើម្បីពុះពារខូបសគ្គទាំងនោះ។**

**ចម្លើយ** :

នៅឆ្នាំ២០០៧ ព្រះរាជាណាចក្រកម្ពុជា មានមណ្ឌលកុមារកំព្រាចំនួន១៩៦កន្លែង ក្នុងនោះមណ្ឌលគ្រប់គ្រងដោយរដ្ឋចំនួន២០ មានកុមារចំនួន២២៤០នាក់ និងមានមណ្ឌល១៧៦កន្លែង មានកុមារ៦៣៨៣នាក់ ដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងសប្បុរសជននានា ។ ការសិក្សាបង្ហាញឱ្យឃើញថាមានការកើនឡើង៧៦ភាគរយ ក្នុងរយៈពេល០៥ឆ្នាំនៃការថែទាំកុមារនៅក្នុងមណ្ឌល ជាក់ស្តែងគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១០ ចំនួនមណ្ឌលមាន២៦៩កន្លែង មានកុមារកើនឡើងដល់ចំនួន ១១ ៩៤៥នាក់ ។ ទិន្នន័យនេះកុមារដែលមានឪពុកឬម្តាយនៅរស់ចំនួន ៦២% ។ ការកើនឡើងនៃចំនួនកុមារក្នុងមណ្ឌលនេះ គឺផ្ទុយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការថែទាំជំនួសចំពោះកុមារ ដែលសំដៅលើការថែទាំតាមគ្រួសារ និងសហគមន៍ជាជម្រើសទី១ ។ មណ្ឌលថែទាំកុមារដែលជាកន្លែងទទួលយកកុមារឱ្យចូលក្នុងការថែទាំជំនួស ឬទាំងសហគមន៍មិនទាន់បានអនុវត្តគោលនយោបាយនេះឱ្យបានពេញលេញនៅឡើយទេ ដោយជឿជាក់ថានេះជាឧត្តមប្រយោជន៍របស់កុមារក្នុងការចាកចេញពីគ្រួសារ ឬសហគមន៍។ ឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានកាត់បន្ថយមណ្ឌលចំនួន ៧០ របស់អង្គការមិនមែនរដ្ឋាភិបាល ដោយប្រែក្លាយទៅជាការផ្តល់សេវាតាមសហគមន៍វិញ ។

**៩. សូមពិពណ៌នាពីវឌ្ឍនភាពដែលសម្រេចបាន ក្នុងការអនុវត្តគោលដៅដែលមានកំណត់រយៈពេល ដែលត្រូវបានអនុម័តនៅក្នុងសេចក្តីប្រកាស Rio De Janeiro និងសេចក្តីអំពាវនាវឱ្យមានវិធានការដើម្បីបង្ការទប់ស្កាត់ និងបញ្ឈប់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងក្មេងជំទង់ ត្រឹមឆ្នាំ២០១៣ ដូចជាការបង្កើត ៖**

**ក) ប្រព័ន្ធដែលមានប្រសិទ្ធភាពនិងអាចទទួលព័ត៌មានបាន សម្រាប់រាយការណ៍ តាមដានបន្ត និងជួយគាំទ្រកុមាររងគ្រោះដោយសារខូប្បត្តិហេតុពិតជាក់ស្តែង ឬការសង្ស័យនៃអំពើកេងប្រវ័ញ្ចផ្លូវភេទ ។**

**ចម្លើយ** :

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានអបអរសាទរចំពោះសេចក្តីប្រកាសទីក្រុង Rio De Janeiro ដែលអនុម័តនិយមន័យនៃអំពើជួញដូរ ។ ក្នុងការទទួលស្គាល់ពីតម្រូវការសម្រាប់ប្រព័ន្ធរាយការណ៍ជាផ្លូវការនិងមានប្រសិទ្ធភាព ក្រសួងមហាផ្ទៃបានបង្កើតនូវប្រព័ន្ធទូរស័ព្ទពិសេសប្រចាំការ២៤ម៉ោង លើ២៤ម៉ោង នៅភ្នំពេញសម្រាប់ទទួលបណ្តឹងពីជនរងគ្រោះ ។ ក្នុងចន្លោះឆ្នាំ២០០៥-២០០៨ ប្រព័ន្ធទូរស័ព្ទពិសេសប្រចាំការត្រូវបានតម្លើង៧បណ្តាញបន្ថែមទៀត និងលេខទូរស័ព្ទត្រូវបានផ្សព្វផ្សាយនិងប្រើប្រាស់យ៉ាងទូលំទូលាយ ។[៤] នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានបញ្ជូនករណី ឬស៊ើបអង្កេតករណីដោយផ្ទាល់ ឬបញ្ជូនព័ត៌មានទៅនគរបាលមូលដ្ឋាន ។ ភាពជាដៃគូជាមួយមន្ត្រីសុខុមាលភាពកុមារតាមរយៈមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវបានបង្កើតឡើងដើម្បីធានាថាបញ្ហាសុខុមាលភាពកុមារ និងការឆ្លើយតបនៃការអនុវត្តច្បាប់ត្រូវបានអនុវត្តនិងគោរព។ ទូរស័ព្ទពិសេសប្រចាំការគឺនៅតែជាយន្តការទទួលបណ្តឹង និងបានពង្រីកបណ្តាញទូទាំង២៤រាជធានី ខេត្ត។[៥]

**ខ) យន្តការ និង/ឬដំណើរការជាក់ស្តែងដើម្បីជួយសម្រួលដល់ការសម្របសម្រួល នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ សម្រាប់ធ្វើឱ្យប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួងនានារបស់រដ្ឋាភិបាល ស្ថាប័នផ្តល់មូលនិធិ ទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន សមាគមនិយោជិតនិងនិយោជក ប្រព័ន្ធផ្សព្វផ្សាយ អង្គការកុមារ និងតំណាងផ្សេងៗទៀតរបស់សង្គមស៊ីវិល ដើម្បីជួយជំរុញ និងគាំទ្រសកម្មភាពជាក់ស្តែងសំដៅបង្ការទប់ស្កាត់ និងបញ្ឈប់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងក្មេងជំទង់ ។**

**ចម្លើយ** :

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៥ ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ ។

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៦២ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដែលជាសេនាធិការក្នុងកិច្ចប្រឆាំងការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារដោយមានលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសចម្រុះស្ថាប័នចំនួន០៦ ជាជំនួយការក្នុងការអនុវត្តផែនការសកម្មភាពជាតិ និងមានគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ថ្នាក់រាជធានី ខេត្ត ។

រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ៧១ ស.ស.រ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការរៀបចំក្រុមការងារកម្ពុជាប្រឆាំងនឹងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ហៅកាត់ថាក្រុមការងារ

---

[៤] សេចក្តីព្រាងការវាយតម្លៃលើគម្រោងនៃការប៉ាន់ប្រមាណនៃការអនុវត្តច្បាប់ប្រឆាំងការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរកុមារ (LEASETC)ផ្នែកប្រព័ន្ធទូរស័ព្ទពិសេសប្រចាំការរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន លោកស្រី Kim,Jane ២០០៩ ។

[៥] ក្របខណ្ឌការងារជាយុទ្ធសាស្ត្រ ២០១១-២០១៥ ទំព័រ២៩។

ខមមីតកម្ពុជា (Cambodian COMMIT Task Force) ។ ក្រុមការងារនេះមានគម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សប្រចាំព្រះរាជាណាចក្រកម្ពុជាជាលេខាធិការដ្ឋាន ជួយធ្វើការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់តំបន់ដែលពាក់ព័ន្ធនឹងបញ្ហាជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ និងជាពិសេសសហការជាមួយ គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ។

គ) ស្ថាប័នសិទ្ធិកុមារឯករាជ្យនានា ដូចជាអ្នកទទួលពាក្យបណ្តឹងរបស់កុមារ (children's ombudspersons) ឬជន ស្រដៀងគ្នា ឬជនបង្គោលផ្នែកសិទ្ធិកុមារនៅក្នុងស្ថាប័នសិទ្ធិមនុស្សដែលមានស្រាប់ ។

**ចម្លើយ** :

- រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាសេនាធិការក្នុងការតាមដាន ត្រួតពិនិត្យការអនុវត្តសិទ្ធិកុមារ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានអង្គភាពជំនាញមួយហៅថា " ផ្នែកការការពារកុមារ និងពិនិត្យតាមដាន " ដែលមានតួនាទីនិងភារកិច្ចពិនិត្យ តាមដាន វាយតម្លៃនិងធ្វើរបាយការណ៍លើការអនុវត្តគោលនយោបាយ កម្មវិធីជាតិ និងបទដ្ឋានអន្តរជាតិផ្សេងៗ ពាក់ព័ន្ធនឹងកុមារ ពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាធ្វើការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិមនុស្សជាទូទៅ ដែលក្នុងនោះមានទាំងការអនុវត្តសិទ្ធិកុមារផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពជាគោលការណ៍ឱ្យបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សឯករាជ្យមួយដែលមានតួនាទីត្រួតពិនិត្យ តាមដានការអនុវត្តសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា។

- រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១២២ អនក្រ.បក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតយន្តការថ្នាក់ជាតិដើម្បីទប់ស្កាត់ការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញឬទណ្ឌកម្ម ដើម្បីធានាគោរពសិទ្ធិជាមូលដ្ឋានរបស់ជនដែលត្រូវបានដកហូត សិទ្ធិសេរីភាពនៅតាមទីកន្លែងឃុំឃាំង ។
- ក្រសួងយុត្តិធម៌បានចេញប្រកាសលេខ ៥៨ កយប្រក/០៦ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៦ បង្កើតក្រុមការងារយុត្តិធម៌កុមារដែលមានសមាសភាពមកពីក្រសួងចំនួន០៥ ដើម្បីរៀបចំប្រព័ន្ធយុត្តិធម៌កុមារមេត្រី និងធ្វើសេចក្តីព្រាងច្បាប់ និងបទបញ្ញាទាក់ទងនឹងវិស័យយុត្តិធម៌កុមារ។
- ក្នុងខែមិថុនា ឆ្នាំ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការបានឯកភាពលើគម្រោងមួយដែលផ្តួចផ្តើមនិងរៀបចំនូវក្របខណ្ឌទស្សនាទានសម្រាប់ ការបង្កើតគណៈកម្មាធិការឃ្លាំមើល (Ombudsman) នៅព្រះរាជាណាចក្រកម្ពុជា។

**សំណួរជាក់លាក់** (សូមមេត្តាភ្ជាប់មកជាមួយនូវព័ត៌មានពាក់ព័ន្ធដែលគាំទ្រការឆ្លើយបំភ្លឺរបស់អ្នក)

កន្លែងសំខាន់ៗដូចជា៖

- គ្រួសារនិងផ្ទះ
- កន្លែងអប់រំ
- ការថែទាំក្នុងមណ្ឌលនិងស្ថាប័នយុត្តិធម៌អនីតិជន (ប្រព្រឹត្តល្មើសនឹងច្បាប់)

- កន្លែងធ្វើការ
- សហគមន៍

**៦. តើប្រទេសរបស់អ្នកមានគោលនយោបាយ យុទ្ធសាស្ត្រ ឬផែនការសកម្មភាពអំពីអំពើហិង្សាលើកុមារដែរឬទេ ?**

**ចម្លើយ** :

ព្រះរាជាណាចក្រកម្ពុជាមានគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពអំពីអំពើហិង្សាលើកុមារ ។ (សូមមើលក្នុងចម្លើយទី១ នៃអនុសាសន៍ទី១)។

**៧. តើមានគោលនយោបាយ ឬផែនការតាមវិស័យ អ្វីខ្លះដែលដោះស្រាយអំពើហិង្សាលើកុមារ នៅក្នុងកន្លែងសំខាន់ៗ៥ ដែលត្រូវបានកំណត់ដោយការសិក្សារបស់ អ.ស.ប ?**

**ចម្លើយ** :

## គ្រួសារ និងផ្ទះ

មានក្រសួង ស្ថាប័នជាច្រើនដែលត្រួតពិនិត្យលើបញ្ហាទាក់ទងនឹងគ្រួសារ និងមិនមានផែនការតាមវិស័យដែលផ្តោតជាពិសេសលើការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើកុមារនៅផ្ទះទេ។ ក្រសួង និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធបានសហការគ្នាយ៉ាងជិតស្និទ្ធនៅក្នុងការអនុវត្តយន្តការ ដែលមានក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ជាពិសេសតាមរយៈផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ ២០០៩-២០១៣ ដែលរួមទាំងកុមារីផងដែរ ។ បន្ថែមពីលើនេះ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ មានតួនាទីបង្ការទប់ស្កាត់ និងកាត់បន្ថយករណីអំពើហិង្សាក្នុងគ្រួសារ ការរំលោភបំពាន ការជួញដូរ អំពើធ្វើអាជីវកម្មផ្លូវភេទនិងពលកម្មលើស្ត្រី និងកុមារនៅក្នុងឃុំ សង្កាត់ៗ[៦]

ផែនការពាក់ព័ន្ធផ្សេងៗទៀត មានបញ្ចូលយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ ដែលតម្រូវឱ្យផ្តល់អាហារ និងជំនួយផ្សេងៗទៀតដល់គ្រួសារក្រីក្របំផុត។ ផែនការសកម្មភាពជាតិសម្រាប់ដោះស្រាយបញ្ហាជនអានាថា ឆ្នាំ២០០៩ ដែលគ្របដណ្តប់លើគ្រួសារអានាថានិងកុមារតាមចិញ្ចើមថ្នល់ និងផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រានិងកុមារងាយរងគ្រោះ ឆ្នាំ២០១១-២០១៥។

## កន្លែងអប់រំ

ក្រសួងអប់រំ យុវជន និងកីឡាបានចេញគោលនយោបាយមេនិងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥ ក៏ដូចជាផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រសម្រាប់វិស័យអប់រំ ឆ្នាំ២០០៦-២០១០ គោលនយោបាយស្តីពីសាលាកុមារមេត្រីនិងផែនការមេឆ្នាំ២០០៧ និងគោលនយោបាយស្តីពីការអប់រំសម្រាប់កុមារពិការ ឆ្នាំ២០០៨។

ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ និងក្រមសីលធម៌ ឆ្នាំ២០០៨ ត្រូវបានចេញសម្រាប់បុគ្គលិកអប់រំដែលហាមឃាត់ទាំងអំពើហិង្សាលើរូបរាងកាយ ឬផ្លូវចិត្ត ឬទម្រង់ណាមួយនៃទណ្ឌកម្មលើរូបរាងកាយនៅកន្លែង

[៦] សេចក្តីណែនាំស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ២០០៧

អប់រំ ។ គោលនយោបាយស្តីពីសាលាកុមារមេត្រីលើកទឹកចិត្តដល់ការសិក្សាដែលមានការចូលរួម និងដំណោះស្រាយអហិង្សា ។ ត្រឹមឆ្នាំ២០១១ គោលនយោបាយសាលាកុមារមេត្រីត្រូវបានអនុវត្តស្ទើរ ១០០% នៃចំនួនសាលារៀនសរុបទូទាំងប្រទេស។

## ការថែទាំក្នុងមណ្ឌលនិងស្ថាប័នយុត្តិធម៌អនីតិជន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រា កុមារដែលមានផ្ទុកមេរោគអេដស៍ និងកុមារងាយរងគ្រោះដទៃទៀតនៅកម្ពុជា ឆ្នាំ២០០៨-២០១០ បន្ទាប់មក ផែនការសកម្មភាពជាតិសម្រាប់កុមារកំព្រានិងកុមារងាយរងគ្រោះ ឆ្នាំ២០១១-២០១៥។

គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦ មានគោលបំណង "ដើម្បីធានាថាកុមាររួតលាស់នៅក្នុងគ្រួសារនិងសហគមន៍" និងលើកស្ទួយគោលការណ៍ "ការថែទាំតាមស្ថាប័នគួរតែជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្ន" បន្ទាប់ពីការអនុវត្តសាកល្បងគោលនយោបាយនេះនៅឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញបទដ្ឋាននិងគោលការណ៍សម្រាប់ការថែទាំ ការគាំទ្រ និងការការពារចំពោះកុមារកំព្រានិងកុមារងាយរងគ្រោះក្នុងគោលបំណងបង្ហាញថា ការថែទាំតាមស្ថាប័នជាជម្រើសចុងក្រោយ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល ឆ្នាំ២០០៦ និងបទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួស ឆ្នាំ២០០៨ ពុំបានបញ្ចូលអំពើហិង្សានិងការធ្វើបាបកុមារទេ។ បទដ្ឋានទាំងនេះក៏អនុវត្តផងដែរចំពោះមណ្ឌលស្តារនីតិសម្បទា មណ្ឌលសំចតប៉ោយប៉ែត និងមន្ទីរពេទ្យផ្នែកចិត្តសាស្ត្រ។ មណ្ឌលត្រូវបានធ្វើអធិការកិច្ចដោយមន្ត្រីមកពីការិយាល័យអធិការកិច្ច ផ្នែកថែទាំជំនួសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ការិយាល័យនេះ ធ្វើអធិការកិច្ចនៅតាមមណ្ឌលទូទាំងរាជធានីខេត្តនីមួយៗ ដោយផ្តល់ការណែនាំ ពិធីការ ទម្រង់ ។ ក្នុងករណីមិនគោរពតាមលក្ខខណ្ឌនៃបទដ្ឋានអប្បបរមា ការិយាល័យនេះអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់វិធានការ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងរៀបចំសេចក្តីព្រាងក្រមសីលធម៌សម្រាប់បុគ្គលិកទាំងអស់ដែលធ្វើការនៅក្នុងមណ្ឌលថែទាំកុមាររបស់រដ្ឋ ទាក់ទងនឹងការធ្វើអធិការកិច្ច ការឆ្លើយតបទៅនឹងបណ្តឹងនិងវិធានការទណ្ឌកម្មវិន័យ ។ ក្រមសីលធម៌នេះមិនអនុវត្តលើបុគ្គលិកដែលធ្វើការនៅពន្ធនាគារទេ ប៉ុន្តែអនុវត្តលើមណ្ឌលកុមារកំព្រា មន្ទីរពេទ្យសុខភាពផ្លូវចិត្ត មណ្ឌលស្តារនីតិសម្បទា និងមណ្ឌលសំចតប៉ោយប៉ែត។ សេចក្តីព្រាងមានបញ្ចូលពីកាតព្វកិច្ចនៃការរាយការណ៍សម្រាប់បុគ្គលិកដែលសង្ស័យបុគ្គលិកផ្សេងទៀតធ្វើការសម្រុះសម្រួលអំពីសុវត្ថិភាពកុមារណាមួយ។

## ពន្ធនាគារ

ពន្ធនាគារនិងកន្លែងឃុំខ្លួនរបស់នគរបាលយុត្តិធម៌ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាគឺមិនមែនជាកន្លែងឃុំឃាំងអនីតិជនឡើយ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានដាក់កុមារទំនាស់នឹងច្បាប់នៅក្នុងមណ្ឌលស្តារនីតិសម្បទាដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

## កន្លែងធ្វើការ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ២០០៨-២០១២ ដែលមានគោលដៅសម្រេចឱ្យបាននូវគោលដៅគ្រោះ ស្តីពីពលកម្មកុមារគឺកាត់បន្ថយគ្រប់ទម្រង់នៃពលកម្មកុមារឱ្យដល់៨ភាគរយត្រឹម ឆ្នាំ២០១៥ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារត្រឹមឆ្នាំ២០១៦។

## សហគមន៍

ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០៥១ សណន/គ.ជ.អ.ប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធសុខភាពមាតា មត្តេយ្យសិក្សា សហគមន៍ អនាម័យ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំសង្កាត់ តួនាទីនិងការទទួលខុសត្រូវទាក់ទងនឹងកុមារមានភាគច្រើនមាននៅក្នុងសេចក្តីណែនាំស្តីពីការរៀបចំនិងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារសម្រាប់ឃុំសង្កាត់ នៅក្នុងប្រទេសឆ្នាំ២០០៧ និងបានចេញគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពឆ្នាំ២០១០ ក្នុងគោលបំណង ៖

- គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការផលិត ចែកចាយ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ២០១០ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញបានបញ្ចេញជនអានាថាចំនួន ៨៦ គ្រួសារមានមនុស្សចំនួន១៥០នាក់ ដែលក្នុងនោះរួមមានកុមារផងដែរ និងបញ្ជូលជនអានាថា ជនចាស់ជរា គ្មានទីពឹងដោយស្ម័គ្រចិត្តចំនួន ១៥០នាក់ ដែលក្នុងនោះរួមមានកុមារផងដែរ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ បានទទួល និងអប់រំជនងាយរងគ្រោះរយៈពេលខ្លីចំនួន ៥៦៣នាក់ និងបានពិគ្រោះយោបល់បញ្ជូនទៅមជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ អង្គការដៃគូ ដើម្បីទទួលការឧបត្ថម្ភរយៈវែង និងធ្វើសមាហរណកម្មទៅសហគមន៍វិញចំនួន៥៦៣នាក់ ។

**៨. តើស្ថាប័ន ឬ អាជ្ញាធររដ្ឋាភិបាលនាំមុខណា ដែលធ្វើការពាក់ព័ន្ធនឹងការសម្របសម្រួលសកម្មភាពដែលដោះស្រាយអំពើហិង្សាលើកុមារ រួមទាំងកិច្ចសហការ និងការសម្របសម្រួលឆ្លងក្រសួង និងរវាងអាជ្ញាធរថ្នាក់កណ្តាលនិងថ្នាក់ក្រោមជាតិ ?**

**ចម្លើយ** :

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកែសម្រួលសមាសភាព និងរចនាសម្ព័ន្ធឡើងវិញ ដែលរចនាសម្ព័ន្ធថ្មីមានរហូតដល់រាជធានី ខេត្ត និងក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន។ ការកែសម្រួលរចនាសម្ព័ននេះ មានគោលបំណងដើម្បីឱ្យស្របនឹងស្ថានភាពរីកចម្រើននៃការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានផែនការយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំ ២០១១-២០១៣ ក្នុងការបង្កើតនូវរចនាសម្ព័ន្ធផ្ទៃក្នុងផ្ទាល់ ដើម្បីបញ្ជាក់ពីតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួន ។

គោលដៅយុទ្ធសាស្ត្រមាន ៖

១. ការសម្របសម្រួលសមត្ថភាព និងរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

២. ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិដើម្បីសិទ្ធិកុមារ

៣. ការរៀបចំរបាយការណ៍ ការពិនិត្យតាមដាន និងការវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ

៤. ច្បាប់ និងគោលនយោបាយសម្រាប់កុមារ ។

បច្ចុប្បន្ននេះមានមន្ត្រីសង្គមកិច្ច មន្ត្រីឃុំសង្កាត់ និងសមាជិករបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនៅគ្រប់រាជធានី ខេត្ត ដើម្បីធានាថាបណ្តាញការពារកុមារបានផ្សព្វផ្សាយតាមខ្សែបណ្តោយពីថ្នាក់ជាតិដល់ថ្នាក់រាជធានីខេត្ត ស្រុកខណ្ឌ ភូមិឃុំ និងខ្សែទទឹងទូទាំង២៤រាជធានី ខេត្ត។

គណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ មានក្រុមការងារទាំង០៦ ។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក) ជាអង្គភាពសម្រាប់ពិគ្រោះយោបល់ចំពោះក្រុមប្រឹក្សាឃុំសង្កាត់ ស្តីពីបញ្ហានានាដែលពាក់ព័ន្ធនឹងស្ត្រីនិងកុមារ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត (គ.ក.ស.ក) មានតួនាទីផ្តល់យោបល់ និងលើកជាអនុសាសន៍ជូនក្រុមប្រឹក្សា គណៈអភិបាល អភិបាល និងគណៈកម្មធិការដទៃទៀតរបស់ក្រុមប្រឹក្សាលើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ កុមារ និងជនងាយរងគ្រោះដែលស្ថិតក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ។

**៩. តើមានអាជ្ញាធរ រចនាសម្ព័ន្ធ និងយន្តការផ្សេងៗទៀតណាមួយរបស់រដ្ឋាភិបាល នៅកម្រិតថ្នាក់សហព័ន្ធ រដ្ឋ/ខេត្ត ក្រុង និងថ្នាក់មូលដ្ឋានណាខ្លះដែលបច្ចុប្បន្ននេះទទួលខុសត្រូវដោះស្រាយ អំពើហិង្សាលើកុមារ ? តើមួយណា និងនៅកម្រិតណា ?**

**ចម្លើយ** :

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររបស់ក្រុមប្រឹក្សារាជធានី ខេត្ត ជារចនាសម្ព័ន្ធគន្លឹះទទួលខុសត្រូវលើការត្រួតពិនិត្យតាមដានសុខុមាលភាពកុមារនៅថ្នាក់មូលដ្ឋាន។
- ប្រកាសលេខ ២២៨០ ស.អ.យ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ បានផ្តល់តួនាទីនិងការទទួលខុសត្រូវដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ ដើម្បីត្រួតពិនិត្យតាមដានរកកន្លែងទុកដាក់កុមារផងដែរ ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់ថា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ អាចស្នើសុំឱ្យមានវិធានការបង្វែរសម្រាប់អនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់នីមួយៗដែលស្ថិតក្រោមដីកាបង្វែររបស់តុលាការ ។
- ក្រសួង និងមន្ទីរ ទទួលខុសត្រូវផ្តល់សេវានានានៅថ្នាក់រាជធានី ខេត្ត ជាពិសេស មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរកិច្ចការនារី និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលគ្រប់គ្រងបណ្តាញមន្ត្រីសង្គមកិច្ច មានចំនួនកាន់តែច្រើនឡើង ព្រមទាំងអ្នកធ្វើអធិការកិច្ចតាមមណ្ឌលថែទាំនៅមូលដ្ឋាន និងបុគ្គលិករដ្ឋបាល ។

**១០. តើមានការវាយតំលៃពីផលយូរអង្វែងរបស់គោលនយោបាយ និងកម្មវិធីដែលផ្តោតលើអំពើហិង្សាលើកុមារដែរឬទេ ? សូមបង្ហាញពីយន្តការត្រួតពិនិត្យតាមដានពាក់ព័ន្ធ ដើម្បីវាយតម្លៃនាពរីកចម្រើននៅក្នុងផ្នែកនេះៗ**

**ចម្លើយ** :

បច្ចុប្បន្ននេះ ពុំមានទិន្នន័យជាមូលដ្ឋានសម្រាប់ការវាស់វែងស្តីពីអំពើហិង្សាលើកុមារគ្រប់ទម្រង់ នៅទូទាំងប្រទេសទេ ។ ការសិក្សាជាមូលដ្ឋានសម្រាប់ការវាស់វែងដែលសហការរៀបចំដោយក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រោមការសម្របសម្រួលនិងឧបត្ថម្ភដោយអង្គការយូនីសេហ្វ នឹងធ្វើនៅឆ្នាំ២០១២ សង្ឃឹមថានឹងទទួលបានលទ្ធផលក្នុងការសិក្សានោះ នៅឆ្នាំ២០១៣ ។

ទិន្នន័យស្តីពីអំពើហិង្សាលើកុមារត្រូវបានប្រមូលតាមរយៈឃុំ សង្កាត់ ដែលរាយការណ៍ពីករណីអំពើហិង្សាទៅមន្ទីរផែនការខេត្ត ហើយលទ្ធផលនៃករណីរាយការណ៍ នឹងត្រូវបានបោះពុម្ពផ្សាយប្រចាំឆ្នាំដោយក្រសួងផែនការ ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រមូលទិន្នន័យមិនបានបញ្ចូលជាមួយគ្នាគ្រប់ករណីនៃអំពើហិង្សាលើកុមារទេ ។ ក្រសួងកិច្ចការនារី បានធ្វើការស្រាវជ្រាវដើម្បីធ្វើការសាកល្បងលើប្រសិទ្ធភាពនៃយន្តការប្រមូលទិន្នន័យស្តីពីអំពើហិង្សាលើស្ត្រី និងបានរកឃើញថារបាយការណ៍របស់ឃុំសង្កាត់អាចយកជាផ្លូវការបាន ។[៧]

**១១. តើមានការចាត់ចែងបម្រុងទុកនូវធនធានហិរញ្ញវត្ថុ និង/ឬធនធានមនុស្សជាក់លាក់ ដើម្បីដោះស្រាយអំពើហិង្សាលើកុមារដែរឬទេ?**

**ចម្លើយ** :

ពុំទាន់មានបម្រុងទុកថវិកាដោយឡែកសម្រាប់ដោះស្រាយតែអំពើហិង្សាលើកុមារនោះទេ ។ ថវិកាសម្រាប់ដោះស្រាយបញ្ហានេះ ត្រូវបានដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការបស់ក្រសួងនានា ដើម្បីអនុវត្តមុខងារកិច្ចការពារសង្គមរបស់ខ្លួន ។

**១២. តើមានរចនាសម្ព័ន្ធពិសេសរបស់សភា (ឧ. គណៈកម្មាធិការពិសេស) ឬមានគំនិតផ្តួចផ្តើមដើម្បីដោះស្រាយអំពើហិង្សាលើកុមារដែរឬទេ ?**

**ចម្លើយ** :

ស្ថាប័ននីតិបញ្ញត្តិពិភាក្សាលើគ្រប់សេចក្តីព្រាងច្បាប់ទាំងអស់ ដែលមានគណៈកម្មការទី ១ ទទួលបន្ទុកសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភានិងព្រឹទ្ធសភា និងគណៈកម្មការទី ៨ ស្តីពីសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ។

**១៣. តើមានស្ថាប័នជាតិឯករាជ្យផ្នែកសិទ្ធិកុមារដែលដោះស្រាយខូប្បត្តិហេតុអំពើហិង្សាដែរឬទេ ?**

**ចម្លើយ** :

(សូមពិនិត្យមើលចំណុច គ សំណួរទី៥ ក្នុងអនុសាសន៍ទី១) ។

## អនុសាសន៍ទី២ : ការហាមឃាត់ដោយច្បាប់នូវគ្រប់អំពើហិង្សាលើកុមារ

សំណួរទូទៅ

**១. សូមពិពណ៌នាអំពីវិធីដែលអំពើហិង្សាលើកុមារត្រូវបានដោះស្រាយ នៅក្នុងក្របខ័ណ្ឌច្បាប់របស់ប្រទេសអ្នក រួមទាំងនៅក្នុងរដ្ឋធម្មនុញ្ញ**

---

[៧] រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងកិច្ចការនារី, របាយការណ៍ស្តីពីការប្រមូលទិន្នន័យ និងពិនិត្យតាមដាន ស្តីពីអំពើហិង្សាលើស្ត្រី ឆ្នាំ២០១០។

ច្បាប់ និងលិខិតបទដ្ឋានក្រោមច្បាប់ និងក្នុងករណីសមស្រប តាមសាសនា និងច្បាប់ប្រពៃណី ។ សូមបញ្ចូលព័ត៌មានអំពីការប្រឈមមុខដែលបានរកឃើញ ទាក់ទងនឹងការអនុម័តនូវការហាមឃាត់តាមផ្លូវច្បាប់ដ៏ទូលំទូលាយនូវរាល់ទម្រង់នៃអំពើហិង្សាលើកុមារ និងអំពីវិធានការដែលបានប្រកាន់យក ឬវិធានការដែលបានពិចារណាដើម្បីពុះពារខ្ទបសគ្គទាំងនោះ ។

**ចម្លើយ** :

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩២ និងបានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៩៣ ក្នុងនោះមាត្រា៣១ វាក្យខណ្ឌ១ ចែងថា " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ " និងមាត្រា៤៨ វាក្យខណ្ឌ១ ចែងថា " រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ"។

ព្រះរាជាណាចក្រកម្ពុជាកំពុងអនុវត្តច្បាប់នានាពាក់ព័ន្ធនឹងកិច្ចការពារកុមារ ដែលច្បាប់ និងបទប្បញ្ញត្តិ ទាំងនោះស្ថិតនៅផ្សេងៗពីគ្នា មិនស្ថិតក្នុងច្បាប់កិច្ចការពារកុមារតែមួយនោះទេ ។ ចាប់តាំងពីឆ្នាំ២០០៦មក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានត្រួតពិនិត្យលើការអនុម័តច្បាប់បានយ៉ាងច្រើន អនុវត្តតាមគោលការណ៍អនុសញ្ញាស្តីពីសិទ្ធិកុមារ រួមមាន ៖ (សូមពិនិត្យមើលវាក្យខណ្ឌ៣ នៃចម្លើយតបនឹងសំណួរទូទៅទី ១ ) ។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន បាននិងកំពុងពិនិត្យដោយក្រុមជំនាញបច្ចេកទេសនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានធ្វើការវិភាគរកភាពខ្វះចន្លោះនៃក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការការពារកុមារនៅព្រះរាជាណាចក្រកម្ពុជា ។

២. សូមមេត្តាផ្តល់ព័ត៌មានអំពីការសិក្សា និងការស្ទង់មតិណាមួយដែលបានធ្វើឡើងដើម្បីប៉ាន់ប្រមាណពីឥទ្ធិពលនៃវិធានការតាមផ្លូវច្បាប់ដើម្បីដោះស្រាយអំពើហិង្សាលើកុមារ។

**ចម្លើយ** :

ការអនុម័តវិធានការច្បាប់មានឥទ្ធិពលច្រើនចំពោះកិច្ចការពារអំពើហិង្សា ។ ការស្ទង់មតិជាមូលដ្ឋានសម្រាប់ការវាស់វែង ឆ្នាំ២០០៥ របស់ក្រសួងកិច្ចការនារីស្តីពីអំពើហិង្សាលើស្ត្រី និងការស្ទង់មតិបន្តឆ្នាំ២០០៩ បានបង្ហាញថា ការយល់ដឹងមានការកើនឡើងអំពីអ្វីដែលហៅថាការបំពារបំពានក្នុងបរិបទគ្រួសារ ដែលបានចូលរួមចំណែកដល់យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ប្រជាពលរដ្ឋចំនួន ២៣ភាគរយ បានចាត់ទុកប្រភេទ " ពាក្យជេរប្រទិច " ជាបទល្មើស និងពី៥៧ភាគរយ ទៅ៨០ភាគរយ ចាត់ទុកប្រភេទ "ការគប់គ្រវែង" ជាបទល្មើស និងពី៨៨ភាគរយ ទៅ ៩៧ភាគរយ ចាត់ទុកប្រភេទ "ការគំរាមកំហែងដោយប្រើកាំបិត" ជាបទល្មើស ។

៣. តើក្របខណ្ឌច្បាប់មានបទប្បញ្ញត្តិជាក់លាក់ណាមួយដែលចែងអំពី ៖

ក. ការហាមឃាត់រាល់ទម្រង់នៃអំពើហិង្សា រួមមាន អំពើហិង្សាលើរាងកាយ ផ្លូវចិត្ត និងផ្លូវភេទ ការធ្វើឱ្យរបួស ឬការរំលោភបំពាន

ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ ការធ្វើបាប និងការកេងប្រវ័ញ្ចដែរឬទេ ?

**ចម្លើយ** :

មាត្រា៣៨នៃរដ្ឋធម្មនុញ្ញចែងថា " ច្បាប់ការពារមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូរបស់ប្រជាពលរដ្ឋ " និងមាត្រា៤៨ ចែងថា " រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ "។

ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២១៩ ស្ដីពីស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ ចែងថា " អំពើហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ២ (ពីរ)ឆ្នាំ ទៅ ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន) រៀល ទៅ១០ ០០០ ០០០ (ដប់លាន)រៀល កាលបើអំពើហិង្សានេះ ត្រូវបានប្រព្រឹត្តទៅលើ ៖ ១- បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ។ ២- នារីមានគភ៌ កាលបើគភ៌បានឃើញជាក់ស្ដែង ឬកាលបើជនល្មើសបានដឹង " ។ មាត្រា ២២១ ស្ដីពីស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនល្មើស ចែងថា " អំពើហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ទៅ៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ១០ ០០០ ០០០ (ដប់លាន)រៀល កាលបើអំពើហិង្សានេះដោយអ្នករាជការសាធារណៈនៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន" ។ មាត្រា ២១៣ ស្ដីពីស្ថានទម្ងន់ទោសទាក់ទងទៅនឹងចារី ចែងថា " បទឧក្រិដ្ឋដែលមានចែងក្នុងមាត្រា២១០ (បទទារុណកម្ម និងអំពើឃោរឃៅ) នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ទៅ២០ (ម្ភៃ)ឆ្នាំ កាលបើបទឧក្រិដ្ឋនេះ ត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន" ។

ក្រមព្រហ្មទណ្ឌជំពូក៥ ផ្នែក២ ចែងអំពីការញុះញង់អនីតិជនឱ្យប្រព្រឹត្តអំពើខុសច្បាប់ ឬអំពើគ្រោះថ្នាក់ ៖

- មាត្រា៣៤៣ ចែងថា " អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យបរិភោគជាប្រចាំ និងយ៉ាងច្រើននូវគ្រឿងស្រវឹង ត្រូវផ្ដន្ទាទោសដាក់ព័ន្ធនាគារពី៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ ១.០០០. ០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។
- មាត្រា៣៤៤ ចែងថា " អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យសុំទាន ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។
- មាត្រា៣៤៥ ចែងថា " អំពើញុះញង់អនីតិជនដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្ដន្ទាទោសដាក់ព័ន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ។
- មាត្រា៣៤៦ ចែងថា " អំពើរបស់នីតិជនដែលរៀបចំការជួបជុំ ដែលរួមមានការបង្ហាញភេទ ឬមានទំនាក់ទំនងខាងផ្លូវភេទ ដោយមានអនីតិជនបានមើល ឬចូលរួមផងនោះ ត្រូវផ្ដន្ទាទោសដាក់ព័ន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

អំពើដែលជាបទល្មើសព្រហ្មទណ្ឌ អាចធ្វើការចោទប្រកាន់បានតាមក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ច្បាប់ទាំងនេះ ដាក់ទណ្ឌកម្មចំពោះអំពើល្មើស និងមានចែងអំពីទណ្ឌកម្មការពិន័យជាប្រាក់ និងសំណងរដ្ឋប្បវេណីផ្សេងៗទៀត ។

**ខ. ការបង្ការទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ការធ្វើឱ្យរបួស ឬការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ និងការកេងប្រវ័ញ្ចដែរឬទេ?**

**ចម្លើយ** :

ច្បាប់ជាតិមានចែងជាចម្បងចំពោះការហាមឃាត់ ការចោទប្រកាន់ ឬការធ្វើអធិការកិច្ច ការដាក់ទណ្ឌកម្មបញ្ហាឱ្យសងការខូចខាត ។ មុខងារនៃអធិការកិច្ចត្រូវបានកំណត់ដោយច្បាប់ស្តីពីការងារសម្រាប់កន្លែងធ្វើការ គឺត្រូវមានការចុះបញ្ជីជាចាំបាច់នូវឈ្មោះកម្មករដែលមានអាយុក្រោម ១៨ឆ្នាំ ។ ប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាកំណត់នូវមុខងារនៃអធិការកិច្ច និងតម្រូវឱ្យមានការផ្លាស់ប្តូរក្នុងគ្រប់មណ្ឌលថែទាំដែលស្ថិតក្រោមការធ្វើអធិការកិច្ចរបស់ក្រសួងនេះ ។ ក្រសួងមហាផ្ទៃបានចេញសេចក្តីសម្រេចលេខ០០១ ប.ប.ជ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីក្រមសីលធម៌ និងបទវិន័យមន្ត្រីអនុរក្សពន្ធនាគារ និងបានចេញសៀវភៅព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តល្អៗ និងនីតិវិធីនៃការធ្វើអធិការកិច្ច និងទណ្ឌកម្មវិន័យត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានពន្ធនាគារ នៃក្រសួងមហាផ្ទៃ ។

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ មាត្រា១ ចែងថា "ច្បាប់នេះ មានគោលបំណងទប់ស្កាតអំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គមនៅព្រះរាជាណាចក្រកម្ពុជា ច្បាប់នេះមានគោលដៅបង្កើតនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ ស្របតាមមាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដោយបំពេញបន្ថែមលើបទដ្ឋានគតិយុត្ត ជាធរមាន ។

អំពើហិង្សាក្នុងគ្រួសាររួមមាន ការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ និងការឈ្លានពានខាងផ្លូវភេទ ។

អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុត មានកាតព្វកិច្ចធ្វើអន្តរាគមន៍ជាបន្ទាន់ដើម្បីទប់ស្កាត់អំពើហិង្សានិងការពារជនរងគ្រោះ ដោយយកជនរងគ្រោះទៅកន្លែងសុវត្ថិភាពក្នុងករណីចាំបាច់ និងបន្តការស៊ើបអង្កេតធ្វើរបាយការណ៍ជាបន្ទាន់ ទៅព្រះរាជអាជ្ញាមានសមត្ថកិច្ច។ តុលាការមានអំណាចចេញដីកាការពារ បញ្ជាឱ្យមានការសម្រុះសម្រួល និងថាតើអំពើហិង្សាមានពាក់ព័ន្ធនឹងកុមារដែរឬទេ ចាត់តាំងបុគ្គលម្នាក់ឱ្យធ្វើការស៊ើបអង្កេត។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការអប់រំបង្ការទប់ស្កាត់ ផ្សព្វផ្សាយច្បាប់ ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រី និងផ្តល់ការអប់រំដល់សាធារណៈជនស្តីពីវិធីដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។

**គ. កិច្ចការពារកុមារឱ្យរួចផុតពីរាល់ទម្រង់នៃអំពើហិង្សា រួមទាំងកុមាររងគ្រោះ និងសាក្សីដែរឬទេ ?**

**ចម្លើយ** :

ក្រសួងយុត្តិធម៌បានចេញប្រកាសលេខ ៦២ កយប្រក/០៨ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ បានណែនាំឱ្យប្រើប្រាស់របាំងនិងបណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្មពីកុមារ/ជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះនៅក្នុងពេលដំណើរការសវនាការ ។ ឧបករណ៍សម្ភារៈ/បណ្តាញទូរទស្សន៍ ត្រូវបានបំពាក់នៅក្នុងតុលាការចំនួន ៥ មានតុលាការខេត្តកណ្តាល បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងព្រះសីហនុ ។ មាត្រា៤៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មានចែងពីកិច្ចការពារអត្តសញ្ញាណជនរងគ្រោះ តាមរយៈការហាមឃាត់មិនឱ្យបោះពុម្ពផ្សាយនូវភិនភាគអត្តសញ្ញាណជនរងគ្រោះ ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានចេញសេចក្តីសម្រេចលេខ ១០៧ ក.ជ.ក.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ ដែលបានកំណត់ថា នៅក្នុងគ្រប់សកម្មភាពទាំងអស់ដែលទាក់ទងនឹងកុមាររងគ្រោះដោយសារការជួញដូរ ទោះបីជាត្រូវបានអនុវត្តដោយស្ថាប័នសុខុមាលភាពសាធារណៈរបស់រដ្ឋឬឯកជន នគរបាល តុលាការ អាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារទាំងនោះត្រូវគិតជាចម្បង។

នៅឆ្នាំ ២០០៩ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស[៨] ដែលបានចែងអំពីសិទ្ធិដែលត្រូវទទួលបានរបស់ជនរងគ្រោះ។ គោលបំណង និងគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងកិច្ចការពារ គឺផ្តោតលើការស្តារនីតិសម្បទា និងកិច្ចការពារពីការរងគ្រោះជាលើកទី២ ដោយសារឥរិយាបទសង្គម ឬអវេយិតភាពរបស់ទីភ្នាក់ងារស្ថាប័ន។

**ឃ. សំណងនៃការខូចខាត រួមទាំង សំណងជំងឺចិត្តចំពោះកុមាររងគ្រោះដោយអំពើហិង្សាដែរឬទេ ?**

**ចម្លើយ** :

សំណងនៃការខូចខាតដល់ជនរងគ្រោះអាចទទួលបានតាមរយៈចោទប្រកាន់ខាងព្រហ្មទណ្ឌ លើជនល្មើស។ សំណងជំងឺចិត្តដល់ជនរងគ្រោះត្រូវបានសម្រេចដោយតុលាការ និងត្រូវបង់ដោយជនល្មើស (ឬគ្រួសាររបស់ជនល្មើស) ។

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ អនុញ្ញាតឱ្យជនរងគ្រោះនៃបទល្មើសប្តឹងទាមទារសំណងនៃការខូចខាតនៅគ្រប់ពេលវេលា ទោះបីជាមិនមានដំណើរការនីតិវិធីបណ្តឹងព្រហ្មទណ្ឌ ឬក្នុងករណីដំណើរការនីតិវិធីបណ្តឹងព្រហ្មទណ្ឌត្រូវបានទុកចោល ឬលើកលែងការចោទប្រកាន់ ។

ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ តម្រូវឱ្យចៅក្រមជំរះសម្រេចលើបញ្ហាសំណងរដ្ឋប្បវេណី បើមានការស្នើសុំសម្រាប់ជនរងគ្រោះ រួមជាមួយនឹងការសម្រេចសេចក្តីអំពីការផ្តន្ទាទោសព្រហ្មទណ្ឌ ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា ៤៦ ចែងថា " ជនណាទទួលយកនូវផលប្រយោជន៍ ដោយគ្មានហេតុផលស្របច្បាប់ ដោយដឹងថា ផលប្រយោជន៍នោះ បានមកពីអំពើលក់ដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទ នឹងត្រូវទទួលខុសត្រូវលើសំណងបដិទានចំពោះអំពើទទួលបានផល

[៨] ក.ជ.ក, របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

ប្រយោជន៍មិនសមហេតុផល ព្រមទាំងការប្រាក់កើតឡើង ។ ជនដែលត្រូវគេកេងយកប្រយោជន៍ អាចប្តឹងទាមទារសំណងលើការខូចខាត ជាបន្ថែមលើសំណងបដិទានចំពោះអំពើទទួលបានប្រយោជន៍ ដោយមិនសមហេតុផល ។ ជនណាបានបង្កើតកិច្ចសន្យាឱ្យខ្ចី ឬការផ្តល់ផ្សេងទៀតទៅជនដទៃក្នុងគោលដៅធ្វើការលក់-ដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទមិនអាចប្តឹងទាមទារសំណងបដិទានចំពោះការផ្តល់នោះបានទេ។"

នៅព្រះរាជាណាចក្រកម្ពុជា មិនទាន់មានការកំហិតអាយុសម្រាប់ការដាក់ពាក្យប្តឹងទាមទារសំណងការខូចខាតនៅឡើយទេ ។ ច្បាប់បានផ្តល់ជំនួយពិសេសដល់កុមារក្នុងការទទួលបានយន្តការផ្លូវច្បាប់។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន និងគណៈមេធាវី បានផ្តល់ជំនួយផ្នែកច្បាប់ និងការការពារកុមារតាមផ្លូវច្បាប់ រួមទាំងក្នុងករណីសំណងរដ្ឋប្បវេណីផងដែរ ។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនស្នើឱ្យមានមធ្យោបាយជំនួសសំណងការខូចខាតចំពោះជនរងគ្រោះ។

**ង. ទណ្ឌកម្មលើជនល្មើសនៃអំពើហិង្សាលើកុមារដែរឬទេ?**

**ចម្លើយ** :

យោងតាមក្រមព្រហ្មទណ្ឌ ប្រសិនបើជនរងគ្រោះមានភាពងាយរងគ្រោះដោយសារអាយុរបស់ខ្លួន ជនល្មើសត្រូវទទួលស្ថានទម្ងន់ទោសនៅពេលដែលត្រូវបានកាត់ទោសពីបទមនុស្សឃាតដោយចេតនាការធ្វើទារុណកម្ម អំពើឃោរឃៅ អំពើហិង្សាដោយចេតនា ការបំពារបំពានផ្លូវភេទ ការបង្ខាំងទុកដោយខុសច្បាប់ ការគំរាមកំហែង ឬសញ្ចារកម្ម។

ក្រមព្រហ្មទណ្ឌកំណត់ទណ្ឌកម្មខុសៗគ្នាពីបទល្មើសមួយទៅបទល្មើសមួយទៀត ប៉ុន្តែគោរពតាមគោលការណ៍ដែលមានចែងក្នុងជំពូក១ និងជាទូទៅបញ្ចូលទណ្ឌកម្មបន្ថែមពីលើទោសពន្ធនាគារ និងទោសពិន័យជាប្រាក់ ។ យោងតាមជំពូក ១ ផ្នែក ២ មាត្រា ៥៣ ដល់មាត្រា ៧១ ជនល្មើសទទួលខុសត្រូវទោសបន្ថែមទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ ឧទាហរណ៍ ដីកាហាមឃាត់ ការដកហូតប័ណ្ណបើកបរ ការហាមឃាត់មិនឱ្យធ្វើការលើការងារវិជ្ជាជីវៈជាក់លាក់ក្នុងរយៈពេលមួយ។ មានទណ្ឌកម្មផ្សេងៗស្រាលជាងនេះ រួមមាន ទោសធ្វើការតាមសហគមន៍ដែលមានចែងក្នុងផ្នែកទី ៣ ។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងអំពីការទទួលខុសត្រូវរបស់ជនល្មើសក្នុងការផ្តល់សំណងបដិទាន ដែលបានមកពីផលកម្រៃមិនសមស្រប ក៏ដូចជាសំណងហិរញ្ញវត្ថុចំពោះការខូចខាត ។

**ច. ការស្តារ និងសមាហរណកម្ម កុមាររងគ្រោះដោយអំពើហិង្សាដែរឬទេ ?**

**ចម្លើយ** :

គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឆ្នាំ២០០៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានចែងពីសិទ្ធិ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងករណី ការត្រួតពិនិត្យតាមដាន និងការតាមដានបន្តលើជនរងគ្រោះដោយការជួញដូរ និងរួមទាំងបទប្បញ្ញត្តិពិសេសសម្រាប់កុមាររងគ្រោះ ។ គោលនយោបាយនេះមានបញ្ចូលទស្សនៈ

នៃការការពារសិទ្ធិជនរងគ្រោះដោយការជួញដូរមនុស្ស និងគំរូនៃកិច្ចការពារ ក៏ដូចជាគោលការណ៍ គោលនយោបាយទូទៅ និងគោលបំណង ។ ទាំងនេះនឹងមានភាពស៊ីសង្វាក់គ្នាទៅនឹងច្បាប់ ដែលបានកំណត់ពីកិច្ចការពារសិទ្ធិជនរងគ្រោះ រួមទាំងកម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០០៨ -២០១៣ ។[៩]

**៤. តើក្របខណ្ឌច្បាប់ មានបទប្បញ្ញត្តិជាក់លាក់ណាមួយដែលដោះស្រាយ នូវរាល់ទម្រង់នៃអំពើហិង្សា រួមទាំងអំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ និងផ្លូវចិត្ត ការធ្វើឱ្យរបួស ឬការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ ឬការមិនអើពើ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលកើតឡើងនៅក្នុង ៖**

**ក. បរិយាកាសគ្រួសារនិងផ្ទះឬទេ ?**

**ចម្លើយ** :

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ចែងពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារលើរូបរាងកាយ និងផ្លូវចិត្តលើសមាជិកគ្រួសារ រួមទាំងកុមារផងដែរ។ ច្បាប់មិនរាប់បញ្ចូលជាការប្រើហិង្សា ឬសកម្មភាពហិង្សាក្នុងគ្រួសារទេ រាល់ការប្រៀនប្រដៅដោយផ្តល់ដំបូន្មានដាស់តឿនក្រើនរំលឹក ឬចាត់វិធានការនានាសមស្រប ដើម្បីឱ្យសហព័ទ្ធ ឬកូន ឬអ្នកក្នុងបន្ទុក ឱ្យដើរតាមផ្លូវល្អ ហើយការអប់រំនេះ ធ្វើឡើងប្រកបដោយព្រហ្មវិហារធម៌ ស្របទៅតាមគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្ស និងសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា ។[១០]

មាតិកាទី៣ នៃក្រមព្រហ្មទណ្ឌ២០០៩ចែងពីបទល្មើសប្រព្រឹត្តលើកុមារនិងគ្រួសារ ច្បាប់នេះផ្តន្ទាទោសចំពោះការធ្វើបាប ផ្តន្ទាទោសដាក់ពន្ធនាគារឪពុកម្តាយ ឬអ្នកអាណាព្យាបាលចំពោះការធ្វើបាប ការបោះបង់ និងការទុកអនីតិជនចោលមិនយកចិត្តទុកដាក់ដែលអាចនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានចំពោះសុខភាព ឬការអភិវឌ្ឍរបស់កុមារ។ ក្រមព្រហ្មទណ្ឌក៏មានចែងពីបទល្មើសមួយចំនួនដែលប្រព្រឹត្តដោយបុព្វញាតិរបស់កុមារទៅលើកុមារដែលបន្ថែមស្ថានទម្ងន់ទោស ឧទាហរណ៍ មាត្រា៣៥១ មានចែងទោសបន្ថែម ចំពោះការផ្តន្ទាទោសពីបទរួមភេទជាមួយអនីតិជនដោយបុព្វញាតិ។

**ខ. សាលារៀន រួមទាំងការថែទាំតាមសាលាមត្តេយ្យ និងការអប់រំ (ទាំងការអប់រំក្នុងនិងក្រៅប្រព័ន្ធ រដ្ឋនិងឯកជន និងរួមទាំងអំពើហិង្សាផ្លូវភេទ និងការសម្លុតគំរាមកំហែង) ដែរឬទេ ?**

**ចម្លើយ** :

ច្បាប់ស្តីពីការអប់រំ[១១] កំណត់ថាសិស្សមានសិទ្ធិរួចផុតពីការធ្វើទារុណកម្ម ឬទណ្ឌកម្មលើរូបរាងកាយ ឬផ្លូវចិត្ត តម្រូវឱ្យគ្រប់បុគ្គលិកគោរពតាមក្រមសីលធម៌ និងគ្រូបង្រៀនមិនត្រូវធ្វើទារុណកម្មលើរូបរាងកាយ និងផ្លូវចិត្តដល់អ្នកសិក្សាឡើយ។

[៩] ក.ជ.ក, របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ច ខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

[១០] មាត្រា ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ កំណត់ពន្យល់ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ៖ ជីវប្រវត្តិ ទស្សនៈ និងគោលការណ៍ណែនាំសម្រាប់ការបកស្រាយរបស់ក្រសួងកិច្ចការនារី ឆ្នាំ២០០៧ ទំព័រ ៧៩ ។

[១១] មាត្រា៣៥ នៃច្បាប់ស្តីពីការអប់រំ

**គ. ស្ថាប័នថែទាំក្នុងមណ្ឌលរួមទាំងសម្រាប់សុខភាព និងសុខភាពផ្លូវចិត្តដែរឬទេ ?**

**ចម្លើយ** :

បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារកំណត់ថា ទណ្ឌកម្មវិន័យមិនគួរធ្វើឱ្យប៉ះពាល់ការអភិវឌ្ឍផ្នែករូបរាងកាយ បញ្ញាស្មារតី និងសង្គមឡើយ ។ បទដ្ឋាននេះ ហាមឃាត់ចំពោះការគំរាមកំហែង ស្តីបន្ទោសកុមារដោយប្រើពាក្យមិនសមរម្យ និងអាសគ្រាម ការប្រើកុមារឱ្យដាក់វិន័យលើកុមារដទៃទៀត ចងកុមារ បង្អត់អាហារ ឬទឹក ឬមិនព្យាបាលជំងឺ រារាំងកុមារមិនឱ្យទៅរៀន និងធ្វើការងារហួសកម្លាំងកាយ និងទណ្ឌកម្មវិន័យផ្សេងៗទៀត ដែលប៉ះពាល់ដល់ការអភិវឌ្ឍរូបរាងកាយ បញ្ញាស្មារតី និងសង្គមរបស់កុមារ។ ដើម្បីកាត់បន្ថយករណីរំលោភបំពាន ឬអំពើហិង្សាជាយថាហេតុ បទដ្ឋាននេះកំណត់ថា ការដាក់វិន័យលើកុមារអាចធ្វើទៅបានតែនៅពេលដែលកុមារមិនគោរពតាមបទបញ្ជាឬវិន័យប៉ុណ្ណោះ ។

ក្រមព្រហ្មទណ្ឌដាក់ទណ្ឌកម្មបន្ថែមចំពោះការបំពារបំពាន ឬការរំលោភបំពានដែលត្រូវបានប្រព្រឹត្តដោយជនដែលមានតួនាទីអនុវត្តចំពោះបុគ្គលិកនៅក្នុងមណ្ឌលថែទាំ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងធ្វើសេចក្តីព្រាងក្រមសីលធម៌សម្រាប់អនុវត្តលើគ្រប់បុគ្គលិកដែលធ្វើការក្នុងមណ្ឌលថែទាំកុមារ។

**ឃ. ស្ថាប័នយុត្តិធម៌អនីតិជន និងមណ្ឌលឃុំឃាំងផ្សេងៗទៀត ឬមណ្ឌលដែលអាចដាក់កុមារអន្តោប្រវេសន៍ កុមារស្វែងរកសិទ្ធិជ្រកកោន និងកុមារភៀសខ្លួន ដែរឬទេ?**

**ចម្លើយ** :

រដ្ឋធម្មនុញ្ញ មាត្រា៣៨ ហាមឃាត់ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬការប្រព្រឹត្តមិនល្អណាមួយដែលដាក់ទណ្ឌកម្មបន្ថែមលើអ្នកជាប់ឃុំ ឬទណ្ឌិត ។

ច្បាប់ស្តីពីពន្ធនាគារបានបញ្ចូលការហាមឃាត់ចំពោះការធ្វើទារុណកម្ម ការធ្វើឱ្យអាម៉ាស់ និងការប្រព្រឹត្តបន្ទាបបន្ថោក និងហាមឃាត់ចំពោះការអនុវត្តទណ្ឌកម្មវិន័យ រួមមានការប្រើប្រាស់អ្នកទោសឱ្យដាក់ទណ្ឌកម្មលើរូបរាងកាយអ្នកទោសដូចគ្នា និងឃុំឃាំងនៅក្នុងបន្ទប់ងងឹត ។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន មានបទប្បញ្ញត្តិដែលបញ្ចូលច្បាប់អន្តរជាតិអំពីការឃុំខ្លួនអនីតិជន ។

**ង. សហគមន៍ រួមទាំងអ្នកនៅជិតខាង តំបន់ជនបទ និងរួមទាំងអំពើហិង្សាដោយប្រើអាវុធៗ**

**ចម្លើយ** :

បទដ្ឋានអប្បបរមាស្តីពីការថែទាំតាមសហគមន៍ឆ្នាំ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្រដៀងនឹងបទដ្ឋានអប្បបរមាស្តីពីការថែទាំកុមារក្នុងមណ្ឌលឆ្នាំ២០០៦ ដែរ ដែលហាមឃាត់អំពីវិធានការដាក់វិន័យហួសប្រមាណ។ ជំពូក២ ប្រការ៣ ចំណុចទី៥ នៃបទដ្ឋានអប្បបរមាស្តីពីការថែទាំកុមារក្នុងមណ្ឌល ដូចគ្នានឹងជំពូក២ ប្រការ៤ ចំណុចទី៥ ស្តីពីការដាក់ទណ្ឌកម្មចំពោះកុមារបានហាមឃាត់ការធ្វើទារុណកម្មលើរូបរាងកាយ ដោយបានកំណត់អំពីទណ្ឌកម្មដែលត្រូវបានហាមឃាត់ដូចជាការគំរាមកំហែង ស្តីបន្ទោសកុមារដោយប្រើពាក្យមិនសមរម្យនិងអាសគ្រាម ការប្រើកុមារឱ្យដាក់

វិន័យលើកុមារដទៃទៀតចងកុមារ បង្អត់អាហារឬទឹកឬមិនព្យាបាលជំងឺ រារាំងកុមារមិនឱ្យទៅរៀន និងធ្វើការងារហួសកម្លាំងកាយ និងទណ្ឌកម្មវិន័យផ្សេងៗទៀតដែលប៉ះពាល់ដល់ការអភិវឌ្ឍរូបរាងកាយ បញ្ញាស្មារតី និងសង្គមរបស់កុមារ ។ ដើម្បីកាត់បន្ថយករណីរំលោភបំពាន ឬអំពើហិង្សាជាយថាហេតុ បទដ្ឋាននេះកំណត់ថា ការដាក់វិន័យលើកុមារអាចធ្វើទៅបានតែនៅពេលដែលកុមារមិនគោរពតាមបទបញ្ជាឬវិន័យប៉ុណ្ណោះ ។

រដ្ឋធម្មនុញ្ញផ្តល់កិច្ចការពារដល់កុមារក្នុងស្ថានភាពមានសង្គ្រាម ។ ចំណុចនេះ មានពិពណ៌នាក្នុងព័ត៌មានលម្អិតក្នុងរបាយការណ៍ជាតិលើកទី១និងទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការអនុវត្តពិធីសាបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ឆ្នាំ ២០០២-២០១០ (ភ្ជាប់ក្នុងឧបសម្ព័ន្ធ) ។

គោលនយោបាយភូមិឃុំមានសុវត្ថិភាព ត្រូវបានចេញដោយក្រសួងមហាផ្ទៃ ឆ្នាំ២០១០ ក្នុងគោលបំណង៖

- គ្មានសកម្មភាព លួច ឆក់ ប្លន់ គ្រប់ប្រភេទ
- គ្មានការផលិត ចែកចាយ ប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានអំពើអនាចារ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងគ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។

ក្នុងការអនុវត្តគោលនយោបាយនេះ ធ្លាប់បានបញ្ជូនកុមារតាមចិញ្ចើមថ្នល់ទៅមណ្ឌលថែទាំ និងអ្នកប្រើប្រាស់គ្រឿងញៀនទៅដាក់ក្នុងមណ្ឌលថែទាំ។

**ច. កន្លែងធ្វើការ (រៀបរយ និងមិនរៀបរយ ពាក់ព័ន្ធទាំងពលកម្មកុមារ និងការងារស្របច្បាប់ដែលធ្វើដោយកុមារលើសពីអាយុធ្វើការអប្បបរមតាមផ្លូវច្បាប់) ដែរឬទេ ?**

**ចម្លើយ** :

ក្រមព្រហ្មទណ្ឌ មាត្រា៣៣៩ មានកំណត់ពីបទដាក់អនីតិជនឱ្យស្ថិតក្នុងលក្ខខណ្ឌនៃការងារដែលបណ្តាលឱ្យខូចសុខភាព ឬសុខុមាលភាពរបស់កុមារ និងមាត្រា៣៤០ កំណត់ពីស្ថានទម្ងន់ទោសដោយសារមរណភាពនៃអនីតិជន ។ អាយុរបស់អនីតិជនមិនត្រូវបានកំណត់ និងការហាមឃាត់មិនត្រូវបានដាក់កំហិតចំពោះកន្លែងធ្វើការមិនរៀបរយ។ ក្រមព្រហ្មទណ្ឌក៏មានកំណត់ពីទណ្ឌកម្មដាក់ពន្ធនាគារ ពិន័យជាប្រាក់ ឬវិធានការផ្សេងៗទៀត រួមមាន ការហាមឃាត់ចំពោះការងារបុគ្គលក្នុងវិជ្ជាជីវៈដាក់លាក់ និងការដាក់ទណ្ឌកម្មដល់នីតិបុគ្គល រួមទាំងការបិទការិយាល័យ ឬប្រតិបត្តិការ ។

ច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ មាត្រា១៧៧ មានកំណត់ពីការហាមឃាត់ការធ្វើបាបនិយោជិត និងមានចែងពីអាយុអប្បបរមាត្រឹម១៥ឆ្នាំ អាចធ្វើការងារបាន ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញប្រកាស[១២] ដោយបញ្ញត្តិវិស័យដែលមានគ្រោះថ្នាក់ជាច្រើន ជាមួយនឹងប្រកាសចំនួន១២ទៀត

---

[១២] ប្រកាសលេខ ៣០៦ កប/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងចំការ។ ប្រកាសលេខ ៣០៧ កប/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីលក្ខខណ្ឌអនាម័យ និងសន្តិសុខការងារក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់ និងដេរស្បែកជើង។ ប្រកាសលេខ ៣០៨ កប/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសស្រែអំបិល និងប្រកាសលេខ ៣០៨ កប/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ។

ដែលពាក់ព័ន្ធនឹងបញ្ហាពលកម្មកុមារ ក្នុងនោះប្រកាសលេខ០០២/០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៨ ស្តីពីការកំណត់ប្រភេទមុខរបរ ការងារស្រាលដែលអនុញ្ញាតឱ្យកុមារអាចធ្វើការងារចាប់ពីអាយុពី១២ ដល់១៥ឆ្នាំ។

ដើម្បីពិនិត្យតាមដានពីការអនុវត្តច្បាប់ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតអធិការដ្ឋាន[១៣] ដើម្បីធ្វើអធិការកិច្ចលើភាពជាក់ស្តែង និងត្រួតពិនិត្យឯកសាររបស់និយោជិត ។ ច្បាប់ស្តីពីការងារតម្រូវឱ្យគ្រប់និយោជកបញ្ជូននូវការធ្វើអធិការកិច្ចប្រចាំឆ្នាំ នូវព័ត៌មានលម្អិតអំពីនិយោជិតទាំងអស់ដែលមានអាយុក្រោម ១៨ ឆ្នាំ។[១៤]

ច្បាប់ស្តីពីការងារ មានចែងពីទណ្ឌកម្មដាក់ពន្ធនាគារ និងពិន័យជាប្រាក់ចំពោះនិយោជកដែលរំលោភច្បាប់[១៥](សូមមេត្តាពិនិត្យចំលើយក្នុងអនុសាសន៍ទី៨ សម្រាប់ព័ត៌មានលម្អិតអំពីការធ្វើអធិការកិច្ចនិងការរាយការណ៍) ។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពីការងារមិនអនុវត្តចំពោះអ្នកធ្វើការងារតាមផ្ទះ និងការស្រាវជ្រាវបង្ហាញថា មានចំនួនអ្នកបំរើការងារតាមផ្ទះជាកុមារីយ៉ាងច្រើននៅកម្ពុជា។ វិស័យនេះទិន្នន័យមានចំនួនកំណត់ ប៉ុន្តែភាពខ្វះខាតទិន្នន័យនឹងត្រូវបានដោះស្រាយដោយការស្ទង់មតិជាមូលដ្ឋានសម្រាប់ការវាស់វែងឆ្នាំ ២០១២ ស្តីពីអំពើហិង្សាលើកុមារ ។

**៩. តើទណ្ឌកម្មលើរូបរាងកាយកុមារ នៅគ្រប់ទីកន្លែង ឬនៅកន្លែងមួយចំនួន រួមទាំងនៅផ្ទះផង ត្រូវបានហាមឃាត់យ៉ាងច្បាស់ដោយច្បាប់ដែរឬទេ ?**

**ចម្លើយ** :

មិនមាននិយមន័យអំពីទណ្ឌកម្មលើរូបរាងកាយនៅក្នុងច្បាប់កម្ពុជាទេ ។

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៤៥ បានអនុញ្ញាតឱ្យអ្នកមានអំណាចមេបាដាក់ទណ្ឌកម្មកូនដោយខ្លួនឯងនៅក្នុងទំហំដែលចាំបាច់បាន ។ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ អនុញ្ញាតឱ្យដាក់ទណ្ឌកម្ម និងទូន្មានប្រៀនប្រដៅ ដរាបណាការដាក់ទណ្ឌកម្មនោះត្រូវបានដាក់ក្នុងលក្ខណៈប្រកបដោយព្រហ្មវិហារធម៌ និងស្របទៅតាមគោលការណ៍នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាស្តីពីសិទ្ធិកុមារ របស់អង្គការសហប្រជាជាតិ ។[១៦]

អំពើហិង្សាក្នុងគ្រួសារ ត្រូវបានកំណត់ពាក់ព័ន្ធនឹងអ្វីដែលអាចទទួលយកបានថាជាទណ្ឌកម្មលើរូបរាងកាយ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ មាត្រា៤ បានកំណត់អំពើហិង្សាក្នុងគ្រួសារ រួមមាន អំពើដែលប៉ះពាល់ដល់ជីវិត អំពើដែលប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ និងការឈ្លានពានខាងផ្លូវភេទ[១៧] និងមាត្រា៨ ពង្រីកនិយមន័យដោយបញ្ចូលការគំរាមកំហែងក្នុងគោលបំណងធ្វើឱ្យជនរងគ្រោះភ័យខ្លាច តក់ស្លុត និងអំពើប៉ះពាល់ដល់បុគ្គលភាព និងទ្រព្យសម្បត្តិ។ អំពើហិង្សាក្នុងគ្រួសារត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារតាមក្រមព្រហ្មទណ្ឌ ។

---

[១៣] មាត្រា២៣៣-២៣៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

[១៤] មាត្រា១៧៩ និង១៨០នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

[១៥] មាត្រា៣៥៩ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧

[១៦] មាត្រា ៨ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ កំណត់ពន្យល់នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ:ជីវប្រវត្តិ ទស្សនៈ និងគោលការណ៍ណែនាំសម្រាប់ការបកស្រាយ របស់ក្រសួងកិច្ចការនារី ឆ្នាំ២០០៧ ទំព័រ ៧៥។

[១៧] មាត្រា៣នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។

ទណ្ឌកម្មលើរូបរាងកាយត្រូវបានហាមឃាត់នៅកន្លែងភាគច្រើន ក្រៅផ្ទះ ក្នុងសាលា និងគ្រឹះស្ថានអប់រំ (ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧ និងប្រកាសលេខ៩២២ ម.ស.ទ ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០០៦ ទាក់ទងនឹងបញ្ហានៃការដាក់ទណ្ឌកម្មលើសិស្សដែលបានចេញដោយក្រសួងអប់រំ យុវជន និងកីឡា) ប្រព័ន្ធទណ្ឌកម្ម (ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩) និងក្នុងមណ្ឌលថែទាំជំនួស (បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៨ ) ។

ច្បាប់ស្តីពីពន្ធនាគារហាមឃាត់យ៉ាងច្បាស់ពីទណ្ឌកម្មលើរូបរាងកាយលើអ្នកទោសទាំងអស់ ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានបញ្ចូលនូវបទដ្ឋានអន្តរជាតិសម្រាប់កន្លែងឃុំខ្លួនអនីតិជន និងក៏បានហាមឃាត់ផងដែរចំពោះទណ្ឌកម្មលើរូបរាងកាយ។

**៦. តើក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យមានទណ្ឌកម្មលើរូបរាងកាយទោសដាក់ពន្ធនាគារអស់មួយជីវិត និង/ឬ ទោសប្រហារជីវិត ជាទោសសម្រាប់ដាក់ចំពោះបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តដោយកុមារអាយុក្រោម ១៨ឆ្នាំ ដែរឬទេ ?**

**ចម្លើយ** :

រដ្ឋធម្មនុញ្ញ មាត្រា៣៨ បានហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គល និងការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តអំពើណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មសម្រាប់អនុវត្តចំពោះជនជាប់ចោទ ឬពិរុទ្ធជន ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។

ក្រមព្រហ្មទណ្ឌ មាត្រា៣៨ ដល់មាត្រា៤១ កំណត់ពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ។

- មាត្រា៣៨ចែងថា "នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ"។
- មាត្រា៣៩ ចែងថា "អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ" ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈ ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។
- មាត្រា៤០ ចែងថា "វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថមមានតទៅ ៖
  - ១- ការប្រគល់អនីតិជន ឱ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជន នោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត ។
  - ២- ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន ។
  - ៣- ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន
  - ៤- ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស ។
  - ៥- ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ" ។
- មាត្រា៤១ ចែងថា "ក្នុងករណីដាក់ឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូប ដែលទទួលភារៈធ្វើការតាមដានអនីតិជន ។ បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមាយាទរបស់អនីតិជនឱ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា ។ បុគ្គលនេះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញា អំពីព្រឹត្តិការទាំងអស់ ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ ។

ទោសសម្រាប់អនីតិជនដែលត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ មានចែងក្នុងក្រមព្រហ្មទណ្ឌ ជំពូក៦។

ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានកំណត់ទោសអប្បបរមានិងអតិបរមា សម្រាប់បទល្មើសនីមួយៗផងដែរ។ ប៉ុន្តែយោងតាមមាត្រា១៦០នៃក្រមព្រហ្មទណ្ឌ គ្មានករណីណាដែលអនីតិជនត្រូវទទួលទោសជាប់ពន្ធនាគាររយៈពេលអស់មួយជីវិតនោះទេ ក្នុងករណីដែលទោសអតិបរមាអាចជាប់ពន្ធនាគារអស់មួយជីវិតសម្រាប់អនីតិជន គឺច្បាប់ឱ្យបន្ថយមកនៅត្រឹម២០ឆ្នាំប៉ុណ្ណោះ។

សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនមានចែងពីវិធានការបង្វែរ ដែលសំណងការខូចខាតអាចធ្វើទៅតាមវិធានការសម្របសម្រួល ដោយអាជ្ញាធរបង្វែរ ដែលជាវិធានការជំនួសឱ្យការជំនុំជម្រះទោស ។

**៧. តើក្របខណ្ឌច្បាប់ដោះស្រាយ ឬហាមឃាត់ការអនុវត្តជាប្រពៃណី/ដែលបង្កឱ្យមានអន្តរាយ មានជាអាទិ៍ ការកាត់អវៈយវៈភេទស្ត្រី ការរៀបការឆាប់ពេក ឬដោយបង្ខំ បទល្មើសព្រហ្មទណ្ឌទាក់ទងនឹងអំពើអាបធ្មប់ ឬបទល្មើសទាក់ទងនឹងកិត្តិយសដែរឬទេ?**

**ចម្លើយ** :

ក្រមសីលធម៌ប្រពៃណីសម្រាប់ស្ត្រីនិងបុរស (ច្បាប់ស្រីនិងច្បាប់ប្រុស) ជាមូលដ្ឋានសម្រាប់វប្បធម៌កម្ពុជាក្នុងប៉ុន្មានសតវត្សរ៍កន្លងមកនេះ ដោយបង្កើតឱ្យមានទំនាក់ទំនងវិសមភាពយេនឌ័រ។ ក្រមសីលធម៌ទាំងនេះ ត្រូវបានហាមឃាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (របបប៉ុលពត) បច្ចុប្បន្នមិនមានលក្ខណៈតាមផ្លូវច្បាប់ឡើយនៅព្រះរាជាណាចក្រកម្ពុជា និងមិនត្រូវបានឱ្យប្រើដោយរាជរដ្ឋាភិបាលនោះទេ ប៉ុន្តែជាទិដ្ឋភាពទាក់ទាញនៃកេរ្តិ៍តំណែលពីដូនតាជាប្រពៃណី និងមិនបានបញ្ចូលក្នុងកម្មវិធីសិក្សាសាលាឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយវប្បធម៌នៃក្រមសីលធម៌ទាំងនេះ នៅតែដក់ក្នុងចិត្តរបស់ពលរដ្ឋក្នុងសង្គមកម្ពុជា ។

**៨. តើច្បាប់អនុវត្តស្មើគ្នាចំពោះកុមារទាំងអស់ រួមទាំងកុមារដែលគ្មានសញ្ជាតិ និងកុមារដែលគ្មានរដ្ឋដែរឬទេ?**

**ចម្លើយ** :

រដ្ឋធម្មនុញ្ញ មាត្រា៣១ វាក្យខណ្ឌ២ ចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។"

ការវិភាគលើក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងការការពារកុមារ ដើម្បីស្វែងរកភាពខ្វះចន្លោះ ជាជំហានទៅមុខដ៏មានសារសំខាន់មួយ ក្នុងការធ្វើឱ្យមានភាពច្បាស់លាស់នូវការរៀបចំកំណែទម្រង់គោលនយោបាយដែលអាចដោះស្រាយនូវភាពខ្វះចន្លោះនៅក្នុងច្បាប់ជាតិទាក់ទងនឹងភាពគ្មានសញ្ជាតិ ។

ការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលមានគោលនយោបាយបំពេញទៅតាមតម្រូវការរបស់កុមារនៃជនជាតិខុសគ្នា ជាក់ស្តែង ទោះបីជាភាសាសម្រាប់ការអប់រំជាភាសាខ្មែរ ប៉ុន្តែក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំការអប់រំជា ២ ភាសា នៅក្នុងសាលាមត្តេយ្យ និងសាលាបឋមសិក្សា[១៨]។

**៩. តើច្បាប់ហាមឃាត់ចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ រួមទាំងតាមរយៈពេស្យាចារ្យ និងសកម្មភាពផ្លូវភេទខុសច្បាប់ផ្សេងៗទៀតដែរឬទេ?**

**ចម្លើយ** :

មាត្រា៣១នៃរដ្ឋធម្មនុញ្ញចែងថា " ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមាន

---

[១៨] កម្មវិធីនេះអនុវត្តលើថ្នាក់ទី១-៣ និងត្រូវបានអនុវត្តនៅក្នុងសាលាចំនួន២៧ ក្នុងខេត្តចំនួន០៣ ដោយមានចំនួនសិស្សជាជនបរទេសច្រើនដែលទទួលបានលទ្ធផលលើសិស្សសរុបចំនួន ២៣៥៩ នាក់ (ស្រី ១ ០៥៤ នាក់)

ចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ”។ និងមាត្រា៤៨ ចែងថា“ រដ្ឋ ធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ”។

ក្រមព្រហ្មទណ្ឌ មាត្រា២៣៦ ដល់មាត្រា២៥២ កំណត់ពីការរំលោភសេពសន្ថវៈ និងការបំពានផ្លូវភេទដោយត្រូវបានផ្តន្ទាទោស ទណ្ឌកម្មត្រូវបានបង្កើនប្រសិនបើជនរងគ្រោះមានលក្ខណៈទន់ខ្សោយដោយមូលហេតុអាយុ ឬពិការភាព ។ មានបទល្មើសដោយឡែកពីការរួមភេទជាមួយអនីតិជនដោយបុព្វញាតិ យោងតាមមាត្រា ៣៥១ ដល់មាត្រា៣៥២។

ក្រមព្រហ្មទណ្ឌ មាត្រា២៥៣ ដល់មាត្រា២៦០ កំណត់ពីការផ្តន្ទាទោសចំពោះបទដកយកអនីតិជនដោយផ្ទុយច្បាប់ពីបុគ្គលដែលថែរក្សាស្របច្បាប់ ។ មាត្រា៣២៧ កំណត់ពីការចាប់ឃុំឃាំង និងបង្ខាំងមនុស្ស និងមាត្រា២៧៤ កំណត់ពីការផ្តន្ទាទោសចំពោះការធ្វើអាជីវកម្មលើភាពទន់ខ្សោយ ឬអនិស្សរភាព (dependence) តាមរយៈការដាក់ពួកគេឱ្យស្ថិតក្នុងលក្ខខណ្ឌនៃការងារដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ។ មាត្រា២៨៤ ដល់មាត្រា២៩៦ សញ្ចារកម្មត្រូវបានផ្តន្ទាទោសតាមដែលមានចែងពីសញ្ចារកម្ម រួមទាំងការការពារ ការរៀបចំ ឬបិទបាំងដំណើរការប្រព្រឹត្តទៅនៃបទល្មើស និងរារាំងដល់ការបង្ការអំពើពេស្យាចារ ។ មានស្ថានទម្ងន់ទោសប្រសិនបើជនរងគ្រោះជាអនីតិជន ជនល្មើសជាបុព្វញាតិរបស់ជនរងគ្រោះ ឬជនល្មើសប្រើប្រាស់អំណាចរបស់ខ្លួន ប្រើប្រាស់កម្លាំង ឬធ្វើទារុណកម្ម ឬអំពើឃោរឃៅ។ ការដំណើរការ ឬយល់ព្រមឱ្យដំណើរការគ្រឹះស្ថានពេស្យាចារ ត្រូវហាមឃាត់ ។

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទត្រូវផ្តន្ទាទោស និងកំណត់ទណ្ឌកម្មសម្រាប់ការចាប់ពង្រត់ និងការជួញដូរសម្រាប់គោលបំណងកេងប្រវ័ញ្ច រួមទាំងពេស្យាចារ និងរូបភាពនិងសម្ភារៈអាសអាភាស។

ច្បាប់ស្តីពីទេសចរណ៍ហាមឃាត់ គ្រប់ទេសចរណ៍ប្រើប្រាស់ពេស្យាចារកុមារ និងរូបភាពនិងសម្ភារៈអាសអាភាស និងកំណត់កាតព្វកិច្ចរាយការណ៍ចំពោះអ្នកធ្វើការផ្នែកទេសចរណ៍ចំពោះការរំលោភបំពានដែលត្រូវបានសង្ស័យ ។

ក្រសួងយុត្តិធម៌បានផ្តល់នូវគោលការណ៍ណែនាំដែលមានបទប្បញ្ញត្តិដូចខាងក្រោម ៖

- សេចក្តីណែនាំស្តីពីការចោទប្រកាន់ និងការផ្តន្ទាទោសចំពោះជនដែលប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ
- សេចក្តីណែនាំ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០០៥ ស្តីពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅមានជាធរមានទាក់ទងនឹងការការពារជនរងគ្រោះ

- សេចក្តីណែនាំលេខ០១ កយសណន/០៩ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០០៩ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តមាត្រា៤២ និងមាត្រា៤៣នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨
- គោលការណែនាំលេខ០០១ សណន បជរពភ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨
- ប្រកាសលេខ៦២ កយប្រក/០៨ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨ ស្តីពីការប្រើប្រាស់របាំង និងបណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្មពីកុមារ/ជនរងគ្រោះ ឬសាក្សីដែលងាយរងគ្រោះ[១៩]។

**១០. តើច្បាប់ហាមឃាត់ចំពោះការប្រើប្រាស់កុមារនៅក្នុងសកម្មភាពឧក្រិដ្ឋដែរឬទេ ?**

**ចម្លើយ** :

នៅព្រះរាជាណាចក្រកម្ពុជា ច្បាប់បានហាមឃាត់ការប្រើប្រាស់កុមារក្នុងសកម្មភាពឧក្រិដ្ឋកម្ម។ ជនណាដែលប្រើកុមារ ក្នុងសកម្មភាពឧក្រិដ្ឋកម្មត្រូវផ្តន្ទាទោសតាមច្បាប់ក្រមបហ្មទណ្ឌដែលមានបញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌរួមមាន ៖

- មាត្រា៣៤៣ចែងថា "បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុន ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ" ។
- មាត្រា៣៤៤ ចែងថា បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់"។
- មាត្រា៣៤៥ចែងថា " ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស ៖

  ១- ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

  ២- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

  ៣- ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

  ៤- កាហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

  ៥- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

  ៦- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស ឬសម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

  ៧- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស នៅក្នុងសារព័ត៌មាន ។

  ៨- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

- មាត្រា៣៤៦ ចែងថា "គ្រប់អំពើប៉ះពាល់ស្វាបអង្អែលកេរ្តិ៍ភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រចិត្តផងទេ ឬបង្ខំបុគ្គលដទៃទៀតឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជើបរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្ត

---

[១៩] ក.ជ.ក ៖ របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

កេរ្តិ៍ខ្មាស់ ។ អំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ)ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២០០០ ០០០ (ពីរលាន) រៀល ទៅ ៦០០០ ០០០ (ប្រាំមួយលាន) រៀល។"

ក្រមព្រហ្មទណ្ឌ មាត្រា៣៦ កំណត់មិនឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងករណីអំពើល្មើសប្រព្រឹត្តក្រោម "អានុភាពនៃកម្លាំងឬការបង្ខំ" ។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌ អនីតិជនស្នើឱ្យមានការកែប្រែថា "អានុភាពនៃកម្លាំងឬការបង្ខំ" រួមបញ្ចូលទាំងការណែនាំរបស់ឪពុកម្តាយ ឬអ្នកថែទាំនិងគ្រប់គ្រងកុមារ ដើម្បីជៀសវាងកុំឱ្យកុមារទទួលការផ្តន្ទាទោសចំពោះអំពើដែលត្រូវប្រព្រឹត្តដោយប្រើកម្លាំង ការអូសទាញ ឬតាមរយៈការណែនាំពីជនដែលមានអំណាចពិតប្រាកដលើកុមារ ។ កុមារមិនត្រូវបានផ្តន្ទាទោសចំពោះអំពើអូសទាញក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាចារផ្ទាល់ខ្លួននៅកន្លែងសាធារណៈ[២០]។

**១១. តើច្បាប់ហាមឃាត់ចំពោះរាល់ទម្រង់នៃការលក់ ឬការជួញដូរកុមារដែរឬទេ ?**

**ចម្លើយ** :

ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទត្រូវបានអនុម័តនៅឆ្នាំ ២០០៨ ។ ច្បាប់នេះជាការអនុវត្តអនុលោមតាមពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និងផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារដែលបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។

ច្បាប់នេះហាមឃាត់រាល់អំពើពាក់ព័ន្ធនឹងការជួញដូរកុមារ[២១] រួមមាន អំពើជួញដូរមនុស្សក្នុងគោលដៅធ្វើអាជីវកម្ម រួមទាំងរកប្រាក់ចំណេញ និងរូបភាពអាសអាភាស[២២]។ មានស្ថានទម្ងន់ទោស ប្រសិនបើជនរងគ្រោះជាកុមារ ព្រមទាំងហាមឃាត់ការយកចេញដោយខុសច្បាប់សម្រាប់នាំឆ្លងដែន ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច អំពើលក់ដូរមនុស្សដោយមានគោលដៅ (ដូចជាកេងយកចំណេញ ឬការផលិតរូបភាពនិងសម្ភារៈអាសអាភាស) អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន ការដឹកជញ្ជូន (ឆ្លងដែន) ដោយមានគោលដៅ ការទទួលយកមនុស្សដោយមានគោលដៅ ។ បទល្មើសត្រូវបានបន្ថែមស្ថានទម្ងន់ទោស ប្រសិនបើជនរងគ្រោះជាអនីតិជន។

ច្បាប់ស្តីពីសុំកូនអន្តរប្រទេស២០០៩ និងក្រមព្រហ្មទណ្ឌ២០១០ មានចែងពីទណ្ឌកម្មសម្រាប់ឪពុកម្តាយដែលលក់ទារក[២៣]។

អនុក្រឹត្យលេខ ១៩០/២០១១ អនប្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការការគ្រប់គ្រងការបញ្ជូនប្រជាពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីការពារការកេងប្រវ័ញ្ចកម្មករកម្ពុជាដែលចាកចេញដោយស្ម័គ្រចិត្ត។

**១២. តើច្បាប់ហាមឃាត់ចំពោះការប្រើប្រាស់កុមារ សញ្ជារកម្មកុមារ ឬការផ្តល់កុមារ សំរាប់ការផលិតរូបភាពអាសអាភាស ឬសម្រាប់ការសម្តែងសកម្មភាព អាសអាភាសដែរឬទេ ?**

---

[២០] មាត្រា២៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨។

[២១] មាត្រា៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ ។

[២២] មាត្រា១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

[២៣] មាត្រា ៣៣១និងមាត្រា ៣៣២ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៥៩(២),(៣) នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ។

**ចម្លើយ** :

ច្បាប់ហាមឃាត់អំពើសញ្ញារកម្មពាក់ព័ន្ធនឹងកុមារ ឬការប្រើប្រាស់កុមារឱ្យធ្វើពេស្យាចារ គឺជាបទឧក្រិដ្ឋដែលត្រូវផ្តន្ទាទោស។ (សម្រាប់ព័ត៌មានលម្អិត សូមពិនិត្យរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឆ្នាំ២០០២-២០១០ )។

**១៣.** តើច្បាប់ហាមឃាត់ ការកាន់កាប់ និងការផ្សព្វផ្សាយនូវរូបភាពអាសអាភាសកុមារ រួមទាំងតាមរយៈអ៊ីនធឺណេតដែរឬទេ ?

**ចម្លើយ** :

មាត្រា៤០នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទកំណត់និយមន័យរូបភាពនិងសម្ភារៈអាសអាភាសកុមារ ជា“សម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិចដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជនដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ” ។[២៤] មាត្រា៤១នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តន្ទាទោសចំពោះជនណាដែលចែកចាយ លក់ ជួល ដាក់តាំង បញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ និងហាមឃាត់ការកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញ ឬផ្សព្វផ្សាយសម្ភារៈអាសអាភាសសម្រាប់ប្រព្រឹត្តបទល្មើសទាំងនេះ។

បទប្បញ្ញត្តិនេះមិនបានពង្រីកទីកន្លែងឯកជន និងមិនមែនជាបទល្មើសទេ ចំពោះការទុករូបភាពអាសអាភាស ឬដាក់តាំងរូបភាពនោះនៅកន្លែងឯកជន ឬទាញយករូបភាពពីប្រព័ន្ធអ៊ិនធើណេត សម្រាប់ទុកផ្ទាល់ខ្លួននិងមើលផ្ទាល់ខ្លួន ។

រួមជាមួយទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ ច្បាប់ក៏មានចែងពីទណ្ឌកម្មរដ្ឋប្បវេណីលើអ្នកទេចរណ៍ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ ការបោះពុម្ពផ្សាយរូបភាព និងសម្ភារៈអាសអាភាស[២៥] រួមទាំងការដកទិដ្ឋាការ ។ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ផ្តន្ទាទោសចំពោះការផ្សាយពាណិជ្ជកម្មពេស្យាចារកុមារ[២៦]។

## **អនុសាសន៍ទី៣ : ផ្តល់អាទិភាពដល់ការបង្ការទប់ស្កាត់**

**១.** សូមផ្តល់នូវសេចក្តីសង្ខេបនៃកម្មវិធីដែលបានផ្តល់ដោយរដ្ឋាភិបាលរបស់អ្នក សំដៅបង្ការទប់ស្កាត់អំពើហិង្សាលើកុមារ ដោយផ្តោតលើហានិភ័យ និងកត្តានានាដែលបានកំណត់នៅក្នុងអនុសាសន៍នេះ និង/ឬកម្មវិធីដែលត្រូវបានគាំទ្រដោយផ្ទាល់ដោយរដ្ឋាភិបាល ហើយអនុវត្តដោយទីភ្នាក់ងារផ្សេងៗទៀតៗ សូមមេត្តាផ្តល់ព័ត៌មានលម្អិត ក្នុងនោះ រួមមានព័ត៌មានអំពីការបម្រុងទុកធនធាន (ជាថវិកាឬថវិកាជាតិ) ដើម្បីធានាឱ្យមានភាពអាចទទួលបានជាទូទៅនូវសេវាសង្គមកិច្ចជាមូលដ្ឋានដែលមានគុណភាព និង កិច្ចការពារផ្នែកសង្គមដែលយកជនស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ជាគោលដៅ។

---

[២៤] មាត្រា ៤០ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

[២៥] មាត្រា ៦៨ នៃច្បាប់ស្តីពីទេសចរណ៍។

[២៦] មាត្រា ៣៥-៣៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨ ។

**ចម្លើយ** :

របាយការណ៍ឆ្នាំ២០០៦ ស្តីពីអំពើហិង្សាលើកុមារ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានភាពស្របគ្នាជាមួយនឹងការប៉ាន់ប្រមាណស្តីពីភាពក្រីក្ររបស់កម្ពុជា និងរបាយការណ៍របស់ធនាគារពិភពលោកស្តីពីការគ្រប់គ្រងហានិភ័យនិងភាពងាយរងគ្រោះនៅកម្ពុជា *(ការប៉ាន់ប្រមាណនិងយុទ្ធសាស្ត្រស្តីពីកិច្ចការពារសង្គម ខែមិថុនា ឆ្នាំ២០០៦)*។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ អនុវត្តយុទ្ធសាស្ត្រចតុកោណ ដោយយកការកាត់បន្ថយភាពក្រីក្រ និងអភិបាលកិច្ចល្អជាចំណុចស្នូលរបស់ខ្លួន និងបញ្ហាកិច្ចការពារកុមារជាបញ្ហាពហុវិស័យ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ថាភាពក្រីក្រ និងការតស៊ូនឹងភាពខ្វះខាតជីវភាពនៅក្នុងគ្រួសារ គឺជាកត្តាមួយធ្វើឱ្យមានហានិភ័យសម្រាប់កុមារ ធ្វើឱ្យមានភាពងាយស្រួលបែកចេញពីគ្រួសារ ការកេងប្រវ័ញ្ចនៅកន្លែងការងារដែលមានគ្រោះថ្នាក់ និងការកេងប្រវ័ញ្ចផ្លូវភេទ ។ សហគមន៍ដាច់ស្រយ៉ាល ដែលការធ្វើដំណើរ និងទូរគមនាគមន៍ មានការលំបាក ទទួលបានតិចតួចនូវសេវារបស់រាជរដ្ឋាភិបាល និងជំនួយសង្គ្រោះបន្ទាន់ពីយន្តការគាំទ្រផ្សេងៗទៀត។

បច្ចុប្បន្នរាជរដ្ឋាភិបាល បាននិងកំពុងស្តារ ជួសជុល និងថែទាំប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាប្រព័ន្ធ ដើម្បីតភ្ជាប់ពីតំបន់ដាច់ស្រយាលមកទីជនបទ ពីទីជនបទមកទីប្រជុំជន ជាផលប្រយោជន៍ និងជាឱកាសសម្រាប់កុមារអាចធ្វើដំណើរទៅសាលារៀន មណ្ឌលសុខភាព ផ្សារ និងទីប្រជុំជន ដោយកាត់បន្ថយពេលវេលាធ្វើដំណើរ មធ្យោបាយធ្វើដំណើរមានតម្លៃថោក និងបានផ្តល់ទឹកស្អាតដល់ប្រជាពលរដ្ឋដែលបានរស់នៅតាមតំបន់ដាច់ស្រយាល និងជនបទ ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាលបានសហការជាមួយអង្គការមិនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ធ្វើការផ្សព្វផ្សាយអំពីការលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ ការកេងប្រវ័ញ្ចផ្លូវភេទការកេងប្រវ័ញ្ចពលកម្មលើកុមានៅនិងកន្លែងធ្វើការ អប់រំស្តីពីការប្រើប្រាស់ទឹកស្អាត និងលាងដៃជាមួយនឹងសាប៊ូ ឬផេះ បន្ទាប់ពីបន្ទោរបង់រួច និងមុនពេលញ៉ាំអាហារ ដើម្បីកាត់បន្ថយជំងឺរាគរូស គ្រុន ពោះវៀន ទាចទឹក ។ល។ សកម្មភាពទាំងនេះអាចប្រព្រឹត្តទៅបាន គឺអាស្រ័យដោយមានហេដ្ឋារចនា សម្ព័ន្ធរូបវន្តជាប្រព័ន្ធ រួមផ្សំជាមួយវិស័យផ្សេងៗទៀត។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ឆ្នាំ២០១១-២០១៥ ដែលមានអាណត្តិអន្តរាគមន៍ដោយមានកញ្ចប់ថវិកាសម្រាប់សង្គ្រោះបន្ទាន់នៅពេលមានវិបត្តិ និងផែនការជាតិស្តីពីការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥ ផ្តល់នូវថវិកា និងផែនការផ្តល់អាហារូបករណ៍ដល់គ្រួសារក្រីក្រដោយមានកូតាខ្ពស់សម្រាប់កុមារី ។

ការបង្កើតរចនាសម័ន្ធឃុំ/សង្កាត់ និងវិមជ្ឈការនៃសេវាកម្ម គួរតែពិនិត្យមើលនៅតំបន់ភូមិសាស្ត្រងាយរងគ្រោះបំផុត ហើយនៅឆ្ងាយពីគេតិចតួច តាមរយៈបណ្តាញរាយការណ៍ខ្សែទឹង និងបណ្តោយ។ សមាជិកឃុំ/សង្កាត់ មានអន្តរាគមន៍ពិសេស និងកាតព្វកិច្ចរាយការណ៍ក្នុងករណីដែលមានអំពើហិង្សាការកេងប្រវ័ញ្ចផ្លូវភេទ ឬពលកម្ម ដែលជារឿងហេតុថ្មីៗ និងការគាំទ្រទៅក្នុងសហគមន៍ និងគ្រួសារ ។[២៧] រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ថា ឥរិយាបទសង្គមចំពោះយេនឌ័រ[២៨] កំពុងតែ

---

[២៧] សេចក្តីណែនាំស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ២០០៧

[២៨] ច្បាប់ស្រី និងច្បាប់ប្រុស

នៅមានឥទ្ធិពលដាក់កំហិតលើការអភិវឌ្ឍទាំងកុមារា និងកុមារី ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានត្រួតពិនិត្យឃើញថា ការកាត់បន្ថយហានិភ័យ តាមរយៈការដាក់បញ្ញត្តិ និងការធ្វើអធិការកិច្ចនៅកន្លែងធ្វើការគឺជាវិធានមួយសមស្របដើម្បីអន្តរាគមន៍ បង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការផ្លាស់ប្តូរឥរិយាបទជាប្រពៃណីចំពោះអំពើហិង្សាក្នុងគ្រួសារ ការចាត់វិធានការយ៉ាងសកម្មដើម្បីបង្ការទប់ស្កាត់ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទ និងការការពារកុមារឱ្យរួចផុតពីទុក្ខទោស។

២. សូមផ្តល់ព័ត៌មានអំពីគោលនយោបាយ ច្បាប់ ឬគោលការណ៍ណែនាំ ដើម្បីការពារកុមារពីព័ត៌មានដែលមានគ្រោះថ្នាក់ និងសម្ភារៈដែលត្រូវបានបញ្ជូនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ អ៊ីនធឺណេត វីដេអូ ល្បែងតាមប្រព័ន្ធអេឡិកត្រូនិក និងផ្តល់អំណាចដល់កុមារ ដើម្បីបង្ការទប់ស្កាត់ស្ថានភាពគ្រោះថ្នាក់បែបនេះ។

**ចម្លើយ** :

វិធានការដែលបានប្រកាន់យកដើម្បីគ្រប់គ្រងលើភាពដែលងាយរកបាននៃរូបភាពនិងសម្ភារៈអាសអាភាសផ្សេងៗទៀតរបស់កុមារគឺមានព័ត៌មានលម្អិតក្នុងរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឆ្នាំ២០០២-២០១០ ដែលបានបញ្ជូននៅឆ្នាំ២០១១ ។ ប្រកាសលេខ២២០ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើអាជីវកម្មនិងសេវាកម្មលក់ និងជួលភាពយន្តនិងវីដេអូ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានការព្រួយបារម្ភថា ការប្រើប្រាស់រូបភាពនិងសម្ភារៈអាសអាភាស ធ្វើឱ្យមានទំនាក់ទំនងទៅនឹងអំពើហិង្សាផ្លូវភេទលើស្ត្រីនិងក្មេងស្រី មានចំនួនកើនឡើងនៃការរំលោភសេពសន្ថវៈ និងការរំលោភជាក្រុម[២៩] និងមានចំនួនកើនឡើងនៃជនល្មើសដែលត្រូវបានកត់ត្រាមានអាយុក្រោម ១៨ឆ្នាំ។

## អនុសាសន៍ទី៤ : លើកស្ទួយតម្លៃអំពើអហិង្សា និងការលើកកម្ពស់ការយល់ដឹង

១. តើរដ្ឋាភិបាលរបស់អ្នកបានធ្វើ ឬ ប្រគល់ឱ្យធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីសិទ្ធិកុមារ ក្នុងការរួចចាកពីអំពើហិង្សា និងបង្ការទប់ស្កាត់អំពើហិង្សាលើកុមារដែរឬទេ ? ប្រសិនបើបានធ្វើ សូមមេត្តារៀបរាប់ពីយុទ្ធនាការថ្មីៗណាមួយ ទីកន្លែង និងប្រភេទនៃអំពើហិង្សាដែលបានធ្វើយុទ្ធនាការ និងក្រុមគោលដៅ (សាធារណៈជនទូទៅ អ្នកថែទាំ គ្រូបង្រៀន។ល។) រួមទាំងគំនិតផ្តួចផ្តើមជាក់លាក់សម្រាប់កុមារ ក៏ដូចជាអនុវត្តដែលត្រូវបានវាស់វែងផងដែរ ។

**ចម្លើយ** :

ផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឆ្នាំ២០១១-២០១៣ មានការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិជាគោលដៅយុទ្ធសាស្ត្រ។

រាជរដ្ឋាភិបាល នឹងដាក់បញ្ចូលភារកិច្ចនេះទៅក្នុងកាតព្វកិច្ចរបស់រដ្ឋអំណាចនៅគ្រប់ថ្នាក់នៅក្នុងការគ្រប់គ្រងរបស់រដ្ឋ ។ គណៈកម្មាធិកាទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ និងគណៈកម្មាធិការ

[២៩] អង្គការយូនីសេហ្វ៖ ការវិភាគស្ថានភាពស្ត្រី និងកុមារ ទំព័រ១៩៣ និងចំណែកស្មើភាពសម្រាប់ស្ត្រី ការប៉ាន់ប្រមាណស្តីពីយេនឌ័រនៅកម្ពុជា ទំព័រ១៣៣ អង្គការទស្សនៈពិភពលោកកម្ពុជា ខណៈពេលដែលពួកគេកំពុងតែមើលរូបរាងកាយរបស់ខ្ញុំៈរូបភាពអាសអាភាស និងការអភិវឌ្ឍឥរិយាបទចំពោះផ្លូវភេទ និងសកម្មភាពផ្លូវភេទ ក្នុងចំណោមយុវជនកម្ពុជា ឆ្នាំ ២០០៦ ទំព័រ ៥១

ពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ រាជធានី ខេត្ត មានតួនាទីនិងភារកិច្ច "លើកកម្ពស់ការយល់ដឹងស្តីពីច្បាប់ និងគោលនយោបាយផ្សេងៗទាក់ទងនឹងសិទ្ធិស្ត្រីនិងកុមារ ដល់ប្រជាពលរដ្ឋ អំពីសុខភាព ការអប់រំ កិច្ចការពារ និងការអភិវឌ្ឍកុមារ រួមទាំងការចុះបញ្ជីកំណើតទារក និងកុមារ"។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជារៀបចំឱ្យមានវិធីផ្លាស់ប្តូរព័ត៌មានតាមវិធីសាស្ត្រ ២ ពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិ ។ ទី១ ជាយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈរួមគ្នា ដោយក្រសួងទេសចរណ៍ ឆ្នាំ២០០៥-២០០៩ តាមរយៈគណៈកម្មាធិការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ប្រើប្រាស់ទូរទស្សន៍ វិទ្យុ និងផ្ទាំងផ្សព្វផ្សាយ ដើម្បីចូលរួមកាត់បន្ថយការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្មលើកុមារនៅក្នុងវិស័យទេសចរណ៍ រួមទាំងការបណ្តុះបណ្តាលពហុវិស័យរបស់ក្រសួង និងបុគ្គលិកវិស័យទេសចរណ៍ (សូមពិនិត្យអនុសាសន៍ទី៥) និងមានបញ្ចូលការចែកចាយច្បាប់ចម្លងនៃផែនការយុទ្ធសាស្ត្រជាភាសាខ្មែរ និងភាសាអង់គ្លេសចំនួន២២០០ច្បាប់ និងគោលការណ៍ណែនាំសម្រាប់អនុវត្ត ។ សៀវភៅបណ្តុះបណ្តាលចំនួន២២០០ច្បាប់ ត្រូវបានចែកចាយទៅក្រសួងនានា វិស័យឯកជន សហជីព ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកបណ្តុះបណ្តាល បុគ្គលិកនិងអ្នករៀបចំអភិវឌ្ឍនៅតាមសហគមន៍ អ្នកសម្របសម្រួល និងគ្រូបង្រៀន ។ ស្ទីកគ័របិទ(sticker) ចំនួន២០០០០ច្បាប់ (ពាក់កណ្តាលជាភាសាខ្មែរ និងពាក់កណ្តាលជាភាសាអង់គ្លេស) អំពីទេសចរណ៍សុវត្ថិភាពកុមារដែលត្រូវបានបិទនៅតាមរថយន្តក្រុង និងស្ថានីយ៍រថភ្លើង សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងតំបន់ទេសចរណ៍ផ្សេងៗទៀត ។ ទី២ ជាយុទ្ធនាការចុះបញ្ជីកំណើតប្រកបដោយ ជោគជ័យដែលសម្របសម្រួលដោយក្រសួងមហាផ្ទៃ តាមរយៈសិក្ខាសាលា និងប្រព័ន្ធផ្សព្វផ្សាយឃុំ សង្កាត់ ។ នៅឆមាសទី១ ឆ្នាំ២០១១ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានសហការគ្នារៀបចំវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ផលប៉ះពាល់នៃទេសន្តរប្រវេសន៍ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរ ប្រជាពលរដ្ឋតាមបណ្តាភូមិ ឃុំ សមត្ថកិច្ចជាប់ព្រំដែនសរុបចំនួន **១១៩.១២៨នាក់ (ស្រី ៦៥.៣៨៣នាក់)** នៅខេត្តចំនួន១២ ។ នៅឆមាសទី១ ឆ្នាំ២០១១ អគ្គស្នងការនគរបាលជាតិបានរៀបចំកិច្ចប្រជុំស្តីពីការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋាន ចំនួន ៣៦,៣៥០នាក់ ។

**២. សូមពិពណ៌នាពីមធ្យោបាយដែលសារនិងព័ត៌មានរបស់យុទ្ធនាការត្រូវបានផ្សព្វផ្សាយ ( ប្រព័ន្ធ ផ្សព្វផ្សាយ វិទ្យុ និងទូរទស្សន៍ រោងល្ខោន សាលារៀនៗលៗ)ៗ សូមពិពណ៌នាពីការដើរតួដោយប្រព័ន្ធផ្សព្វផ្សាយ នៅក្នុងការដោះស្រាយអំពើហិង្សាលើកុមារ ៗ**

**ចម្លើយ** :

សូមមេត្តាពិនិត្យរបាយការណ៍ជាតិលើកទី២និងទី៣ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឆ្នាំ២០០០-២០១០ និងរបាយការណ៍ឆ្លើយតបនឹងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងរបាយការណ៍លើកទី២និងទី៣ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា ឆ្នាំ២០០០-២០០៧ (ភ្ជាប់ក្នុងឧបសម្ព័ន្ធ) ។

ក្រសួងនានាបានផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ កាសែត ផ្ទាំងក្រដាសផ្សព្វផ្សាយ និងផ្ទាំងប៉ាណូ

អំពីសិទ្ធិកុមារ ។ នៅឆ្នាំ២០០៩ ក្រសួងកិច្ចការនារីបានផ្សព្វផ្សាយអំពីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ និងទូរទស្សន៍ ។ ការផ្សព្វផ្សាយ ត្រូវបានផ្តល់បន្ថែមដោយការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មាន ។ ក្រសួងកិច្ចការនារីបានធ្វើការបណ្តុះបណ្តាលនៅក្នុងសាលារៀន និងគណៈនាយក លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស ស្តីពីអំពើហិង្សាក្នុងគ្រួសារ ។ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើយុទ្ធនាការអប់រំសម្រាប់សិស្សនិងសហគមន៍ស្តីពីហានិភ័យនៃការជួញដូរមនុស្ស ។ យុទ្ធនាការនេះត្រូវបានធ្វើដោយផ្ទាល់នៅក្នុងសាលា និងតាមរយៈការដាក់បញ្ចូលក្នុងកម្មវិធីសិក្សា ជាមួយនឹងឯកសារបណ្តុះបណ្តាលស្តីពីអនុសញ្ញាសិទ្ធិកុមារ និងលុបបំបាត់ការជួញដូរពលកម្ម និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

**៣. សូមផ្តល់ព័ត៌មានអំពីកម្មវិធីដែលត្រូវបានអនុវត្ត ដោយកំណត់គោលដៅទៅលើឳពុកម្តាយ និងអ្នកថែទាំផ្ទាល់ផ្សេងទៀត ដែលបានរៀបចំបង្កើតឡើង ដើម្បីលើកស្ទួយជំនាញចិញ្ចឹមថែទាំកុមារ និងការចិញ្ចឹមកុមារដោយមិនប្រើអំពើហិង្សា និងប្រសិនបើអាចមានព័ត៌មានអំពីផលប៉ះពាល់ (impact) និងលទ្ធផល(results)។ សូមផ្តល់ច្បាប់ថតចម្លងនៃការវាយតម្លៃ ប្រសិនបើបានធ្វើ។**

**ចម្លើយ** :

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពាជនរងគ្រោះ[៣០] ចែងថា "រដ្ឋធ្វើការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ជ្រួតជ្រាបអំពីបញ្ញត្តិនៃច្បាប់នេះ និងវិធីដោះស្រាយទំនាស់តាមមធ្យោបាយអហិង្សា និងសន្តិភាព" រាជរដ្ឋាភិបាលបានផ្តល់ជំនាញអំពីការចិញ្ចឹមអប់រំបីបាច់ថែរក្សាកូន ដោយមិនប្រើអំពើហិង្សា។ សមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំសង្កាត់ មានបញ្ចូលការត្រួតពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពនៅក្នុងការអប់រំកុមារតាំងពីតូច ដូចជាការអប់រំតាមសាលាមត្តេយ្យតាមសហគមន៍ និងការអប់រំអំពីការចិញ្ចឹមអប់រំបីបាច់ថែរក្សាកូន[៣១]។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញនូវបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌលឆ្នាំ២០០៦ និងបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ឆ្នាំ២០០៨ ដែលផ្តល់គោលការណ៍ណែនាំ និងកំណត់បទដ្ឋានស្តីពីការចិញ្ចឹមអប់រំបីបាច់ថែរក្សាកូនដល់អ្នកថែទាំ។

## អនុសាសន៍ទី៥: បង្កើនសមត្ថភាពរបស់អ្នកទាំងអស់ដែលធ្វើការជាមួយនឹងកុមារ

១. សូមបង្ហាញ និងពិពណ៌នាអំពីកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើ ដើម្បីបង្កើនសមត្ថភាពរបស់អ្នកវិជ្ជាជីវៈដែលធ្វើការជាមួយនឹងកុមារ ដើម្បីស៊ើបរកឱ្យឃើញ បញ្ជូន និងតាមដានបន្តនូវឫសគល់នៃអំពើហិង្សាលើកុមារ ។ សូមបង្ហាញផងដែរអំពីវិធានការ ដែលបានប្រកាន់យកដើម្បីបង្កើនសមត្ថភាព ដើម្បីធានាឱ្យមានការគាំទ្រដែលមានវេទយិតភាពកុមារ (child-sensitive support) នៅក្នុងបរិបទនៃការប្រឹក្សាយោបល់ ការប្តឹង និងយន្តការរាយការណ៍ រួមទាំងតាមរយៈការអនុម័តក្រមសីលធម៌ និងបទដ្ឋានប្រតិបត្តិ ។

[៣០] ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ មាត្រា ៣៣។

[៣១] សេចក្តីណែនាំស្តីពីការអនុវត្តមុខងាររបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំសង្កាត់ ២០០៧។

២. សូមបង្ហាញថា តើរដ្ឋាភិបាលរបស់អ្នកបានឱ្យធ្វើ ឬ ផ្តល់ការឧបត្ថម្ភដល់កម្មវិធីបណ្តុះបណ្តាលនៅក្នុងវិស័យអំពើហិង្សាលើកុមារដែរឬទេ ? ប្រសិនបើមាន សូមបង្ហាញថា តើក្រុមគោលដៅណាដែលកម្មវិធីបណ្តុះបណ្តាលនេះផ្តោតលើនិងបានទទួលវគ្គបណ្តុះបណ្តាល (សូម ពិនិត្យ មើលគ្រប់ជនទាំងអស់ដែលពាក់ព័ន្ធ) ។

**ចម្លើយ** : ទី១ និងទី២

នៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បាននឹងកំពុងបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈរួមមាន៖

- ***អ្នកមានអាជីពពេទ្យ (រួមទាំងពេទ្យកុមារ គិលានុប្បដ្ឋាយិកា ពេទ្យវិកលចរិក និងទន្តពេទ្យ)៖***

- ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងយុត្តិធម៌បានរៀបចំការបណ្តុះបណ្តាលរួមគ្នា និងដាច់ដោយឡែកពីគ្នាជូនដល់នគរបាលយុត្តិធម៌ វេជ្ជបណ្ឌិត និងមន្ត្រីតុលាការ អំពីនីតិវេជ្ជវិទ្យា និងការស៊ើបអង្កេតវេជ្ជសាស្ត្រលើករណីរឿងរំលោភបំពានផ្លូវភេទលើកុមារ ។ ការបណ្តុះបណ្តាលលើកទី១ស្តីពីនីតិវេជ្ជវិទ្យា និងការស៊ើបអង្កេតលើករណីរឿងរំលោភបំពានខាងផ្លូវភេទលើកុមារ បានប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០០៨ ។ បន្ទាប់មកមានការបណ្តុះបណ្តាលបន្តអំពី "ការធ្វើកោសល្យវិច្ច័យវេជ្ជសាស្ត្រ និងទិដ្ឋភាពផ្លូវច្បាប់នៃការស៊ើបអង្កេតរឿងរំលោភបំពានខាងផ្លូវភេទលើកុមារ" ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ២០១០។

- ក្រសួងសុខាភិបាល បានដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពីទទួលខុសត្រូវខាងវេជ្ជសាស្ត្រចំពោះអំពើហិង្សាលើកុមារទៅក្នុងកម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ។

- ***អ្នកធ្វើការខាងវិស័យសុខភាពសាធារណៈ***

- ***មន្ត្រីសង្គមកិច្ច និងអ្នកចិត្តសាស្ត្រ :*** ដេប៉ាតឺម៉ង់សង្គមកិច្ចត្រូវបានបង្កើតឡើងនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយដែលកំពុងតែខិតខំទាក់ទាញការគាំទ្រឱ្យបានក្លាយទៅជាសមាជិករបស់សមាគមសង្គមកិច្ចអន្តរជាតិ។ នៅក្នុងឆ្នាំ២០០៩ មន្ត្រីសង្គមកិច្ចថ្នាក់ជាតិចំនួន៥៤% និងថ្នាក់ក្រោមជាតិចំនួន៨៣% បានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីសេវាសង្គមកិច្ចមូលដ្ឋាន និងវគ្គសេវាសង្គមកិច្ចវិជ្ជាជីវៈ។ មេរៀនស្តីពីតួនាទីរបស់មន្ត្រីសង្គមកិច្ចនៅក្នុងប្រព័ន្ធយុត្តិធម៌កុមារ ត្រូវបានគេដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលសេវាសង្គមកិច្ចវិជ្ជាជីវៈរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

នៅឆ្នាំ២០១១នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច ដើម្បីធ្វើការបណ្តុះបណ្តាល និងស្រាវជ្រាវផ្នែកសង្គមកិច្ច ។ វិទ្យាស្ថានជាតិនេះស្ថិតក្រោមអាណាព្យាបាលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ក្រសួងយុត្តិធម៌បានបើកវគ្គបណ្តុះបណ្តាលពហុវិស័យ ស្តីពីយុត្តិធម៌កុមារជូនដល់គ្រូបង្គោលចំនួន៣៥នាក់ ដែលរួមមានមន្ត្រីតុលាការ អ្នកសង្គមកិច្ច និងបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល[៣២]។

- ***គ្រូបង្រៀន និងអ្នកអប់រំផ្សេងៗទៀត និងបុគ្គលិករបស់សាលារៀន :*** ចាប់ពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០០៩ ក្រសួងកិច្ចការនារី និងក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបណ្តុះបណ្តាលស្តីពីអំពើហិង្សាក្នុងគ្រួសារដល់នាយកសាលា និងគ្រូបង្រៀន នៅក្នុងរាជធានីភ្នំពេញ និងទីប្រជុំជនខេត្តចំនួន០៣ មានសិក្ខាកាមចំនួន១២៩នាក់ និងមានសិស្សសរុប ចំនួន ២២ ៣៥៥នាក់ ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ក៏បានជួយឧបត្ថម្ភណែនាំដល់ការិយាល័យអប់រំតាមស្រុក និងសាលារៀនផងដែរ ។

[៣២] កជក, របាយការណ៍ស្តីពីការអនុវត្តន៍សេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ចខិតខំប្រឹង ប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

- ***មន្ត្រីតុលាការ (រួមទាំងចៅក្រម) :*** ឆ្នាំ២០០៦ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងមជ្ឈមណ្ឌលបណ្តុះបណ្តាល និងសុក្រឹតការវិជ្ជាជីវៈមេធាវី បានធ្វើការបណ្តុះបណ្តាលដល់និស្សិត ចៅក្រម និងព្រះរាជអាជ្ញាក្នុងតំណែងស្តីពីសិទ្ធិកុមារ ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានផលិតខ្សែវីដេអូសម្រាប់ការបណ្តុះបណ្តាលមន្ត្រីតុលាការបានចំនួន០២រឿង ស្តីពីរបៀបសម្ភាសន៍កុមាររងគ្រោះ និងកុមារប្រព្រឹត្តល្មើសនឹងច្បាប់ ។

- ***មន្ត្រីអនុវត្តច្បាប់ រួមទាំងនគរបាល :***
  - នៅឆ្នាំ២០០៩ មន្ត្រីនគរបាលយុត្តិធម៌មកពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមកពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្នុងរាជធានីខេត្ត ចំនួន១០ បានទទួលការបណ្តុះបណ្តាលដោយធ្វើការផងរៀនផង អំពីការគ្រប់គ្រងករណី និងការតាមដានបន្តនៅក្នុងការស៊ើបអង្កេត ការបញ្ជូនករណីជួញដូរ រំលោភបំពានខាងផ្លូវភេទ ការកេងប្រវ័ញ្ច និងអំពើហិង្សាក្នុងគ្រួសារ។
  - សៀវភៅបណ្តុះបណ្តាលសម្រាប់មន្ត្រីនគរបាល ត្រូវបានធ្វើបច្ចុប្បន្នកម្មដោយដាក់បញ្ចូលបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបញ្ញត្តិនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។
  - សិក្ខាសាលាចំនួន ២ ត្រូវបានគេរៀបចំឡើងនៅថ្នាក់ជាតិ ដោយមានការចូលរួមពីតំណាងរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងតំណាងមកពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនទាំង២៤រាជធានី ខេត្ត។
  - អធិការ និងអធិការរង ប្រធាន និងអនុប្រធានប៉ុស្តនគរបាលរដ្ឋបាល ចំនួនសរុប៩៥០នាក់ មកពីរាជធានីខេត្តចំនួន១០ បានទទួលការបណ្តុះបណ្តាលស៊ីជម្រៅអំពីនីតិវិធីខាងផ្លូវច្បាប់ និងជំនាញក្នុងការស៊ើបអង្កេត ព្រមទាំងអំពីកិច្ចសហការជាមួយនឹងអាជ្ញាធរមូលដ្ឋានផ្សេងៗទៀត។
  - មានមន្ត្រីនគរបាលយុត្តិធម៌ជាង១ ៧០០នាក់ ដែលបានទទួលការបណ្តុះបណ្តាលនៅឯរាជបណ្ឌិតសភានគរបាល និងនៅតាមសាលាបណ្តុះបណ្តាលភូមិភាគទាំង៥ ដើម្បីធ្វើឱ្យមានវេទយិតភាពជាមួយនឹងរឿងរំលោភបំពានផ្លូវភេទលើកុមារ ការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ ហើយនឹងឱ្យចេះនីតិវិធីដោះស្រាយរឿងក្តីប្រភេទនេះផងដែរ ។ (សូមពិនិត្យមើលរបាយការណ៍ជាតិលើកទី២ និងទី៣ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឆ្នាំ២០០០-២០១០)។
  - នៅឆ្នាំ២០១០-២០១១ កម្មវិធីពង្រឹងការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ៖ បានរៀបចំការបណ្តុះបណ្តាលចំនួន១៩លើក ជូននគរបាលមកពីថ្នាក់រាជធានី ខេត្តចំនួន៥២៨នាក់ អំពីការអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងបានផ្តល់ការបណ្តុះបណ្តាលដោយឱ្យធ្វើការផង និងរៀនផងអំពីបច្ចេកទេសធ្វើសម្ភាសន៍ និងការអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ។
  - នៅឆ្នាំ២០១១ មន្ត្រីនគរបាលរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន០៨នាក់ បានទៅចូលរួមនៅក្នុងការបណ្តុះបណ្តាលថ្នាក់តំបន់របស់អាស៊ាន ស្តីពីការបង្ការបទល្មើសឆ្លងដែន ការជួញដូរដើម្បីធ្វើពលកម្មដោយបង្ខំ និងការកេងប្រវ័ញ្ចផ្លូវភេទ ទេសចរផ្លូវភេទលើកុមារ ការស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះ។

- នៅក្នុងឆ្នាំ២០១១ កម្មវិធី LEAP ក៏បានបណ្តុះបណ្តាលមន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនមកពីរាជធានីខេត្តចំនួន៩ មានចំនួនទាំងអស់១៦៥នាក់ (នារី២១នាក់) អំពីការគ្រប់គ្រងករណី ការតាមដានបន្ត ការស៊ើបអង្កេត ករណីហិង្សា ការជួញដូរ ការរំលោភបំពាន និងកេងប្រវ័ញ្ចខាងផ្លូវភេទ។ LEAP ដឹកនាំការបណ្តុះបណ្តាលរំលឹកឡើងវិញ (វិក្រឹតការ) ជូនមន្ត្រីនគរបាលមកពីរាជធានី ខេត្តចំនួន៩ ឱ្យចេះឆ្លើយតបទៅនឹងការហៅចូលទូរស័ព្ទទាន់ហេតុការណ៍ និងបានបណ្តុះបណ្តាលតាមសាលានគរបាលថ្នាក់តំបន់ជូនមន្ត្រីនគរបាលចំនួន៧០៨នាក់ ក្នុងនោះមាននារី ៣៧នាក់ ព្រមទាំងបានរៀបចំគម្រោងកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល និងបានបណ្តុះបណ្តាលមន្ត្រីនគរបាល នៅក្នុងរាជធានី ខេត្តចំនួន៩។
- សៀវភៅបណ្តុះបណ្តាលនគរបាលអំពីយុត្តិធម៌អនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ កំពុងត្រូវបានរៀបចំឡើង ដែលមានគ្របដណ្តប់លម្អិតគ្រប់ដំណាក់កាលនៃដំណើរការ ចាប់តាំងពីការរាយការណ៍អំពីបទល្មើស ឆ្លងកាត់ការស៊ើបអង្កេត រហូតមកដល់ការឃាត់ខ្លួន ការបង្វែរ និងការកាត់ទោស។

- *មន្ត្រីពន្ធនាគារ និងបុគ្គលិកធ្វើការផ្នែកជនល្មើសជាអនីតិជន*

- នៅឆ្នាំ២០០៩ មន្ត្រីសង្គមកិច្ច មន្ត្រីពន្ធនាគារ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមកពីរាជធានីខេត្តចំនួន ៩ បានទទួលការបណ្តុះបណ្តាលរំលឹកឡើងវិញអំពីការគ្រប់គ្រងករណី និងសមាហរណកម្មកុមារប្រព្រឹត្តល្មើសនឹងច្បាប់។
- នៅឆ្នាំ២០១១ គម្រោងជំនួយផ្នែកយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជា (Cambodian Criminal Justice Assistance project) ដំណាក់កាលទី៣បានរៀបចំការបណ្តុះបណ្តាលអំពីការគ្រប់គ្រងពន្ធនាគារ និងទណ្ឌិត ដែលរួមមានចំណាត់ថ្នាក់សន្តិសុខទណ្ឌិត ការប្រើកម្លាំងដោយអ្នកយាម បញ្ហាសម្ភារៈថែទាំសុខភាពទណ្ឌិត និងគាំទ្រដល់អគ្គនាយកដ្ឋានពន្ធនាគារក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីពន្ធនាគារ ។
- មានមន្ត្រីពន្ធនាគារចំនួន១៦០នាក់ នៅក្នុងរាជធានីខេត្តចំនួន៨ បានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រងទណ្ឌិត ការគ្រប់គ្រងករណី និងការតាមដានករណី ។

- *បុគ្គលិកធ្វើការផ្នែកថែទាំតាមមណ្ឌលស្នាក់នៅ*

- នៅឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើការបណ្តុះបណ្តាលនាយកមណ្ឌលស្នាក់នៅរបស់រដ្ឋចំនួន២១ អំពីការផ្តួចផ្តើមគំនិតរៀបចំសេចក្តីព្រាងក្រមសីលធម៌ ។
- នៅឆ្នាំ២០១១ គ្រូបង្រៀន មន្ត្រីឃុំ នគរបាលឃុំ និងប្រធានភូមិ នៅក្នុងឃុំចំនួន០៥ នៅក្នុងរាជធានីខេត្តចំនួន០៣ មានចំនួនសរុបទាំងអស់លើសពី១១០នាក់ បានទទួលការបណ្តុះបណ្តាលអំពីការឆ្លើយតបចម្រុះទីភ្នាក់ងារចំពោះការការពារកុមារ ដើម្បីធ្វើជាគំរូសម្រាប់ការបណ្តុះបណ្តាលតាមការ ជាក់ស្តែង និងការបណ្តុះបណ្តាលទ្វេភាគី ដែលអង្គការមិនមែនរដ្ឋាភិបាលផ្តល់ជូននៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ឃុំ សង្កាត់ ។

- *មន្ត្រីអន្តោប្រវេសន៍*

- *គ្រួសារ និងអ្នកថែទាំ*

- *បុគ្គលិកត្រួតពិនិត្យព្រំដែន និងបុគ្គលិកផ្នែកអន្តោប្រវេសន៍ និងមន្ត្រី/បុគ្គលិកផ្សេងទៀត (សូមបញ្ជាក់)*

ក្រសួងទេសចរណ៍បានធ្វើយុទ្ធនាការមួយស្របទៅតាមផែនការយុទ្ធសាស្ត្រលើកកម្ពស់ទេសចរណ៍សុវត្ថិភាពកុមារ (Child-Safe Tourism) ដើម្បីបង្ការទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ ការកេងប្រវ័ញ្ចពលកម្ម និងការកេងប្រវ័ញ្ចខាងផ្លូវភេទ នៅក្នុងឧស្សាហកម្មទេសចរណ៍នៅកម្ពុជា ឆ្នាំ២០០៧-២០០៩ ដែលរួមមានទាំងកម្មវិធីបណ្តុះបណ្តាលផងដែរ ជូនដល់:

- មន្ត្រីរាជការនៅថ្នាក់ជាតិនិងរាជធានី ខេត្តចំនួន២៦៨នាក់ មកពីក្រសួងចំនួន០៤ គឺក្រសួងទេសចរណ៍ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។
- អ្នកគ្រប់គ្រងនិងបុគ្គលិករបស់សមាគមនិយោជក សហជីព និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០០នាក់។
- អ្នកបម្រើការវ័យក្មេងតាមសណ្ឋាគារ ផ្ទះសំណាក់ និងភោជនីយដ្ឋាន ចំនួនទាំងអស់៤ ៥០០នាក់ ដើម្បីឱ្យមានការយល់ដឹងស្តីពីការជួញដូរមនុស្ស របៀបកែលំអស្ថានភាពធ្វើការងារ និងថាតើត្រូវទៅរកជំនួយនៅទីណា។
- សាស្ត្រាចារ្យនិងនិស្សិតសាកលវិទ្យាល័យចំនួន១,៧០០នាក់ អំពីការយល់ដឹងស្តីពីការជួញដូរមនុស្ស និងរបៀបកែលម្អលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ។
- មនុស្សចំនួន៦ម៉ឺននាក់ ក្នុងនោះមានទាំងទេសចរ (ក្នុងស្រុកនិងអន្តរជាតិ) ភ្នាក់ងាររដ្ឋាភិបាល និយោជក កម្មករ សង្គមស៊ីវិល និងសហគមន៍ទេសចរ បានទទួលព័ត៌មានយល់ដឹងជាទូទៅ ។
- កម្មករបម្រើការតាមផ្ទះសំណាក់ ភោជនីយដ្ឋាន និងពលករទេសន្តរប្រវេសគ្មានការងារធ្វើចំនួន ៨០០នាក់ បានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងផ្ទះសំណាក់និងភោជនីយដ្ឋាន ហើយនិងព័ត៌មានយល់ដឹងអំពីការជួញដូរមនុស្ស។

## អនុសាសន៍ទី៦ : ផ្តល់សេវាផ្នែកស្តារ និងសេវាសមាហរណកម្មសង្គម

១. សូមពិពណ៌នាពីគំនិតផ្តួចផ្តើម ឬកម្មវិធី និងសេវានានាក្នុងការផ្តល់ការគាំទ្រដល់កុមាររងគ្រោះពីអំពើហិង្សា ថាតើកម្មវិធី និងសេវាទាំងនេះត្រូវបានផ្តល់ដោយសេវារបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នឯករាជ្យជាតិដែរឬទេ? និងថាតើសេវាទាំងនេះអាចរកបាននៅទូទាំងប្រទេស ឬនៅតែក្នុងទីក្រុងឬក្នុងតំបន់ជាក់លាក់មួយចំនួនតែប៉ុណ្ណោះ។ ប្រសិនបើមានសូមផ្តល់របាយការណ៍ពាក់ព័ន្ធ និងអាស័យដ្ឋានឆ្លាប់ទំនាក់ទំនងតាមប្រព័ន្ធអ៊ិនធឺណេតនៃកម្មវិធី និងសេវាទាំងនេះ។

**ចម្លើយ**:

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបោះពុម្ពផ្សាយគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅឆ្នាំ២០០៩ និងបានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរ និងសមាហរណកម្ម។ អ្នកដែលផ្តល់ការគាំទ្រសំខាន់ផ្នែករដ្ឋាភិបាល គឺមន្ត្រីសង្គមកិច្ចរបស់ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ក៏ប៉ុន្តែសេវាស្តារនីតិសម្បទាភាគច្រើនត្រូវបានផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល ។ នៅឆ្នាំ២០១០ ក្រសួងសង្គមកិច្ច

អតីតយុទ្ធជន និងយុវនីតិសម្បទា បានបោះពុម្ពផ្សាយជាភាសាខ្មែរ និងចែកជូនដោយមិនយកកម្រៃនូវសៀវភៅអាសយដ្ឋានសេវាកម្មសម្រាប់អ្នកដែលងាយរងគ្រោះ ដែលមានរៀបរាប់អំពីសេវាដែលគេអាចរកបាននៅតាមខេត្តនីមួយៗ ព្រមទាំងមានលម្អិតលេខទំនាក់ទំនងរបស់អ្នកផ្តល់សេវាទាំងផ្នែករដ្ឋាភិបាល និងផ្នែកអង្គការមិនមែនរដ្ឋាភិបាល ដូចជាប្រធានភូមិនិងមេឃុំ បុគ្គលិកសុខាភិបាល មន្រ្តីសង្គមកិច្ច នគរបាល សាលារៀន ការិយាល័យរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ អង្គការមិនមែនរដ្ឋាភិបាល និងជួយធ្វើឱ្យមានការយល់ដឹងដូចគ្នាអំពីបណ្តាញ និងងាយស្វែងរកសេវា ។ អ្នកដែលផ្តល់សេវាជូនជនរងគ្រោះដោយសារអំពើហិង្សាសំខាន់ៗ បានចងក្រងរបាយការណ៍ប្រចាំឆ្នាំ ដែលមានទិន្នន័យអំពីអ្នកប្រើប្រាស់សេវាផងដែរ ។ ទិន្នន័យនេះ មានដាក់បញ្ចូលនៅក្នុងស្ថិតិរួមគ្នារបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមានភ្ជាប់ជាឧបសម្ព័ន្ធ ។

**២. សូមបង្ហាញថា តើសេវាទាំងនេះមានគ្របដណ្តប់លើទីកន្លែង និងទម្រង់នៃអំពើហិង្សាដែលត្រូវបានរាយក្នុងប្រអប់ដូចខាងក្រោមនេះដែរឬទេ ?**
*ប្រភេទនៃអំពើហិង្សា ៖ ផ្លូវកាយ ផ្លូវភេទផ្លូវចិត្ត ការមិនយកចិត្តទុកដាក់ HTP[៣៣] និងផ្សេងៗទៀត។*

**ចម្លើយ**:

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ថាការចាំបាច់ត្រូវតែស្តារនីតិសម្បទាកុមារបន្ទាប់មកធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍វិញ ដែលការផ្តល់សេវាស្តារនីតិសម្បទាដល់ទណ្ឌិត[៣៤] ជនរងគ្រោះដោយសារការជួញដូរ[៣៥] និងកុមារដែលត្រូវការការថែទាំជំនួស[៣៦] ជាការចាំបាច់ត្រូវអនុវត្តឱ្យបានល្អ។

សេវាស្តារនីតិសម្បទា និងផ្តល់ការគាំទ្រមិនមានធ្វើការបែងចែកអំពីប្រភព ប្រភេទនៃអំពើហិង្សា ឬស្លាកស្នាមរងគ្រោះទេ ។ បច្ចុប្បន្ននៅមិនទាន់មានទិន្នន័យគ្រប់គ្រាន់អំពីតម្រូវការរបស់អ្នកដែលត្រូវការសេវានៅឡើយ ហេតុនេះគេបានចាត់ថ្នាក់សេវាទៅតាមការយល់ឃើញរបស់អ្នកផ្តល់ ដូចជាការថែទាំខាងផ្នែកវេជ្ជសាស្ត្រ និងការស្តារចលនាខាងរាងកាយ ការផ្តល់ការប្រឹក្សានិងគាំទ្រខាងផ្លូវចិត្ត និងសមាហរណកម្ម ទៅក្នុងគ្រួសារ និងសហគមន៍វិញ ជាដើម។

*គ្រួសារ/ផ្ទះ*

**ចម្លើយ** :

មន្ត្រីសង្គមកិច្ច បានចុះធ្វើការតាមដានបន្តដល់អ្នកដែលត្រូវបានធ្វើសមាហរណកម្មទៅកាន់គ្រួសារបង្កើត ឬគ្រួសារចិញ្ចឹម ឬបងប្អូន ឬមណ្ឌលសាសនាដូចជាវត្តអារាម ស្របទៅតាមបញ្ញត្តិនៃបទដ្ឋានអប្បបរមានៃការថែទាំជំនួសឆ្នាំ២០០៨។

*សាលារៀន*

**ចម្លើយ** :

ក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយស្តីពីការអប់រំក្រៅប្រព័ន្ធនិងគោលនយោបាយ

---

[៣៣] ការអនុវត្តតាមប្រពៃណីដែលធ្វើឲ្យមានការខូចខាត(អន្តរាយ)

[៣៤] ច្បាប់ស្តីពីពន្ធនាគារ មាត្រា៧៤។

[៣៥] សារាចរណែនាំស្តីពីការអនុវត្តនិងកិច្ចសហការរវាងស្ថាប័នរដ្ឋាភិបាលដែលមានការពាក់ព័ន្ធជាមួយនឹងទីភ្នាក់ងារដែលផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារការជួញដូរ ឆ្នាំ២០០៧។

[៣៦] ក្រសួង សអយ ចង់ពង្រីកបទដ្ឋានរួមគ្នានេះទៅទូទាំងប្រទេស និងចំពោះគ្រប់អ្នកផ្តល់សេវាទាំងអស់ តាមរយៈការចេញបទដ្ឋានអប្បបរមានៃការថែទាំជំនួសដែលតម្រូវឲ្យអ្នកកផ្តល់ការថែទាំជំនួសទាំងអស់ ត្រូវតែគិតដល់ការធ្វើសមាហរណកម្មកុមារទៅក្នុងសហគមន៍វិញនៅចុងបញ្ចប់។

ស្តីពីការចូលរៀនឡើងវិញ ដែលត្រូវបានរៀបចំជួយសិស្សានុសិស្សក្នុងការចូលរៀនវិញ។

*ស្ថាប័ន*

**ចម្លើយ** :

បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានកំណត់រកឃើញមានការថែទាំនៅតាមសហគមន៍ ៣ ប្រភេទ គឺ ការថែទាំក្នុងគ្រួសារដែលរួមមានទាំងសាច់ញាតិផងដែរ ការថែទាំក្នុងគ្រួសារដែលមានកុមារជាមេគ្រួសារ និងគ្រួសារចិញ្ចឹម និងវត្តអារាមសាសនា និងការថែទាំក្នុង "គ្រួសាររួម" ដែលត្រូវបានគេឱ្យនិយមន័យថាគឺជា "ការថែទាំចំពោះកុមារមួយចំនួនតូច នៅក្នុងបរិស្ថានគ្រួសារមួយក្រោមការត្រួតពិនិត្យពីពួកអ្នកថែទាំមួយចំនួនដែលមិនមែនជាសាច់ញាតិរបស់កុមារ" ។ មន្ត្រីសង្គមកិច្ចមានកាតព្វកិច្ចត្រូវអនុវត្តតាម និងត្រូវជួបកុមារយ៉ាងហោចណាស់ម្តងជារៀងរាល់ត្រីមាស នៅក្នុងពេល២ឆ្នាំដំបូង ហើយចំពោះអ្នកថែទាំគ្រប់ប្រភេទទាំងអស់មានកាតព្វកិច្ចជារៀងរាល់ឆ្នាំ ត្រូវពិចារណាពីការទុកដាក់កុមារចូលទៅក្នុងគ្រួសារបង្កើតឡើងវិញ ឬគ្រួសារសុំកូនណាមួយ ។ កុមារដែលបានឆ្លងកាត់ការប៉ះទង្គិចខាងផ្លូវចិត្តខ្លាំង មានសិទ្ធិជួបជាមួយអ្នកផ្តល់ការប្រឹក្សាយោបល់ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានសិទ្ធិទទួលបាននូវការអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការថែទាំសុខភាព និងឱកាសនៅក្នុងការអភិវឌ្ឍខាងផ្នែកសង្គម ។ ប្រការ ៣ នៃបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍ កំណត់ឱ្យគ្រប់មណ្ឌល ផ្តល់ការស្នាក់នៅទាំងអស់ទៅចុះបញ្ជីជាមួយនឹងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រការ១១ និង ១២ កំណត់ថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងចុះទៅធ្វើការប៉ាន់ប្រមាណនិងអធិការកិច្ចមណ្ឌលនីមួយៗជារៀងរាល់ឆ្នាំ ។ បទដ្ឋានអប្បបរមា ក៏ត្រូវអនុវត្តចំពោះមណ្ឌលស្តារយុវនីតិសម្បទា និងមណ្ឌលសំចតប៉ោយប៉ែតផងដែរ ។ ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានធ្វើទំនាក់ទំនងជាមួយនឹងពន្ធនាគារ នៅក្នុងរាជធានី ខេត្តចំនួន ០៤ គឺ ភ្នំពេញ បាត់ដំបង កណ្តាល និងសៀមរាប ដើម្បីផ្តល់ការគាំទ្រដល់កុមារប្រព្រឹត្តល្មើសនឹងច្បាប់ ជាពិសេសនៅក្នុងការគ្រប់គ្រងករណីនិងសមាហរណកម្ម ។ មន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅក្នុងខេត្តចំនួន ០៥ បានទទួលការផ្គត់ផ្គង់ធនធានបន្ថែម សម្រាប់ការត្រៀមអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលកំពុងតែស្ថិតនៅជាសេចក្តីព្រាងនៅឡើយ ដែលបានផ្តល់សមត្ថកិច្ចជាច្រើនដល់មន្ត្រីសង្គមកិច្ច ។

ក្រសួងមហាផ្ទៃ បានចេញសេចក្តីណែនាំដល់មណ្ឌលកែប្រែទាំងអស់ឱ្យបំបែកអនីតិជនចេញពីមនុស្សចាស់ និងបានធ្វើការណែនាំនៅក្នុងឆ្នាំ២០១១នេះ ឱ្យមានការផ្តល់នូវការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការអប់រំផងដែរដល់អនីតិជននៅក្នុងកន្លែងឃុំឃាំង ពីថ្នាក់ទី១រហូតដល់ថ្នាក់ទី១១ តាមរយៈការគាំទ្រគ្រូស្ម័គ្រចិត្តមកពីក្រសួងអប់រំ យុវជន និងកីឡា ។ ជាមួយនេះដែរ ក៏មានកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសដូចជា កុំព្យូទ័រ ជួសជុលម៉ូតូ ភាសាអង់គ្លេសជាដើម ដោយមានកិច្ចសហការ និងឧបត្ថម្ភពីស្ថាប័នជាតិ អង្គការដៃគូជាតិ និងអន្តរជាតិ។

*អ្នកជិតខាង/សហគមន៍*

**ចម្លើយ** :

ការរំលោភសេពសន្ថវៈលើកុមារ ភាគច្រើនត្រូវបានប្រព្រឹត្តឡើងដោយមនុស្សនៅក្នុងសហគមន៍ បាន

នឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ។ ជនរងគ្រោះដោយការរំលោភសេពសន្ថវៈ ងាយនឹងក្លាយទៅជារងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទណាស់ ដែលបណ្តាលមកពីស្លាកស្នាមទុរយសសង្គម ដោយមិនបានដាក់ទោសជនល្មើស ដែលជាហេតុនាំឱ្យកាត់បន្ថយជម្រើសស្វែងរកការងារធ្វើរបស់នារី ។ ករណីបែបនេះ សមាជិកក្រុមប្រឹក្សាឃុំមានភារកិច្ច ជួយសម្របសម្រួលការគាំទ្ររបស់សហគមន៍ និងរៀបចំការទៅរកមណ្ឌលស្នាក់នៅដែលមានសេវាថែទាំគ្រប់មុខ។

*កន្លែងធ្វើការ*

**ចម្លើយ** :

គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយសារការជួញដូរមនុស្ស ឆ្នាំ២០០៩របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំបញ្ជីសេវាមួយចំនួន ដែលអ្នករងគ្រោះត្រូវទទួលបាន។ មិនមានសេវាផ្តល់ជូនទេនៅតាមទីកន្លែងធ្វើការងារ ក៏ប៉ុន្តែក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសង្គ្រោះចេញពីទីកន្លែងធ្វើការងារដែលប្រកបទៅដោយគ្រោះថ្នាក់យ៉ាងខ្លាំង ទៅសេវាស្តានីតិសម្បទា និងផ្តល់សំណងហិរញ្ញវត្ថុ និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬបញ្ជូនទៅចូលរៀនវិញ ។ នៅឆ្នាំ២០១០ ដល់២០១១ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយអង្គការ ILO/IPEC បានសង្គ្រោះកុមារចំនួន២៧១៩នាក់ ក្នុងនោះមានកុមារី១៣៩៨នាក់ និងនៅក្នុងឆមាសទី១ ឆ្នាំ២០១១ បានសង្គ្រោះកុមារចំនួន៧៩៦៤នាក់ រួមមានកុមារី ៤៨០២នាក់ តាមរយៈការធ្វើអធិការកិច្ចដោយក្រុមអធិការកិច្ចរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

*ការអនុវត្តច្បាប់*

**ចម្លើយ** :

នៅមិនទាន់មានសេវាស្តារនីតិសម្បទានៅតាមប៉ុស្តិ៍នគរបាលនៅឡើយទេ។ ទោះបីច្បាប់ស្តីពីពន្ធនាគារបានចែងឱ្យមានសេវាស្តារនីតិសម្បទានៅតាមពន្ធនាគារក៏ដោយ ប៉ុន្តែបច្ចុប្បន្នរាជរដ្ឋាភិបាលមិនទាន់មានលទ្ធភាពគ្រប់គ្រាន់នៅឡើយសម្រាប់រៀបចំឱ្យមានសេវានេះ ។ មិនមានទិន្នន័យស្តីពីយន្តការប្តឹងតវ៉ាចំពោះអំពើហិង្សាប្រព្រឹត្តដោយអ្នកអនុវត្តច្បាប់ទេ ។

**៣. សូមបង្ហាញថា តើមានទិន្នន័យជាតារយនៃកុមារដែលប្រើប្រាស់សេវាទាំងនេះដែរឬទេ ប្រសិនបើអាច សូមបំបែកតាមភេទ។**

**ចម្លើយ** :

មិនមានការប្រមូលផ្តុំទិន្នន័យនៅថ្នាក់កណ្តាលទេ ហើយក៏មិនមានតួលេខបែងចែកទៅតាមភេទ អាយុ ឬសេវាដែលបានប្រើផងដែរ ។

ចំពោះការធ្វើមាតុភូមិនិវត្តន៍និងសមាហរណកម្មវិញ មណ្ឌលសំចតមួយត្រូវបានបង្កើតឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅក្នុងឆ្នាំ២០០៧ នៅប៉ោយប៉ែត ដែលជាកន្លែងឆ្លងកាត់សំខាន់មួយរវាងកម្ពុជានិងប្រទេសថៃ ។ មានក្រុមការពារកុមារចម្រុះវិស័យតាមព្រំដែនមួយ ដែលធ្វើការនៅត្រង់ច្រកអន្តរជាតិប៉ោយប៉ែតរង់ចាំស្កាត់រកមើលកុមារដែលមិនមានមនុស្សចាស់ធ្វើដំណើរជាមួយ ដើម្បីទៅរកជំនួយពីមណ្ឌល ។ ក្រុមការងារនេះមានមន្ត្រីមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

នគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត ការិយាល័យសម្របសម្រួលការងារព្រំដែន និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ។

នៅក្នុងឆ្នាំ២០១០ មានមនុស្សទាំងអស់ចំនួន ១ ៥៥៩នាក់ បានទទួលសង្គ្រោះនិងស្តារនីតិសម្បទា ក្នុងនោះមានជនរងគ្រោះដោយអំពើជួញដូរមនុស្ស រួមមានស្ត្រីនិងកុមារ បានធ្វើមាតុភូមិនិវត្តន៍មកវិញ គឺ២៥៦នាក់ មកពីប្រទេសថៃ ៥៥៩នាក់ មកពីវៀតណាម ០៩នាក់ មកពីម៉ាឡេស៊ី ០៥នាក់ មកពីទីម័រ ០៩នាក់ មកពីឥណ្ឌា ០១នាក់ មកពីអាហ្វ្រិកខាងត្បូង ០៥នាក់ មកពីឥណ្ឌូនេស៊ី និង៧៣០នាក់ នៅក្នុងប្រទេស។

៩០%នៃកុមារជាប់ឃុំឃាំងក្នុងពន្ធនាគារ(៧០៥នាក់) បានទទួលសេវាស្តារនីតិសម្បទា ដែលរួមមាន ការគ្រប់គ្រង ការពិគ្រោះយោបល់ ការអប់រំក្រៅប្រព័ន្ធ ការបណ្តុះបណ្តាលជំនាញ ការតាមដានបន្ត និង សេវាថែទាំក្រោយចេញពីពន្ធនាគារ។

នៅឆ្នាំ២០១០ ក្នុងចំណោមជនរងគ្រោះដែលត្រូវបានរំដោះចេញពីការជួញដូរផ្លូវភេទទាំងអស់ចំនួន ១ ៧៦៨នាក់ មាន៣៥១នាក់ ត្រូវបានបញ្ជូនទៅក្រសួងនិងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១៣នាក់ បញ្ជូនទៅអង្គការមិនមែនរដ្ឋាភិបាល និង៤០៨នាក់ទៀត បញ្ជូនទៅឱ្យស្តារនីតិសម្បទា ជាមួយក្រុមគ្រួសារ[៣៧] ។

## អនុសាសន៍ទី៧ : ឆានាការចូលរួមរបស់កុមារ

**១. សូមផ្តល់ព័ត៌មានអំពីការចូលរួមពាក់ព័ន្ធ និងការពិគ្រោះយោបល់ជាមួយកុមារ នៅក្នុងការតស៊ូមតិ និងការតាក់តែងនិងការអនុវត្តច្បាប់ ព្រមទាំងសកម្មភាព កម្មវិធី និងគោលនយោបាយនានា ដើម្បីបង្ការទប់ស្កាត់ និងដោះស្រាយអំពើហិង្សាលើកុមារ ។ តើការពិគ្រោះយោបល់ជាមួយកុមារជាកាតព្វកិច្ចដែរឬទេ នៅក្នុងករណីទាំងនេះ ? សូមផ្តល់ព័ត៌មានលម្អិត រួមទាំងក្រុមអាយុ និងព័ត៌មានលម្អិតផ្សេងៗទៀតរបស់កុមារដែលបានចូលរួម ពាក់ព័ន្ធនឹងបរិបទដែលនៅក្នុងនោះសកម្មភាពទាំងនេះត្រូវបានលើកស្ទួយ (ឧ. សាលារៀន សហគមន៍ ថ្នាក់តំបន់ ឬថ្នាក់ជាតិ) ។**

**ចម្លើយ**:

ទោះបីផ្នត់គំនិតកុមារត្រូវគោរពមនុស្សចាស់ជាជាងសម្តែងមតិ ឬលើកអំពីសេចក្តីត្រូវការណាមួយ បាននិងកំពុងមានឥទ្ធិពលនៅក្នុងសង្គមកម្ពុជាក៏ពិតមែន ប៉ុន្តែនៅក្នុងគ្រប់វេទិកានានា រាជរដ្ឋាភិបាលបាន សហការជាមួយដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល យកចិត្តទុកដាក់ពង្រីកសិទ្ធិចូលរួមរបស់កុមារ។ ជាក់ស្តែងតំណាងកុមារបានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ជាតិ ថ្នាក់តំបន់ ថ្នាក់អន្តរជាតិ ថ្នាក់ក្រោមជាតិជាច្រើន។ បច្ចុប្បន្នក្រុមកុមារ និងយុវជននៅតាមរាជធានីខេត្តទូទាំងប្រទេសមានចំនួន៧១៧ក្រុម ដឹកនាំដោយកុមារ និងយុវជន និងមានក្រុមប្រឹក្សាកុមារ ចលនាយុវជនកាកបាទក្រហមកម្ពុជា និងចលនាក្រុមកាយរិទ្ធ នៅតាមសាលារៀន។ គ្រប់មតិយោបល់និងសំណូមពររបស់កុមារ ត្រូវបានយកមកពិចារណា និងដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនានា ។ គោលនយោបាយសាធារណៈផ្សេងៗសុទ្ធតែបានយកចិត្តទុកដាក់គិតគូរដល់មតិរបស់កុមារ ។ ជាក់ស្តែងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអង្គការមិនមែនរដ្ឋាភិបាល

[៣៧] រាជរដ្ឋាភិបាលកម្ពុជា៖ របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ទាក់ទងទៅនឹង ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០ ទំព័រទី១៣។

បានរៀបចំវេទិកាពិគ្រោះយោបល់ជាមួយកុមារ នៅក្នុងការរៀបចំគ្រប់របាយការណ៍ជាតិសម្រាប់ផ្ញើទៅអង្គការសហប្រជាជាតិ ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានធ្វើការស្ទាបស្ទង់មតិរបស់កុមារផងដែរ នៅក្នុងពេលរៀបចំសេចក្តីព្រាងផែនការសកម្មភាពជាតិលើកទី២ ស្តីពីការប្រឆាំងនឹងអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០១១-២០១៣ ក៏បានដាក់បញ្ចូលការចូលរួមរបស់កុមារថាគឺជាបញ្ហាពាក់ព័ន្ធផងដែរ[៣៨]។ ច្បាប់ដែលទាក់ទងទៅនឹងការចូលរួមរបស់កុមារនៅក្នុងនីតិវិធី បានលើកទឹកចិត្តកាន់តែច្រើនឡើងឱ្យកុមារសម្តែងមតិ ។ ច្បាប់ស្តីពីសុំកូនអន្តរប្រទេសបានតម្រូវឱ្យពិចារណាទស្សនៈរបស់កុមារនៅទូទាំងដំណើរការនៃសុំកូន ។ តុលាការ និងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ដែលទាក់ទិននៅក្នុងករណីសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេញមួយដំណើរការសុំកូន " កុមារដែលមានសមត្ថភាពអាចបញ្ចេញទស្សនៈរបស់គេបាន ត្រូវបានផ្តល់ការពិគ្រោះ និងផ្តល់ព័ត៌មានអំពីផលវិបាកនៃសុំកូន ដោយគិតគូរទៅដល់ចេតនារបស់កុមារ ហើយមានការថ្លឹងថ្លែងអំពីទស្សនៈរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ"[៣៩]។ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងអំពីការផ្តល់ឱកាសឱ្យអនីតិជនអាចសម្តែងយោបល់របស់ខ្លួនបាន នៅក្នុងការប្រជុំរៀបចំផែនការបង្វែរ និងការជួសជុលសំណងដល់ជនរងគ្រោះ ។

គោលនយោបាយសាលាកុមារមេត្រីឆ្នាំ២០០៧ បង្កើតឱ្យមានការរៀនសូត្រមានលក្ខណៈជាសិស្សមជ្ឈមណ្ឌល និងមានការចូលរួមនៅតាមសាលារៀន ។ បទដ្ឋានអប្បបរមានៃការថែទាំតាមមណ្ឌលឆ្នាំ២០០៦ បង្ហាញអំពីមាត្រា១៩យ៉ាងដែលត្រូវមានការចូលរួមពីកុមារនៅក្នុងការរស់នៅ គោលនយោបាយ និងការសម្រេចចិត្តនានានៅក្នុងមណ្ឌល។ បទដ្ឋានអប្បបរមានៃការថែទាំតាមសហគមន៍ បង្ហាញអំពីមាត្រា១៨យ៉ាង ដែលអនុញ្ញាតឱ្យកុមារចូលរួមនៅក្នុងការសម្រេចចិត្តនានា និងនៅក្នុងការរស់នៅប្រចាំថ្ងៃ ជាមួយនឹងអ្នកថែទាំ។

**២. សូមពិពណ៌នាអំពីការគាំទ្រជាសាធារណៈ ឬជាផ្លូវការណាមួយដែលបានផ្តល់ចំពោះការបង្កើតនិងថែរក្សារបស់អង្គការកុមារពិសេស និងវេទិកាសម្រាប់ការពារសិទ្ធិកុមារ។**

**ចម្លើយ**:

បណ្តាញកុមារអ្នកតស៊ូមតិ (Child Advocate Network=CAN) បង្កើតឡើងនៅក្នុងឆ្នាំ២០០៣ ដឹកនាំដោយកុមារ មានចំនួន៣៣២ក្លិប នៅក្នុងរាជធានី ខេត្តចំនួន១១ និងចលនាកុមារនិងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ (Cambodia Children and Young People Movement for Child Rights=CCYMCR) បង្កើតឡើងនៅក្នុងឆ្នាំ២០០២ ដឹកនាំដោយកុមារឬយុវជនមានចំនួន១៧ក្រុម នៅក្នុងរាជធានី ខេត្តចំនួន១៥ ក្នុងគោលបំណងធ្វើការរួមគ្នាដើម្បីលើកកម្ពស់សិទ្ធិកុមារ និងការចូលរួមរបស់កុមារនៅគ្រប់កម្រិត ហើយបានផ្តល់របាយការណ៍បំពេញបន្ថែមជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ នៅឆ្នាំ២០០៩ និងឆ្នាំ២០១០ ។ របាយការណ៍ត្រូវបានស្វែងរកមតិយោបល់តាមរយៈសិក្ខាសាលាថ្នាក់ជាតិ និងការអង្កេតអំពីមតិរបស់កុមារ ។

---

[៣៨] ក.ជ.ក, ផែនការយុទ្ធសាស្ត្រ២០០៩-២០១៣ ទំព័រ១៣។

[៣៩] មាត្រា៥(៥) និងមាត្រា៣០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ។

៣. សូមពិពណ៌នាអំពីចំនួន និងប្រភេទធនធានដែលមាន សម្រាប់គាំទ្រការចូលរួមរបស់កុមារនៅក្នុងសកម្មភាពដើម្បីដោះស្រាយអំពើហិង្សាលើកុមារ ។

**ចម្លើយ**:

ពុំមានទិន្នន័យស្តីពីធនធានដែលអង្គការមិនមែនរដ្ឋាភិបាល បានវិភាជន៍ចូលទៅក្នុងដំណើរការរៀបចំផែនការ ការតាមដាន ឬវាយតម្លៃ នោះទេ។

៤. ប្រសិនបើមាន សូមពិពណ៌នាអំពីការចូលរួមពាក់ព័ន្ធ របស់កុមារនៅក្នុងការអភិវឌ្ឍសម្ភារៈកុមារមេត្រី ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអំពើហិង្សាលើកុមារ និងផ្តល់ព័ត៌មានអំពីការប្រឹក្សាយោបល់ ការរាយការណ៍ និងយន្តការបណ្តឹង រួមទាំងនីតិវិធីតុលាការផងដែរ ។

**ចម្លើយ**:

ពុំមានទិន្នន័យស្តីពីការចូលរួមរបស់កុមារនៅក្នុងយុទ្ធសាស្ត្រព័ត៌មានទេ។ កុមារច្រើនតែបានចូលរួមក្នុងករណីពិសេស ដូចជាក្នុងការរៀបចំឯកសារ ឬសម្ភារៈរបស់ក្រសួងយុត្តិធម៌ សម្រាប់កាត់បន្ថយការភ័យខ្លាចនៅពេលចូលខ្លួនបង្ហាញភស្តុតាងនៅតុលាការ ជាដើម[៤០]។

## អនុសាសន៍ទី៨ : បង្កើតប្រព័ន្ធរាយការណ៍ និងសេវាដែលអាចទទួលបាន និងមានលក្ខណៈកុមារមេត្រី

១. សូមពិពណ៌នាអំពីការរៀបចំផ្នែកច្បាប់ គោលនយោបាយ និងស្ថាប័នដែលមានសម្រាប់ដាក់ឱ្យដំណើរការ សម្រាប់ផ្តល់ឱ្យមានយន្តការប្រឹក្សាយោបល់ដែលមានផលប្រយោជន៍កុមារ យន្តការបណ្តឹងនិងយន្តការរាយការណ៍ រួមទាំងនៅទីកន្លែងហ៊ុំព័ទ្ធ ដូចជាមណ្ឌលកុមារកំព្រា មណ្ឌលថែទាំ និងពន្ធនាគារ ។ សូមផ្តល់ព័ត៌មានលម្អិត ឬឯកសារយោង ឬឯកសារភ្ជាប់ ។

**ចម្លើយ**:

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញប្រកាសលេខ ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមានៃការថែទាំកុមារក្នុងមណ្ឌល និងប្រកាសលេខ១១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ ស្តីពីបទដ្ឋានអប្បបរមា នៃការថែទាំកុមារតាមសហគមន៍ បានតម្រូវឱ្យទីកន្លែងថែទាំមាននូវយន្តការប្តឹងតវ៉ាដែលមានប្រសិទ្ធភាព និងមានអត្ថន័យ ហើយត្រូវផ្តល់ព័ត៌មានឱ្យកុមារបានដឹងអំពីសិទ្ធិរបស់គេនៅក្នុងការប្តឹងតវ៉ា ព្រមទាំងអំពីនីតិវិធីប្តឹងតវ៉ា នោះផង[៤១]។

ច្បាប់ស្តីពីពន្ធនាគារ បានតម្រូវឱ្យពន្ធនាគារនីមួយៗរៀបចំឱ្យមាននីតិវិធីប្តឹងតវ៉ាមួយដែលអនុញ្ញាតឱ្យទណ្ឌិតអាចប្តឹងតវ៉ាពីប្រធានឬនាយកពន្ធនាគារបានដោយសម្ងាត់ អំពីការប្រព្រឹត្តខុសឆ្គងរបស់ទណ្ឌិត ឬដោយបុគ្គលិកពន្ធនាគារ ល្មើសនឹងវិធានឬគោលនយោបាយរបស់ពន្ធនាគារ[៤២]។

[៤០] រាជរដ្ឋាភិបាលកម្ពុជា៖ ក.ជ.ក របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ទាក់ទងទៅនឹងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០ ទំព័រទី៥។

[៤១] ប្រកាសលេខ៦១៦ស្តីពីបទដ្ឋានអប្បបរមានៃការថែទាំកុមារតាមមណ្ឌល មាត្រា៧ និងប្រកាសលេខ១១៩៨ស្តីពីបទដ្ឋានអប្បបរមានៃការថែទាំកុមារតាមសហគមន៍ មាត្រា៨។

[៤២] មាត្រា៦០ នៃច្បាប់ស្តីពីពន្ធនាគារ ។

២. តើមានគោលការណ៍ណែនាំណាមួយដែលបានចេញ សម្រាប់អ្នកមានវិជ្ជាជីវៈដែលធ្វើការពាក់ព័ន្ធនឹងការប្រឹក្សាយោបល់ និងយន្តការរាយការណ៍ដែរឬទេ ? តើមាននីតិវិធីនៃបណ្តឹង នីតិវិធីនៃការរាយការណ៍ ឬកម្មវិធីប្រឹក្សាយោបល់ណាមួយ ត្រូវបានវាយតម្លៃពីប្រសិទ្ធភាព និង/ឬវេទយិតភាពកុមារដែរឬទេ ? ប្រសិនបើមាន សូមផ្តល់ព័ត៌មានលម្អិត ឬឯកសារយោង ឬឯកសារភ្ជាប់ ។

**ចម្លើយ**:

មានតម្រូវការកាន់តែកើនឡើងអំពីនីតិវិធីនិងបរិយាកាសដែលមានវេទយិតភាពកុមារ ។ បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ មានបញ្ញត្តិស្តីពីបរិយាកាសដែលមានវេទយិតភាពកុមារ ហើយសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានតម្រូវឱ្យគ្រប់ការសម្ភាសន៍វិជ្ជាជីវៈដែលអនុវត្តដោយនគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ និងដោយគណៈកម្មការសហគមន៍ណាមួយសម្រាប់ការរៀបចំផែនការបង្វែរ ត្រូវតែប្រព្រឹត្តទៅក្នុងបរិយាកាសកុមារមេត្រី។

មានការបណ្តុះបណ្តាលដល់បុគ្គលិកដែលទទួលទូរស័ព្ទប្រចាំការពិសេស២៤ម៉ោងលើ២៤ម៉ោង អំពីបច្ចេកទេសប្រាស្រ័យទាក់ទង ហើយគេបានសង្កេតឃើញថាចំនួនអ្នកហៅចូលបានកើនឡើង បើទោះបីជាមិនមានការសិក្សាស្រាវជ្រាវយ៉ាងណាក្តី (ទូរស័ព្ទជួយកុមារនៅកម្ពុជា=Child Helpline Cambodia - CHC) បានរាយការណ៍ថាបានទទួលការហៅចូលសរុបទាំងអស់ចំនួន ២ ៨៩៤ដង ពីខែកក្កដាដល់ខែកញ្ញា ឆ្នាំ២០១១ ក្នុងនោះមានអ្នកហៅចូលជាស្ត្រីចំនួន ១ ១០៨ដង និងអ្នកហៅចូលជាបុរសចំនួន ៩០១ដង ដែលបង្ហាញឱ្យឃើញថាមានការកើនឡើងប្រមាណជា ៣៣% បើប្រៀបធៀបទៅនឹងត្រីមាសមុន[៩៣]។ កំណើននេះគឺអាស្រ័យដោយមកពីការបង្កលក្ខណៈងាយស្រួលក្នុងការហៅចូល ហើយនឹងការដែលគេបានឆ្លើយតបសមស្រប និងទាន់ពេលទៅនឹងសំណួររបស់កុមារនិងយុវជន។

ចាប់ពីចុងឆ្នាំ២០១០ ក្រសួងមហាផ្ទៃបានធ្វើការណែនាំដល់គ្រប់មណ្ឌលកែប្រែទាំងអស់ឱ្យរៀបចំឱ្យមានដាក់ប្រអប់សំបុត្រមួយនៅក្នុងបរិវេណរបស់ខ្លួន សម្រាប់ទទួលការប្តឹងតវ៉ាពីទណ្ឌិតនិងក្រុមគ្រួសាររបស់គេ ។ នាយកមណ្ឌលត្រូវចាត់តាំងមន្ត្រីម្នាក់ឱ្យទទួលបន្ទុកដោះស្រាយឆ្លើយតបទៅនឹងបណ្តឹងតវ៉ា ឬបើពុំនោះទេឱ្យបណ្តឹងនោះទៅឱ្យនាយកដ្ឋានពន្ធនាគារធ្វើការដោះស្រាយ ហើយបណ្តឹងត្រូវប្រធានមណ្ឌលកែប្រែយកចិត្តទុកដាក់ និងដោះស្រាយឱ្យបានរហ័ស ឬត្រូវបញ្ជូនមកអគ្គនាយកដ្ឋានពន្ធនាគារដើម្បីស្នើសុំយោបល់ករណីមិនអាចដោះស្រាយដោយខ្លួនឯងបាន ។

នៅឆ្នាំ២០០៩ មានករណីជួញដូរមនុស្ស កេងប្រវ័ញ្ចផ្លូវភេទ និងហិង្សាក្នុងគ្រួសារសរុបទាំងអស់ចំនួន៦៤៨ករណី ដែលត្រូវបានគេរាយការណ៍ឡើង ហើយមានជនសង្ស័យចំនួន៤៥៦នាក់ ដែលត្រូវបានឃាត់ខ្លួន។ ជនរងគ្រោះចំនួន៧៧៣នាក់ត្រូវបានគេរំដោះ ក្នុងនោះចំនួន១៥% ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាល[៩៤]។

### *ការរាយការណ៍ពីអំពើហិង្សា ( ដោយជនទី៣ ដែលមិនមែនជាជនរងគ្រោះ)*

៣. តើការរាយការណ៍ពីអំពើហិង្សាលើកុមារជាកាតព្វកិច្ចត្រូវបានប្រមើលទុកជាមុននៅក្នុងច្បាប់ដែរឬទេ? ប្រសិនបើមាន សូមបង្ហាញពីជនដែលជាប់កាតព្វកិច្ចរាយការណ៍ (ឧ. គ្រូបង្រៀន បុគ្គលិកសុខាភិបាល បុគ្គលិកសង្គមកិច្ច ឬបុគ្គលិកសុខុមាលភាពកុមារ

---

[៩៣] ទូរស័ព្ទជួយកុមារនៅកម្ពុជា ព្រឹត្តប័ត្រប្រចាំត្រីមាស ខែកក្កដាដល់កញ្ញាឆ្នាំ២០១១ គេហទំព័រhttp://childhelpline.org.kh

[៩៤] ក.ជ.ក, របាយការណ៍ស្តីពីការអនុវត្តន៍សេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

មន្ត្រីអនុវត្តច្បាប់ និងសាធារណៈជន) និងសូមផ្តល់ឯកសារពាក់ព័ន្ធ ។ សូមបង្ហាញផងដែរពីប្រភេទអំពើហិង្សាដែលស្ថិតក្នុងការរាយការណ៍ជាកាតព្វកិច្ច (ឧ. ការរំលោភបំពានផ្លូវភេទ អំពើហិង្សាលើរូបរាងកាយ ឬផ្សេងៗទៀត) ។

**ចម្លើយ**:

មន្ត្រីសង្គមកិច្ច មានកាតព្វកិច្ចត្រូវរាយការណ៍ឡើងនៅក្នុងករណីមានរឿងរំលោភបំពានខាងផ្លូវភេទ កេងប្រវ័ញ្ចពលកម្ម បោះបង់ចោលកុមារ ហិង្សាក្នុងគ្រួសារដែលធ្វើឱ្យមានរបួស និងកុមារប្រព្រឹត្តល្មើសនឹងច្បាប់[៩៥] ក៏ប៉ុន្តែបុគ្គលិកសុខាភិបាល គ្រូបង្រៀន មន្ត្រីពន្ធនាគារ ឬមន្ត្រីយុត្តិធម៌ មិនមានកាតព្វកិច្ចដូចគ្នានេះទេ ។ ក្រមសីលធម៌របស់បុគ្គលិកដែលធ្វើការនៅតាមមណ្ឌលរបស់រដ្ឋដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កំពុងតែរៀបចំធ្វើសេចក្តីព្រាងឡើង នឹងមានដាក់បញ្ចូលតម្រូវការឱ្យធ្វើការរាយការណ៍នេះជាកាតព្វកិច្ច។

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ឃុំ សង្កាត់ មានកាតព្វកិច្ចត្រូវប្រមូលនិងរាយការណ៍ព័ត៌មានអំពីអំពើហិង្សាដើម្បីទុកជាឯកសារ ហើយអាចរាយការណ៍ទៅឱ្យនគរបាល ឬសេវាជួយកុមារដទៃទៀត ឬអាចឱ្យសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ធ្វើសកម្មភាពបាន[៩៦]។

ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ បានកំណត់អំពីការរាយការណ៍ជាកាតព្វកិច្ចនូវអំពើហិង្សាដែលត្រូវបានសង្ស័យ ។ ក៏ប៉ុន្តែ វាមិនមែនជាកាតព្វកិច្ចរបស់ប្រជាជនទូទៅដែលត្រូវតែរាយការណ៍នោះទេ ។ អ្នកដែលត្រូវរាយការណ៍គឺ "អាជ្ញាធរដែលនៅជិតជាងគេ" ដែលត្រូវធ្វើការស៊ើបអង្កេត ហើយនៅក្នុងករណីធ្ងន់ធ្ងរ អាចរាយការណ៍ជូនតុលាការតែម្តង[៩៧]។ ជនរងគ្រោះ តំណាងជនរងគ្រោះ អាជ្ញាធរនៃលំនៅដ្ឋានជនរងគ្រោះ ឬ "ជនណាដែលបានដឹងអំពីហេតុការណ៍នៃអំពើហិង្សានៅក្នុងករណីដែលជនរងគ្រោះជាកុមារ" អាចដាក់ពាក្យប្តឹងទៅតុលាការសុំដីកាការពារជនរងគ្រោះបាន ក៏ប៉ុន្តែនេះមិនមែនជាកាតព្វកិច្ចដាច់ខាតទេ ។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩[៩៨] បានផ្តល់អំណាចជូនតុលាការ ឱ្យដកហូតអំណាចមេបាពីឪពុកម្តាយបាន បើសិនជាមានការរំលោភបំពានលើកុមារ ក៏ប៉ុន្តែមិនបានចែងអំពីកាតព្វកិច្ចរបស់មេឃុំ នៅក្នុងការស៊ើបអង្កេតរឿងនេះនោះទេ។

មាត្រា៤៨(ង)នៃច្បាប់ស្តីពីទេសចរណ៍ កំណត់ថា ប្រតិបត្តិករទេសចរណ៍ ភ្នាក់ងារ និយោជិត និងអ្នកជាប់កិច្ចសន្យាទាំងអស់ ត្រូវមានកាតព្វកិច្ចធ្វើការប្តឹង ឬរាយការណ៍ជាបន្ទាន់ជូននគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ដែលនៅជិតបំផុត ក្នុងករណីដឹង ឬមានការសង្ស័យថាមានការប្រព្រឹត្តបទល្មើស ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ឬការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត ។

មន្ត្រីអធិការកិច្ចទេសចរណ៍មាននីតិសម្បទាជានគរបាលយុត្តិធម៌ ហើយមានតួនាទីក្នុងការកត់ត្រា និង

---

[៩៥] តួនាទីរបស់មន្ត្រីរបស់ក្រសួងនិងមន្ទីរ សអយ នៅក្នុងរឿងព្រហ្មទណ្ឌ ដែលមានលើកនៅក្នុងឯកសាររបស់អង្គការយូនីសេហ្វឆ្នាំ២០០៧ ឈ្មោះថា Sound the Alarm: reporting Violence Against Children in Cambodiaទំព័រ២០។

[៩៦] សេចក្តីណែនាំស្តីពីការបង្កើតគណៈកម្មការឃុំសម្រាប់កិច្ចការនារីនិងកុមារនៅទូទាំងប្រទេស ឆ្នាំ២០០៧។

[៩៧] មាត្រា៩នៃច្បាប់ស្តីពីការបង្ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៦។

[៩៨] មាត្រា១២០នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩

ស៊ើបអង្កេតបទល្មើសដែលជាប់សង្ស័យក្នុងករណីធ្ងន់ធ្ងរ និងមានកាតព្វកិច្ចត្រូវរាយការណ៍ជាបន្ទាន់ទៅព្រះរាជអាជ្ញា ឬនគរបាលយុត្តិធម៌ ដើម្បីចាត់វិធានការតាមនីតិវិធីតាមបញ្ញត្តិមាត្រា ៥៩ មាត្រា ៦០ មាត្រា ៦១ និងមាត្រា ៦២ នៃច្បាប់ស្តីពីទេសចរណ៍។ ការអាក់ខានមិនបានអនុវត្តតាមក្រមសីលធម៌ និងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់ស្តីពីទេសចរណ៍ អាចនឹងក្លាយជាមូលហេតុនៃការបដិសេធ ឬដកហូតអាជ្ញាប័ណ្ណបាន។

ទីកន្លែងធ្វើការត្រូវបានធ្វើនិយ័តកម្មដោយការចុះធ្វើអធិការកិច្ច ស្របទៅតាមច្បាប់ស្តីពីការងារ ហើយអធិការមានកាតព្វកិច្ចត្រូវធានាថានិយោជកបានអនុវត្តតាមច្បាប់កម្ពុជា។ អធិការមានអំណាចយ៉ាងខ្លាំងនៅក្នុងការចុះពិនិត្យមើលទីកន្លែងកត់ត្រាទុក និងរៀបចំអធិការកិច្ចបច្ចេកទេស ដែលរួមមានទាំងការពិនិត្យសុខភាពរបស់បុគ្គលិកឡើងទៅ ។ មាត្រា៣៤៧ផ្តល់អំណាចជូនអធិការនៅក្នុងការចេញបញ្ជាឱ្យធ្វើការប្តូរផ្លាស់ បើសិនជាពិនិត្យឃើញថាមានការគំរាមមកលើសុខភាព ឬសុវត្ថិភាពរបស់បុគ្គលិក។ ច្បាប់ក៏បានដាក់ចេញផងដែរនូវទណ្ឌកម្មចំពោះការរំលោភបំពានផ្សេងៗ ដោយឱ្យពិន័យជាប្រាក់ ឬដាក់ពន្ធនាគារ ។ មាត្រា៣៦៨កំណត់ឱ្យពិន័យនិយោជកណាដែលប្រើប្រាស់បុគ្គលិក ដែលមានអាយុក្រោម១៨ឆ្នាំហើយមិនត្រឹមត្រូវទៅតាមបញ្ញត្តិច្បាប់ ។

## *យន្តការបណ្តឹង*

**៤. សូមបង្ហាញពីយន្តការឬស្ថាប័នដែលមានស្រាប់ដែលត្រូវបានបង្កើតឡើងជាពិសេស ដើម្បីទទួលបណ្តឹងអំពីអំពើហិង្សាលើកុមារ និងថាតើកុមារអាចមានសិទ្ធិប្រើប្រាស់នីតិវិធីទាំងនេះ ឬអាចជួបជនដែលបំពេញការងារក្នុងនាមពួកគេបានដែរឬទេ ។ សូមបង្ហាញថាតើមានជំនួយផ្នែកច្បាប់ដើម្បីជួយសម្រួលដល់ការដាក់ពាក្យបណ្តឹងឬទេ និងស្ថិតនៅក្នុងស្ថានភាពណាដែលទទួលបានជំនួយផ្នែកច្បាប់ ។**

**ចម្លើយ**:

ក្រសួងមហាផ្ទៃនិងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានតម្លើងទូរស័ព្ទទាន់ហេតុការណ៍ចំនួន៧ខ្សែនៅចន្លោះពីឆ្នាំ២០០៥ ដល់២០០៨ ដើម្បីជារបៀបចម្បងសម្រាប់ទទួលរបាយការណ៍អំពីករណីដែលមានការសង្ស័យថាមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ មានការសម្របសម្រួលរវាងកិច្ចការនេះ ជាមួយនឹងបទល្មើសទូទៅដែលរាយការណ៍ឡើងដោយទូរស័ព្ទទាន់ហេតុការណ៍របស់ក្រសួងមហាផ្ទៃ ។ អង្គការមិនមែនរដ្ឋាភិបាលក៏មានទូរស័ព្ទទាន់ហេតុការណ៍ដែរ គឺដើម្បីកេណ្ឌប្រមូលការឆ្លើយតបចំពោះករណីមានការសង្ស័យថាមានអំពីហិង្សា ឬកេងប្រវ័ញ្ចលើកុមារ ឬស្ត្រីឱ្យបានទាន់ពេល ។ កុមារសាច់ញាតិ ឬសាក្សីអាចហៅទូរស័ព្ទទៅកាន់លេខទាំងអស់នោះ ហើយអត្តសញ្ញាណរបស់អ្នកហៅ មិនបានធ្វើឱ្យមានការប៉ះពាល់ដល់ការរកឈ្មោះ ការឆ្លើយតប ឬការកត់ត្រាទិន្នន័យអ្វីទេ។ ប្រអប់សំបុត្រសម្រាប់ទទួលបណ្តឹងពីទណ្ឌិត ក្រុមគ្រួសាររបស់ទណ្ឌិត ឬអ្នកដែលមកសួរសុខទុក្ខទណ្ឌិត នឹងមានដាក់នៅតាមពន្ធនាគារ ។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសេចក្តីព្រាងនីតិវិធីប្តឹងតវ៉ាសម្រាប់សិស្ស បុគ្គលិកអប់រំ និងឪពុកម្តាយនៅខែវិច្ឆិកា ឆ្នាំ២០១១ ហើយនឹងបញ្ចប់នៅឆ្នាំ២០១២។

មានការផ្តល់សេវាខាងផ្លូវច្បាប់ដោយមិនយកកម្រៃដែរ សម្រាប់ជួយដល់កុមារដែលប្តឹងតវ៉ា។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) ត្រូវបានបង្កើតឡើងតាមផ្លូវច្បាប់នៅក្នុងឆ្នាំ១៩៩៥ ។ មាត្រា

២៩និង៣០ បានតម្រូវថាមូលនិធិមួយចំណែករបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់សម្រាប់ការផ្តល់សេវាដោយមិនយកកម្រៃជូនជនក្រីក្រ។

សេវាខាងផ្លូវច្បាប់ភាគច្រើនត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការផ្នែកជំនួយផ្លូវច្បាប់[៤៩]។ នៅក្នុងឆ្នាំ២០០៦ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន៨ ដែលធ្វើការផ្តល់សេវាខាងផ្លូវច្បាប់នៅរាជធានីខេត្តចំនួន១៣ ។ ការអង្កេតមួយនៅក្នុងឆ្នាំ២០០៦[៥០] បានឱ្យដឹងថា មានអ្នកដែលគេបានសម្ភាសន៍ចំនួន ៤/៥ មិនដែលបានដឹងអំពីការផ្តល់សេវាខាងផ្លូវច្បាប់ដោយមិនយកកម្រៃនេះទេ ។ ការអង្កេតនោះក៏បានរកឃើញផងដែរថា ការទៅរកសេវាខាងផ្លូវច្បាប់ភាគច្រើនបានធ្វើឡើងដោយមេឃុំ បន្ទាប់មកគឺមានអង្គការនានា ព្រះសង្ឃ និងគ្រូបង្រៀនជាដើម ។

### *ការប្រឹក្សាយោបល់ដល់កុមាររងគ្រោះ*

**៩.** តើកុមារដែលទទួលរងនូវអំពើហិង្សាលើរូបរាងកាយ ផ្លូវភេទ ផ្លូវចិត្ត ឬអំពើហិង្សាផ្សេងៗទៀត មានសិទ្ធិតាមផ្លូវច្បាប់ទទួលបាននូវការប្រឹក្សាយោបល់ដែរឬទេ?

តើមានការកែប្រែច្បាប់ ឬពិធីសារ/កិច្ចព្រមព្រៀងប្រតិបត្តិ ដើម្បីធ្វើឱ្យការស៊ើបអង្កេតដោយស្ថាប័នពាក់ព័ន្ធ ក្នុងនោះរួមមានបុគ្គលិកសង្គមកិច្ច មន្ត្រីអនុវត្តច្បាប់ ឬអ្នកបច្ចេកទេសខាងនីតិវេជ្ជវិទ្យាគិតគូរដល់វ័យឋិតនាពកុមារ ?

សូមផ្តល់ព័ត៌មានពាក់ព័ន្ធ ក្នុងនោះរួមមានព័ត៌មានអំពីថាតើយន្តការទាំងនេះមាននៅថ្នាក់ជាតិ និង/ឬនៅនាយកដ្ឋានជាក់លាក់ណាមួយដែរឬទេ។ តើអាចទទួលបាន(សេវាពី)យន្តការទាំងនេះដោយរបៀបណា និងយន្តការទាំងនេះទទួលបានមូលនិធិរបៀបណា ។

**ចម្លើយ**:

វិជ្ជាជីវៈជាចិត្តវិទូ ជាពេទ្យវិកលចរិត ឬជាអ្នកប្រឹក្សាយោបល់ មិនមានតាមផ្លូវការទេនៅកម្ពុជា។ ច្បាប់ក៏មិនបានចែងអំពីសិទ្ធិត្រូវទទួលបាននូវសេវាពិគ្រោះយោបល់ដោយមិនយកកម្រៃពីជនរងគ្រោះ ។ ទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានលើកទឹកចិត្តឱ្យប្រើការពិគ្រោះយោបល់ និងយន្តការដទៃទៀតនៅក្នុងការកសាងអនាគតរបស់កម្ពុជា ។ បទដ្ឋានអប្បបរមានៃការថែទាំក្នុងមណ្ឌលឆ្នាំ២០០៦របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរៀបរាប់លម្អិតអំពីការផ្តល់នូវការអភិវឌ្ឍខាងសង្គមកិច្ចនិងវប្បធម៌អប្បបរមា ដែលរួមមាន "ឱកាសនៅក្នុងការបានជួបជាមួយនឹងអ្នកផ្តល់ការពិគ្រោះ ដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវចំពោះកុមារដែលបានឆ្លងកាត់បទពិសោធន៍ប៉ះទង្គិចធ្ងន់ធ្ងរ ការស្លាប់ឪពុកម្តាយ អំពើហិង្សា ការរំលោភបំពាន"[៥១]។ល។

បទដ្ឋានអប្បបរមានៃការថែទាំក្នុងសហគមន៍ មិនបាននិយាយអំពីការពិគ្រោះយោបល់ទេ ក៏ប៉ុន្តែបានលើកអំពីសិទ្ធិនៅក្នុងការសម្តែងមតិ ដែលត្រូវតែផ្តល់ឱ្យនៅក្នុងបរិបទថែទាំ យកចិត្តទុកដាក់ និងគាំទ្រដែលធ្វើឱ្យកុមារមានសេរីភាពនៅក្នុងការសម្តែងវេទនារម្មណ៍ គំនិត យោបល់ និងការផ្តួចផ្តើមគំនិតរបស់គេ[៥២]។

---

[៤៩] ក.ជ.ក របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ច ខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០ ។

[៥០] រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ មានឈ្មោះថា ជំនួយផ្នែកច្បាប់នៅកម្ពុជា៖ ការអនុវត្ត ទស្សនៈ និងតម្រូវការ ឆ្នាំ ២០០៦ ។

[៥១] រាជរដ្ឋាភិបាលកម្ពុជា, ក្រសួង សអយ - បទដ្ឋានអប្បបរមានៃការថែទាំក្នុងមណ្ឌលស្នាក់នៅ ឆ្នាំ២០០៦ ទំព័រលេខ៥៤

[៥២] រាជរដ្ឋាភិបាលកម្ពុជា, ក្រសួង សអយ - បទដ្ឋានអប្បបរមានៃការថែទាំក្នុងសហគមន៍ ទំព័រលេខ៣

បច្ចុប្បន្ននេះ មានបច្ចេកទេសប្រាស្រ័យទាក់ទងជាលក្ខណៈកុមារមេត្រីរួចទៅហើយ នៅក្នុងសេវាវិជ្ជាជីវៈផ្សេងៗ។ នៅក្នុងវិស័យអប់រំនិងសិក្សាធិការ គោលនយោបាយសាលាកុមារមេត្រីឆ្នាំ២០០៧ បានដាក់បញ្ចូលនូវវិធីសាស្ត្រជាសិស្សមជ្ឈមណ្ឌល និងមានការចូលរួម ហើយនៅក្នុងបន្ទប់សវនាការវិញបានរៀបចំឱ្យមាននីតិវិធីនិងបរិយាកាសតុលាការកុមារមេត្រីផងដែរ។ នៅក្នុងឆ្នាំ២០០៤ ក្រសួងមហាផ្ទៃបានគ្រោងរៀបចំឧបករណ៍នៅក្នុងបន្ទប់សម្រាប់ធ្វើការសម្ភាសន៍កុមារ នៅក្នុងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងនៅតាមរាជធានីខេត្ត[៥៣]។

ក្រសួងយុត្តិធម៌បានរៀបចំឱ្យមានរបាំងសវនាការនៅក្នុងបន្ទប់សវនាការរបស់សាលាដំបូងរាជធានីខេត្តទាំងអស់ ហើយបានរៀបចំបណ្តាញតភ្ជាប់វីដេអូនៅក្នុងតុលាការចំនួន៥ ដើម្បីកាត់បន្ថយការប៉ះទង្គិចធ្ងន់ធ្ងររបស់កុមារនិងសាក្សីដែលងាយរងគ្រោះនៅក្នុងពេលផ្តល់សក្ខីកម្ម ។ ក្រសួងយុត្តិធម៌បានផលិតវីដេអូបង្រៀនសម្រាប់កុមាររងគ្រោះ កុមារជាសាក្សី និងកុមារទំនាស់នឹងច្បាប់ ដែលមានពន្យល់អំពីច្បាប់និងតួនាទីរបស់តួអង្គផ្សេងៗនៅក្នុងយុត្តិការព្រហ្មទណ្ឌ[៥៤]។

ក្នុងផ្នែកពាក់ព័ន្ធនឹងនគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ សេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានស្នើសុំឱ្យមានការសម្ភាសន៍និងបច្ចេកទេសប្រាស្រ័យទាក់ទងដែលមានលក្ខណៈកុមារមេត្រី ក្នុងនោះមានបន្ទប់សវនាការ ព្រមទាំងបរិយាកាសពន្ធនាគារ មានលក្ខណៈកុមារមេត្រីនិងការប្រជុំនៅថ្នាក់ឃុំ/សង្កាត់ក្នុងការរៀបចំយន្តការបង្វែរជាដើម។

## អនុសាសន៍ទី៩: ធានាឱ្យមានការទទួលខុសត្រូវ និងបញ្ឈប់និទណ្ឌភាព (ភាពរួចផុតពីទោស)

*១. តើមាន(បោះពុម្ព )របាយការណ៍ជាទៀងទាត់(ឧ.ប្រចាំឆ្នាំ)ដែលផ្តល់មានព័ត៌មានជាស្ថិតិ និងព័ត៌មានវិភាគអំពីករណីអំពើហិង្សាលើកុមារដែលត្រូវបានរាយការណ៍ដែរឬទេ ? ប្រសិនបើមាន សូមផ្តល់ព័ត៌មានលម្អិត ឬឯកសារយោង ឬឯកសារភ្ជាប់ៗ*

**ចម្លើយ** :

ក្រសួងផែនការបានបោះពុម្ពរបាយការណ៍ស្តីពីការអង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់កម្ពុជាជារៀងរាល់២ឆ្នាំម្តង ដែលមានទិន្នន័យស្តីពីអំពើឧប្បត្តិហេតុហិង្សាដែលកើតមានឡើង និងទិន្នន័យស្តីពីកម្រិតជីវភាពរស់នៅ និងស្ថានភាពការងារ ។ ក៏ប៉ុន្តែទិន្នន័យទាំងអស់នោះមិនត្រូវបានគេបំបែកទៅតាមអាយុរបស់ជនរងគ្រោះទេ ។ របាយការណ៍នេះមានបោះពុម្ពផ្សាយជាសៀវភៅ និងមាននៅក្នុងគេហទំព័ររបស់វិទ្យាស្ថានស្ថិតិ គឺhttp://www.nis.gov.kh/។ ការអង្កេតសម្រាប់ឆ្នាំ២០១១កំពុងតែដំណើរការ ។

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនមានស្ថិតិប្រចាំឆ្នាំ ហើយរបាយការណ៍ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១០ គឺជាចំណែកមួយនៃរបាយការណ៍ជាតិ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារ ឆ្នាំ២០០២-២០១០ ដែលត្រូវបានបញ្ជូនទៅគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិនៅឆ្នាំ២០១១។

---

[៥៣] រាជរដ្ឋាភិបាលកម្ពុជា,កជកក របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ចទាក់ទងទៅនឹងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០ ទំព័រ៦

[៥៤] រាជរដ្ឋាភិបាលកម្ពុជា,ក.ជ.ក របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០ ទំព័រ ៥ ។

របាយការណ៍រួមគ្នារបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីទិន្នន័យនៃការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភសេពសន្ថវៈនៅកម្ពុជា បានប្រមូលផ្តុំទិន្នន័យមកពីបណ្តាញអង្គការចំនួន ៤ គឺ ECPAT Cambodia, NGOCRC, COSECAM និង Cambodia ACTs ។ របាយការណ៍រួមគ្នានេះ មានតាំងពីឆ្នាំ២០០៣ មក ហើយរបាយការណ៍ចុងក្រោយគេត្រូវបានផ្សព្វផ្សាយនៅក្នុងឆ្នាំ២០១០។

**២. សូមផ្តល់ចំនួនសរុបនៃករណីដែលបានរាយការណ៍ និងការផ្តន្ទាទោសចំពោះបទល្មើសទាក់ទងនឹងអំពើហិង្សាលើកុមារ ដែលបានកត់ត្រាចាប់តាំងពីឆ្នាំ២០០៩ ។ ប្រសិនបើអាច សូមផ្តល់ព័ត៌មានដោយបំបែកទៅតាមប្រភេទនៃបទល្មើស ឬតាមទីកន្លែង (ផ្ទះ សហគមន៍ សាលារៀន កន្លែងធ្វើការ ស្ថាប័នផ្សេងៗទៀត) និង បំបែកទៅតាមអាយុ និងភេទរបស់ជនរងគ្រោះ។**

**ចម្លើយ** :

ទិន្នន័យចុងក្រោយគេបង្អស់ស្តីពីការចោទប្រកាន់ និងដាក់ទោសបទល្មើសប្រឆាំងនឹងកុមារមាននៅក្នុងឆ្នាំ២០០៩ (ព័ត៌មានលម្អិតមានបញ្ជាក់ក្នុងរបាយការណ៍ជាតិស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការជួញដូរកុមារ ការធ្វើពេស្យាចារកម្មកុមារ និងរូបភាពអាសអាភាសកុមារ) ។ នៅឆ្នាំ ២០០៩ ៤៥%នៃករណីរំលោភសេពសន្ថវៈនិងការប៉ុនប៉ងរំលោភសេពសន្ថវៈសរុបទាំងអស់៣៦៤រឿង ដែលត្រូវបានរាយការណ៍ឱ្យនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន មានជនរងគ្រោះដែលមានអាយុក្រោម១៨ឆ្នាំ ក្នុងនោះភាគច្រើនគឺស្ត្រីភេទ (៩៦%)។ បទល្មើសផ្លូវភេទមានច្រើនជាងគេ គឺមាន៦៤% ក្រៅពីនោះមានអំពើហិង្សាក្នុងគ្រួសារ២០% កេងប្រវ័ញ្ចផ្លូវភេទនិងរូបភាពអាសអាភាស ១១% និងជួញដូរមនុស្ស៥%[៥៥]។

**ប្រភេទករណីកេងប្រវ័ញ្ចផ្លូវភេទដែលបានកត់ត្រា ពីខែតុលាឆ្នាំ២០០៩ ដល់ខែតុលាឆ្នាំ២០១០**

| ប្រភេទបទល្មើស | ចំនួនករណី | ចំនួនជនរងគ្រោះ | ចំនួនជនល្មើស |
|---|---|---|---|
| ការដេកហូតអនីតិជនមិនស្របច្បាប់ | 6 | 5 | 7 |
| ការដេកហូតមិនស្របច្បាប់ មានគោលបំណង | 6 | 22 | 10 |
| ការដេកហូតមិនស្របច្បាប់ដើម្បីការឆ្លងដែន | 24 | 195 | 34 |
| ការជ្រើសរើសមិនស្របច្បាប់ដើម្បីកេងប្រវ័ញ្ច | 0 | 0 | 0 |
| អំពីលក់ ទិញ ឬដូរដោះមនុស្ស | 5 | 4 | 9 |
| អំពីលក់ ទិញ ឬដូរដោះមនុស្ស មានគោលបំណង | 3 | 4 | 6 |
| អំពីលក់ ទិញ ឬដូរដោះមនុស្សដើម្បីការឆ្លងដែន | 2 | 2 | 2 |
| ការដឹកជញ្ជូនមានគោលបំណង | 0 | 0 | 0 |
| ការដឹកជញ្ជូនឆ្លងដែន (ការដ្ឋឹជូនមនុស្សឆ្លងដែន) | 3 | 20 | 3 |
| ជម្រត់ ឃុំឃាំង ឬបង្ខាំងទុក | 3 | 64 | 4 |
| ទិញពេស្យាចារកុមារ | 15 | 43 | 22 |
| សញ្ញាកម្មពាក់ព័ន្ធនឹងពេស្យាចារកុមារ | 3 | 5 | 9 |
| សញ្ញាកម្មពេស្យាចារ | 19 | 121 | 34 |
| សញ្ញាកម្មពេស្យាចារកុមារ (អនីតិជន) | 2 | 6 | 6 |
| សញ្ញាកម្មពេស្យាចារ (ស្ថានទម្ងន់ទោស) | 8 | 32 | 9 |
| សញ្ញាកម្មពាក់ព័ន្ធនឹងពេស្យាចារកុមារ | 6 | 55 | 9 |
| ផ្តល់ទីកន្លែងសម្រាប់ពេស្យាចារ | 15 | 111 | 20 |
| រូបភាពអាសអាភាស | 6 | 44 | 18 |

[៥៥] របាយការណ៍សង្ខេបរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន របស់ក្រសួងមហាផ្ទៃ ឆ្នាំ២០០៩។

| | | | |
|---|---|---|---|
| រូបភាពអាសអាភាសកុមារ | 2 | 1 | 2 |
| រួមភេទជាមួយអនីតិជនក្រោម១៥ឆ្នាំ | 26 | 25 | 27 |
| អំពើអាសលើកុមារក្រោម១៥ឆ្នាំ | 7 | 9 | 10 |
| **សរុប** | **161** | **768** | **241** |

**តារាងលេខ១**, ប្រភព: ក.ជ.ក របាយការណ៍ស្តីពីការអនុវត្តសេចក្តីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ទាក់ទងទៅនឹងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

ស្ថិតិស្តីពីទម្រង់នៃបទល្មើសនិងពីជនល្មើស រួមទាំងការកាត់ទោសផងដែរ ត្រូវបានក្រសួងមហាផ្ទៃប្រមូលចងក្រងសម្រាប់ ឆ្នាំ២០០៥-២០១១ (សូមអានតារាងលេខ២ និងលេខ៣ក្នុងឧបសម្ព័ន្ធ)។ បើប្រៀបធៀបតួលេខនេះជាមួយនឹងតួលេខសម្រាប់១០ខែដំបូងនៃឆ្នាំ២០១១ មានការប្រែប្រួលច្រើន ក្នុងការប្រមូលទិន្នន័យនៅក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

ការសិក្សាមួយដែលដឹកនាំធ្វើឡើងដោយក្រសួងយុត្តិធម៌ និងUNDP នៅក្នុងឆ្នាំ២០០៦បានវាយតម្លៃថា ក្នុងមួយឆ្នាំៗ មានជម្លោះលើសពី៤ម៉ឺនករណី ដែលត្រូវបានពិនិត្យនិងដោះស្រាយដោយក្រុមប្រឹក្សាឃុំចំនួន ១,៦២១ ទូទាំងប្រទេសកម្ពុជា ដែលបានធ្វើការសម្រុះសម្រួលជម្លោះរវាងប្រជាពលរដ្ឋ និងលើកទឹកចិត្តឱ្យមានការអនុគ្រោះនិងយោគយល់គ្នា ហើយអភិបាលស្រុក ត្រូវបានចាត់ទុកថាគឺជានគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចអាចទទួលបណ្តឹងស្តីពីបទល្មើសព្រហ្មទណ្ឌ រួចចាត់ឱ្យមានការធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ។

ក៏ប៉ុន្តែ បើតាមមាត្រា៧៥របស់ក្រមនីតិវិធីព្រហ្មទណ្ឌ នគរបាលយុត្តិធម៌ត្រូវបញ្ជូនរឿងព្រហ្មទណ្ឌឱ្យទៅព្រះរាជអាជ្ញា បើទោះបីជាមានការព្រមព្រៀងគ្នាឱ្យដោះស្រាយរឿងដោយសំណងហិរញ្ញវត្ថុ ឬដោយការដកពាក្យបណ្តឹងយ៉ាងណាក្តី ។

មិនមានទិន្នន័យស្តីពីចំនួនករណីដែលមិនត្រូវបានដោះស្រាយដោយប្រព័ន្ធយុត្តិធម៌ទេ ។ តាមការអនុវត្តន៍ជាក់ស្តែង ការទូទាត់ហិរញ្ញវត្ថុត្រូវបានសម្របសម្រួលដោយនគរបាល រវាងគ្រួសាររបស់ជនរងគ្រោះនឹងជនល្មើស នៅក្នុងរឿងព្រហ្មទណ្ឌ ។ នៅតំបន់ឆ្ងាយដាច់ស្រយាលដែលមានជនជាតិភាគតិចរស់នៅ ជម្លោះត្រូវបានដោះស្រាយដោយចាស់ទុំ ។

**៣. សូមបង្ហាញពីវិធានការដែលបានប្រកាន់យក ឬវិធានការដែលបានពិចារណា ដើម្បីបង្ការទប់ស្កាត់មិន ឱ្យជនដែលមានទោសពីបទអំពើហិង្សា និងការរំលោភបំពានផ្លូវភេទលើកុមារ ធ្វើការជាមួយកុមារ ។**

មាត្រា១៧នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩បានចែងអំពីទណ្ឌកម្មបន្ថែម ដែលរួមមានការហាមឃាត់មិនឱ្យអនុវត្តវិជ្ជាជីវៈដោយមកពីបានទទួលកម្រៃពីបទល្មើសជារៀងរហូតឬជាបណ្តោះអាសន្ន ។ ទណ្ឌកម្មផ្សេងៗទៀតមានការហាមឃាត់មិនឱ្យស្នាក់នៅ ឬបណ្តេញចេញពីកម្ពុជា។ មាត្រា១៦៨នៃក្រមព្រហ្មទណ្ឌបានចែងអំពីទណ្ឌកម្មបន្ថែមជាការដកហូតសិទ្ធិខាងផ្លូវច្បាប់ ក្នុងនោះមានទាំងការលប់ចេញ ការបិទការិយាល័យ និងការហាមឃាត់សកម្មភាពមួយចំនួន។

## អនុសាសន៍ទី ១០ : ដោះស្រាយនិដ្ឋភាពយេនឌ័រនៃអំពើហិង្សាលើកុមារ

**១. សូមបង្ហាញពីបទប្បញ្ញត្តិជាក់លាក់ណាមួយដែលផ្តោតលើយេនឌ័រ ដែលមានបញ្ចូលនៅក្នុងគំនិតផ្តួចផ្តើមថ្នាក់ជាតិ (ឧ. ច្បាប់ គោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិ ដែលពាក់ព័ន្ធនឹងអំពើហិង្សាលើកុមារ និងវិធានការពិសេសដែលបានប្រកាន់យក ដើម្បីដោះស្រាយអំពើហិង្សាលើកុមារ ។**

**ចម្លើយ** :

មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញបានហាមឃាត់ការរើសអើងប្រឆាំងនឹងស្ត្រី ហើយច្បាប់នៅកម្ពុជាច្រើនតែត្រូវបានរៀបចំឡើងយ៉ាងណាដើម្បីឱ្យមានអព្យាក្រឹត្យខាងយេនឌ័រ ។ បើទោះជាយ៉ាងណាក្តី នៅមានចំណុចខ្លះនៃរដ្ឋធម្មនុញ្ញនិងច្បាប់ ដែលគ្មានអព្យាក្រឹត្យខាងយេនឌ័រទេ ។ មាត្រា៤៦របស់រដ្ឋធម្មនុញ្ញបានហាមឃាត់ជាពិសេសការកេងប្រវ័ញ្ចលើពេស្យាចារ និងអំពើអាសគ្រាមដែលធ្វើឱ្យមានការប៉ះពាល់ដល់កិត្តិយសរបស់នារី" ដែលជាហេតុអាចឱ្យមានការកាត់ស្មានបានថា គេគិតទៅដល់កេរ្តិ៍ឈ្មោះរបស់នារីច្រើនជាងទៅដល់បូរណភាពខាងរាងកាយ ហើយនិងថាគឺនារីៗដែលជាជនរងគ្រោះទី១ ។ លើសពីនោះទៅទៀត មាត្រា៤៦ក៏បានចែងដែរថា ឱ្យគាំទ្រនារី ឱ្យមានការងារធ្វើ ទទួលបាននូវការថែទាំវេជ្ជសាស្ត្រ ដើម្បីអាចបញ្ជូនកូនឱ្យទៅរៀនសូត្របាន និងមានជីវភាពរស់នៅសមល្មមបាន" ពោលគឺបានទទួលស្គាល់ការចាញ់ប្រៀបគេរបស់ស្ត្រីរួចទៅហើយៗត្រូវតែជំនះ ដើម្បីអាចទទួលនូវសិទ្ធិរបស់ខ្លួនតាមផ្លូវច្បាប់ ។ ក្រុមការងារបញ្ជ្រាបយេនឌ័រត្រូវបានបង្កើតនៅតាមក្រសួងស្ថាប័នចំនួន២៥។

**២. សូមបង្ហាញថា តើគោលនយោបាយទាំងនេះដោះស្រាយការអនុវត្តតាមប្រពៃណីដែលធ្វើឱ្យអន្តរាយដល់កុមារី ដូចជាការកាត់ប្រដាប់ភេទ (FGM/C) ការរៀបការដោយបង្ខំ និង/ឬឆាប់ពេក និង/ឬ ការអនុវត្តន៍តាមប្រពៃណីដែលធ្វើឱ្យអន្តរាយផ្សេងៗទៀតដែរឬទេ ? ។**

**ចម្លើយ** :

គំនិតផ្តួចផ្តើមនៅក្នុងការបញ្ជ្រាបយេនឌ័រ បានប្រឈមមុខដោយផ្ទាល់ជាមួយនឹងទស្សនាទានប្រពៃណីរបស់ច្បាប់ស្រី ដែលជាក្រមសីលធម៌តាមប្រពៃណីសម្រាប់នារីៗកម្ពុជា ហើយដែលបានបង្រៀនអំពីភាពទាបទន់ខ្សោយរបស់ស្ត្រី។

**៣. សូមបង្ហាញថា តើចាប់តាំងពី ឆ្នាំ២០០៩ មក មានការផ្លាស់ប្តូរដូចខាងក្រោមដែរឬទេ ៖**

- *អាយុអប្បបរមានៃការរៀបការសម្រាប់ស្ត្រីនិងបុរស ដើម្បីបង្ការទប់ស្កាត់មិនឱ្យមានការរៀបការឆាប់ពេកនិង/ឬដោយបង្ខំ និងពុះពារការរើសអើងឈរលើមូលដ្ឋានភេទ ?*

**ចម្លើយ** :

អាយុគ្រប់ការមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលចេញបញ្ញត្តិជាន់គ្នាជាមួយនឹងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ។ បច្ចុប្បន្ននេះ ទាំងបុរសទាំងស្ត្រីអាចរៀបការបាននៅអាយុ១៨ឆ្នាំ ប៉ុន្តែភាគីម្ខាងអាចមានអាយុត្រឹមតែ១៦ឆ្នាំក៏បានដែរ កាលណាមានការយល់ព្រមពីគ្រួសារ ។

- *អាយុអប្បបរមាដែលជាលក្ខខណ្ឌសម្រាប់ការយល់ព្រមដែលយកជាការបានក្នុងសកម្មភាពផ្លូវភេទ ។ តើអាយុទាំងនេះខុសគ្នាដែរឬទេ ចំពោះកុមារី និងកុមារា ?*

**ចម្លើយ** :

អាយុសម្រាប់ការយល់ព្រមនៅក្នុងសកម្មភាពខាងផ្លូវភេទគឺ១៥ឆ្នាំ ហើយមិនមានបែងចែកថាអាយុនេះសម្រាប់តែបុរសឬសម្រាប់តែស្ត្រីអ្វីទេ។ មាត្រា៤២និង៤៣នៃច្បាប់ស្តីពីការបង្ក្រាបការជួញដូរ មនុស្សនិងកេងប្រវ័ញ្ចផ្លូវភេទបានចាត់ទុកថាជាបទល្មើសទាំងអស់ រាល់ការរួមភេទឬអំពីអាសអាភាស ប្រព្រឹត្តជាមួយកុមារដែលមានអាយុក្រោម១៥ឆ្នាំ លើកលែងតែក្នុងករណីដែលជនល្មើសក៏មានអាយុក្រោម១៥ឆ្នាំដូចគ្នាដែរ ។

៤. សូមផ្តល់ទិន្នន័យដែលមានស្រាប់ អំពីអំពើហិង្សាលើកុមារ ដោយបំបែកទៅតាមភេទ និងភ្ជាប់ឯកសារដែលពាក់ព័ន្ធ ។

**ចម្លើយ** :

មានទិន្នន័យតិចតួចណាស់អំពីកុមាររងគ្រោះដោយសារអំពើហិង្សា ដែលត្រូវបានគេបំបែកចេញទៅតាមភេទ។ របាយការណ៍ស្តីពីការរំលោភបំពាននិងកេងប្រវ័ញ្ចផ្លូវភេទភាគច្រើនៗតែជារបាយការណ៍ ដែលមានជនរងគ្រោះជាស្ត្រី ។ បើទោះជាយ៉ាងណាក្តី មានភស្តុតាងដែលបញ្ជាក់ថាការបំពានផ្លូវភេទទៅលើកុមារាមិនត្រូវបានគេដាក់បញ្ចូលមកក្នុងវិធីសាស្ត្រសិក្សាស្រាវជ្រាវទេ ។ ការសិក្សាសម្រាប់ធ្វើជាមូលដ្ឋានអំពីអំពើហិង្សាលើកុមារមួយនឹងត្រូវបានគេរៀបចំឡើងនៅក្នុងឆ្នាំ២០១២ នៅក្នុងនោះគេនឹងពិនិត្យមើល អំពីហិង្សានៅតាមទីកន្លែងសំខាន់ៗមួយចំនួន ហើយនឹងមានការបែងចែកទៅតាមភេទនិងក្រុមអាយុ ផងដែរ ។

៥. សូមផ្តល់ព័ត៌មានអំពីការស្រាវជ្រាវជាធរមានដែលបានចេញផ្សាយចាប់តាំងពីឆ្នាំ២០០៩មក អំពីអំពើហិង្សាលើកុមារ ដែលពិចារណាពីចរិតលក្ខណៈពិសេស និងភាពងាយរងគ្រោះរបស់កុមារី និងកុមារា និងភ្ជាប់ឯកសារដែលពាក់ព័ន្ធ ។

**ចម្លើយ** :

មានរបាយការណ៍ស្តីពីអំពើហិង្សាលើកុមារជាច្រើននៅកម្ពុជា។ របាយការណ៍ភាគច្រើនៗតែផ្តោតទៅលើអំពើហិង្សាខាងផ្លូវភេទ។ មានការសិក្សាតិចតួចទេអំពីអំពើហិង្សានៅក្នុងបរិបទផ្សេងទៀត ដូចជាអំពើហិង្សានៅក្នុងឧស្សាហកម្មធ្វើការងារ ក្នុងពន្ធនាគារ ឬអំពើហិង្សាដែលកុមាររងគ្រោះផ្សេងទៀត ថ្វីបើថាការសិក្សាថ្មីៗនេះ បានគ្របដណ្តប់វិស័យទាំងអស់នោះរួចហើយក្តី ។ របាយការណ៍មួយចំនួន ដែលបានធ្វើការបែងចែកភាពងាយរគ្រោះរវាងកុមារីនិងកុមារា រួមមាន៖

- ការអង្កេតសេដ្ឋកិច្ចសង្គមកិច្ច ឆ្នាំ២០០៩របស់ក្រសួងផែនការ ដែលត្រូវបានគេផ្សព្វផ្សាយនៅក្នុងឆ្នាំ២០១០ បានផ្តល់ទិន្នន័យស្តីពីជនរងគ្រោះដោយអំពើហិង្សា ដែលបំបែកតាមភេទ (តែគ្មានតាមអាយុទេ)រួមទាំងការរងគ្រោះផ្ទួនៗ ភាគរយនៃការរាយការណ៍ រាយការណ៍ទៅឱ្យនរណា ។
- របាយការណ៍តាមដានបន្តស្តីពីអំពើហិង្សាឆ្នាំ២០០៩របស់ក្រសួងកិច្ចការនារី (បន្តពីរបាយការណ៍សិក្សាជាមូលដ្ឋាននៅក្នុងឆ្នាំ២០០៥)
- ការវិភាគស្ថានភាពស្ត្រីនិងកុមាររបស់អង្គការយូនីសេហ្វ ឆ្នាំ២០០៩
- ការវិភាគស្ថានភាពកុមារកំព្រា និងកុមារងាយរង្គ្រោះនៅកម្ពុជាក្នុងខេត្តគោលដៅ០៤, ខែឧសភា ឆ្នាំ២០១១។

## អនុសាសន៍ទី១១ : អភិវឌ្ឍ និងអនុវត្តការប្រមូលទិន្នន័យថ្នាក់ជាតិជាប្រព័ន្ធ និងកិច្ចខិតខំប្រឹងស្រាវជ្រាវ

១. តើប្រទេសរបស់អ្នកមានការថែរក្សាប្រព័ន្ធទិន្នន័យថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន ស្តីពីអំពើ ហិង្សាលើកុមារដែរឬទេ? តើថែរក្សាដោយរបៀបណា និងតើព័ត៌មានត្រូវបានផ្សព្វផ្សាយជាសាធារណៈជាញឹកញាប់របៀបណា ? តើប្រភេទព័ត៌មានអ្វីខ្លះ ដែលអាចទទួលបាននៅក្នុងប្រព័ន្ធទាំងនេះ ?

**ចម្លើយ** :

ច្បាប់ស្តីពីស្ថិតិឆ្នាំ២០០៥ បានប្រគល់ការទទួលខុសត្រូវទៅឱ្យវិទ្យាស្ថានជាតិស្ថិតិ ដែលស្ថិតនៅក្នុងក្រសួងផែនការ នៅក្នុងការប្រមូល វិភាគ និងបោះពុម្ពចែកចាយទិន្នន័យទាំងឡាយ។ វិទ្យាស្ថានជាតិ

ស្ថិតិមានគេហទំព័រមួយ ដែលផ្តល់ព័ត៌មានអំពីទិន្នន័យដែលគេអាចស្វែងរកបាន ឬភ្ជាប់ទៅនឹងក្រសួងណាដែលពាក់ព័ន្ធ: http://nis.gov.kh/index.php/nss/official-statistics/581

នៅឆ្នាំ ២០០២ គេបានរៀបចំឱ្យមានសៀវភៅទិន្នន័យឃុំ-សង្កាត់ សម្រាប់ប្រមូលព័ត៌មានសង្គមកិច្ចសេដ្ឋកិច្ចអំពីប្រជាជន ការអប់រំ មុខរបរ ធនធានធម្មជាតិ ការដឹកជញ្ជូន ក្រុមងាយរងគ្រោះ រដ្ឋបាល និងសន្តិសុខ ។ ព័ត៌មានស្តីពីអំពើហិង្សាក្នុងគ្រួសារ ការបំពានខាងផ្លូវភេទ និងការជួញដូរ ត្រូវបានគេដាក់បញ្ចូលជាប្រភេទថ្មីនៅក្នុងសៀវភៅឃុំ/សង្កាត់ នៅឆ្នាំ២០០៥ ។ ទិន្នន័យដែលទទួលបានត្រូវបានបញ្ជូនទៅឱ្យក្រសួងផែនការនិងក្រសួងមហាផ្ទៃ។

នៅក្នុងឆ្នាំ២០០៤ វិទ្យាស្ថានជាតិស្ថិតិបានរៀបចំបង្កើតប្រព័ន្ធទិន្នន័យ CAMInfo ឡើង ដោយប្រើប្រាស់ទិន្នន័យរបស់ឃុំ សម្រាប់តាមដានការរីកចម្រើនឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា។

នៅក្នុងឆ្នាំ២០០៩ ក្រសួងផែនការបានដឹកនាំធ្វើការអង្កេតថ្នាក់ជាតិមួយ ដើម្បីពិនិត្យមើលទិន្នន័យរបស់ឃុំ ហើយបានរកឃើញថាលទ្ធផលនៃការអង្កេតនេះមានការទាក់ទងគ្នាយ៉ាងខ្លាំងជាមួយនឹងទិន្នន័យរបស់ឃុំ ដែលជាការបញ្ជាក់ថាប្រព័ន្ធទិន្នន័យរបស់ថ្នាក់ឃុំមានគុណភាពល្អ ។ រាជរដ្ឋាភិបាលកម្ពុជាបានរាយការណ៍ក្នុងឆ្នាំ២០១០ថា ទិន្នន័យរបស់ថ្នាក់ឃុំស្តីពីអំពើហិង្សាក្នុងគ្រួសារ មានគុណភាពគ្រប់គ្រាន់ដើម្បីយកទៅប្រើប្រាស់នៅក្នុងប្រព័ន្ធតាមដានថ្នាក់ជាតិ សម្រាប់ផ្តល់ព័ត៌មានទៅឱ្យការធ្វើគោលនយោបាយ[៥៦]។

ការវិភាគស្ថានភាពនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ[៥៧] បានអធិប្បាយថា រហូតមកដល់ពេលនេះរបាយការណ៍ជាច្រើនបានពឹងផ្អែកទៅលើភស្តុតាងជាក់ស្តែង ដែលរួមមានទាំងប្រវត្តិរបស់អ្នកជនគ្រោះផងដែរ។ ការដែលខ្វះការស្រាវជ្រាវជាប្រព័ន្ធនិងមានលក្ខណៈវិទ្យាសាស្ត្រ បានធ្វើឱ្យអន្តរាគមន៍ត្រូវបានប្រព្រឹត្តទៅដោយមិនបានទទួលផលប្រយោជន៍អ្វីពីទិន្នន័យគួរឱ្យជឿជាក់និងងាយយល់បាន ។ រាជរដ្ឋាភិបាលកម្ពុជាបានយល់ស្របតាមសេចក្តីសន្និដ្ឋាននេះ ហើយបានលើកផែនការធ្វើការស្រាវជ្រាវលម្អិតអំពីអំពើហិង្សាលើកុមារ ដែលនឹងត្រូវដឹកនាំឡើងដោយក្រសួងកិច្ចការនារីនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្នុងឆ្នាំ២០១២ ដើម្បីផ្តល់តួលេខមូលដ្ឋានសម្រាប់គាំទ្រដល់អន្តរាគមន៍ និងការប៉ាន់ប្រមាណអំពីផលប៉ះពាល់នានា។

**២. តើព័ត៌មានដែលអាចរកបាន ត្រូវបានបែងចែកទៅតាមភេទ អាយុ ជាតិពន្ធុ ចរិតនៃការរបួស ឬមរណភាព មូលហេតុនៃការរបួស ឬមរណភាព ទីតាំងភូមិសាស្ត្រនៃឧប្បត្តិហេតុនៃអំពើហិង្សា បរិបទនៃឧប្បត្តិហេតុ កាលបរិច្ឆេទ និងម៉ោងនៃឧប្បត្តិហេតុ ទំនាក់ទំនងរវាងជនរងគ្រោះ និងជនល្មើស ដែរឬទេ?**

**ចម្លើយ** :

ទិន្នន័យមានការផ្លាស់ប្តូរ។

***៣. សូមបង្ហាញថា តើប្រទេសរបស់អ្នក ថែរក្សានូវប្រព័ន្ធ/បញ្ជីណាមួយក្នុងចំណោមប្រព័ន្ធ/បញ្ជីដូចខាងក្រោម នេះ ៖***

- ***បញ្ជីអត្រានុកូលដ្ឋានកំណើត មរណៈ និងអាពាហ៍ពិពាហ៍***

[៥៦] រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ស្តីពីការប្រមូលទិន្នន័យនិងតាមដានអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាទំព័រ២៨។

[៥៧] ការវិភាគស្ថានភាពស្ត្រីនិងកុមារនៅកម្ពុជា ឆ្នាំ២០០៩។

**ចម្លើយ** :

អនុក្រឹត្យលេខ១០៣ ស្តីពីអត្រានុកូលដ្ឋានត្រូវបានអនុម័តឡើងនៅក្នុងឆ្នាំ២០០០។ អនុក្រឹត្យនេះបានតម្រូវឱ្យឪពុកឬម្តាយទៅចុះសំបុត្រកំណើតឱ្យកូនដែលទើបនឹងកើតថ្មីនៅក្នុងអំឡុងពេល៣០ថ្ងៃ នៅឯមន្ទីរឃុំសង្កាត់នៃអាស័យដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន ។ គេបានរៀបចំធ្វើយុទ្ធនាការផ្សព្វផ្សាយដើម្បីបង្កើនការចុះបញ្ជីអត្រានុកូលដ្ឋាន ហើយនៅពេលដែលយុទ្ធនាការនោះបានបញ្ចប់ទៅនៅក្នុងឆ្នាំ២០០៦ ការចុះសំបុត្រ និងបញ្ជីកំណើតបានកើនឡើងស្មើនឹងលើសពី៩០% នៃចំនួនប្រជាជនដែលនៅពេលចាប់ផ្តើមមានត្រឹមតែ៥%តែប៉ុណ្ណោះ[៥៨] ។

នៅឆ្នាំ ២០១០ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ ០២៩ សណន ដល់អភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ធ្វើការត្រួតពិនិត្យ និងយកចិត្តទុកដាក់ពង្រឹងការងារអត្រានុកូលដ្ឋាន។ ជាមួយគ្នានេះដែរ ក្រសួងក៏កំពុងតែដំណើរការការបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា។ ការអនុវត្តតាមកាតព្វកិច្ចចុះបញ្ជីកំណើតបានថយចុះម្តងទៀតនៅក្នុងបណ្តាឆ្នាំថ្មីៗនេះ និងនៅក្នុងឆ្នាំ២០១០ ដែលគេបានប៉ាន់ស្មានថាបានត្រឹមតែ៦៦%តែប៉ុណ្ណោះ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំលេខ០២៩កាលពីខែវិច្ឆិកាឆ្នាំ២០១០នេះ ធ្វើការណែនាំដល់អ្នកកាន់កាប់បញ្ជី (គណៈអភិបាលរាជធានីខេត្ត ស្រុកខ័ណ្ឌ និងមេឃុំសង្កាត់) ឱ្យធ្វើការកែលំអបញ្ជីឡើងវិញ[៥៩]។ មានការចុះបញ្ជីអាពាហ៍ពិពាហ៍ និងមរណភាពផងដែរ ។

- *ប្រព័ន្ធព័ត៌មានស្តីពីកុមារគ្មានការថែទាំពីឪពុកម្តាយ*

**ចម្លើយ** :

កុមារកម្ពុជា មិនដែលគ្មានអ្នកទទួលខុសត្រូវនោះទេ ព្រោះអំណាចមេបាត្រូវបានផ្ទេរទៅឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅពេលដែលអំណាចមេបានោះត្រូវបានដកហូតពីអ្នកអាណាព្យាបាល ។ នៅក្នុងឆ្នាំ១៩៩៩ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានមួយអំពីកុមារនិងស្ត្រីរងគ្រោះដោយការជួញដូរ ដែលត្រូវបានគេធ្វើមាតុភូមិនិវត្តន៍ ឬនិរទេសមកពីប្រទេសក្រៅមកវិញ ។ នៅក្នុងឆ្នាំ២០០៧ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបង្កើតប្រព័ន្ធទិន្នន័យដោយឡែកថ្មីមួយទៀតស្តីពីកុមារដែលរស់នៅក្នុងការថែទាំជំនួស ។ នៅក្នុងឆ្នាំ២០១១ មានអង្គការចំនួន១៩២ បានចុះអនុសារណៈជាមួយនឹងក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា[៦០] ។ នេះគឺជាការទទួលខុសត្រូវរបស់ស្ថាប័ននីមួយៗដែលត្រូវរាយការណ៍ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អំពីកុមារដែលមានរស់នៅក្នុងមណ្ឌលរបស់ខ្លួន ដោយហេតុនោះព័ត៌មានលម្អិតអំពីកុមារនៅក្នុងមណ្ឌលទាំងអស់នោះមិនត្រូវបានគេដាក់បញ្ចូល ទៅក្នុងប្រព័ន្ធទិន្នន័យទេ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាទទួលខុសត្រូវនៅក្នុងការតាមដាន គ្រប់គ្រង និងធ្វើអធិការកិច្ចលើស្ថាប័នទាំងអស់ ហើយបានចុះធ្វើអធិការកិច្ចមណ្ឌលស្នាក់នៅជាប្រចាំ[៦១]។

---

[៥៨] ព័ត៌មានរបស់អង្គការយូនីសេហ្វ ឆ្នាំ២០១០។

[៥៩] របាយការណ៍ជាតិស្តីពីការអនុវត្តន៍ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ២០០២-២០១០។

[៦០] យូនីសេហ្វ ការវិភាគស្ថានភាពស្ត្រីនិងកុមារនៅកម្ពុជា ឆ្នាំ២០០៩ ទំព័រ១៨១។

[៦១] ក.ជ.ក រាជរដ្ឋាភិបាលកម្ពុជា, របាយការណ៍ឆ្លើយតបទៅនឹងបញ្ជីសំណួររបស់គណៈកម្មការសិទ្ធិកុមារទាក់ទងទៅនឹងរបាយការណ៍លើកទី២

- *ប្រព័ន្ធដើម្បីបញ្ចូល និងរក្សាទុកទិន្នន័យអំពីកុមារត្រូវបានដកហូតសេរីភាព រួមទាំងនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការឃុំឃាំងផ្នែករដ្ឋបាល និងការឃុំខ្លួនរង់ចាំការជំនុំជម្រះ។*

- នៅក្នុងឆ្នាំ២០០៦ ក្រសួងយុត្តិធម៌បានបង្កើតប្រព័ន្ធទិន្នន័យមួយសម្រាប់ប្រមូលសរុបព័ត៌មានស្ដីពីយុវជន ដោយធ្វើសមាហរណកម្មទិន្នន័យដែលទទួលបានពីគ្រប់ទីភ្នាក់ងារដែលមានការពាក់ព័ន្ធនៅក្នុងប្រព័ន្ធយុត្តិធម៌ ដោយបានអនុវត្តសាកល្បងនៅក្នុងរាជធានី ខេត្តចំនួន៦។ ប្រព័ន្ធទិន្នន័យនេះមានបំណងចង់តភ្ជាប់ទៅនឹងកុំព្យូទ័ររបស់តុលាការគំរូ[៦២]។
- ប្រព័ន្ធទិន្នន័យរបស់កម្មវិធី LEASETC មានព័ត៌មានស្ដីពីការជួញដូរ អំពើហិង្សាក្នុងគ្រួសារ និងករណីរឿងរំលោភសេពសន្ថវៈ ដែលត្រូវបានដោះស្រាយតាមប្រព័ន្ធច្បាប់។

- *ប្រព័ន្ធដើម្បីបញ្ចូលនិងរក្សាទុកទិន្នន័យអំពីទម្រង់ជាក់លាក់នៃអំពើហិង្សាលើកុមារ*

- ក្រសួងមហាផ្ទៃបានប្រមូលសរុបស្ថិតិស្ដីពីរឿងព្រហ្មទណ្ឌនិងការស៊ើបអង្កេតដែលដឹកនាំធ្វើដោយនគរបាលជាតិ ។ ទម្រង់ស្តង់ដារសម្រាប់ការស្រង់យកបណ្ដឹងត្រូវបានដាក់បញ្ចូលជួរការទៅក្នុងនីតិវិធីអនុវត្តនៅក្នុងឆ្នាំ២០១០ ហើយកំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បង ដោយបែងចែកតាមភេទនិងអាយុ ផងដែរ។
- នៅក្នុងឆ្នាំ២០០៤ ក្រសួងមហាផ្ទៃបានបង្កើតប្រព័ន្ធទិន្នន័យមួយអំពីការផ្ដន្ទាទោសក្នុងករណីរឿងបទល្មើសខាងផ្លូវភេទនិងជួញដូរ។ ទិន្នន័យស្ដីពីការផ្ដន្ទាទោសរឿងហិង្សាក្នុងគ្រួសារត្រូវបានដាក់បញ្ចូលនៅក្នុងឆ្នាំ២០០៥ ដោយហេតុនោះ នាយកដ្ឋានប្រឆាំងនឹងការជួញដូរមនុស្សនិងការពារអនីតិជន ក៏មានការទទួលខុសត្រូវនៅក្នុងការស៊ើបអង្កេតរឿងហិង្សាក្នុងគ្រួសារ និងហិង្សាខាងផ្លូវភេទ ចាប់ពីឆ្នាំ២០០៦រហូតមក ដោយប្រើប្រាស់ទម្រង់ស្តង់ដារទទួលពាក្យបណ្ដឹង។ ទម្រង់នោះ មាននិយាយអំពីថ្ងៃខែឆ្នាំកំណើតរបស់ជនរងគ្រោះផងដែរ។
- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានប្រព័ន្ធទិន្នន័យស្ដីពីពលករឆ្លងដែន និយោជក និយោជិត និងប្រភេទកិច្ចសន្យា រួមទាំងកិច្ចសន្យាជាមួយនឹងកុមារអាយុក្រោម១៨ឆ្នាំ ផងដែរ។

**៤. សូមបញ្ជាក់ថា ចាប់តាំងពីឆ្នាំ២០០៩មក ក្នុងចំណោមការប្រមូលទិន្នន័យនិងការស្រាវជ្រាវស្ដីពីអំពើហិង្សាលើកុមារដូចមានរាយខាងក្រោមនេះ មានណាមួយដែលត្រូវបានគេអនុវត្តដែរឬទេ ៖**

**ចម្លើយ**

- *ការអង្កេតប្រជាជនគ្រប់ទម្រង់*

- ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ២០០៨
- ការអង្កេតប្រជាសាស្ត្រនិងសុខភាព (CDHS) ឆ្នាំ២០១០
- ការជម្រឿនសហគ្រាស ឆ្នាំ២០១១ (កំពុងដំណើរការ)។

និងទី៣ របស់ព្រះរាជាណាចក្រកម្ពុជា ស្ដីពីការអនុវត្តន៍អនុសញ្ញាស្ដីពីសិទ្ធិកុមារ ខែមេសា ឆ្នាំ២០១១។

[៦២] រាជរដ្ឋាភិបាលកម្ពុជា,ក.ជ.ក របាយការណ៍ស្ដីពីការអនុវត្តន៍សេចក្ដីសម្រេចលេខ 2009/26 របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្ដីពីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ខែកក្កដាឆ្នាំ២០១០។

- *ការសិក្សាអំពីគុណភាព ឬការអង្កេតផ្អែកលើការសម្ភាសន៍ជាមួយនឹងឪពុកម្តាយ/អាណាព្យាបាលរបស់កុមារ*

- អង្គការន័រវេសសង្គ្រោះកុមារ, ការស្រាវជ្រាវស្តីពីការចូលរួមរបស់កុមារ : ជំនឿអំពីតម្លៃនិងការប្រព្រឹត្តខាងវប្បធម៌ ដែលមានឥទ្ធិពលមកលើការចូលរួមរបស់កុមារកម្ពុជា នៅក្នុងការរស់នៅប្រចាំថ្ងៃ ឆ្នាំ២០០៨។
- ការប៉ាន់ប្រមាណអំពីគោលនយោបាយ នីតិវិធី និងការអនុវត្តន៍នៅក្នុងការបញ្ជូន ទុកដាក់ គ្រប់គ្រងស្តារសម្បទា និងសមាហរណកម្មកុមារ ស្ត្រី និងជនងាយរងគ្រោះនៅតាមមណ្ឌលស្តារយុវនីតិសម្បទា និងសារធាតុញៀន ក្រោមអាជ្ញាធរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែកញ្ញា ឆ្នាំ២០១១។

- *ការសិក្សា ឬអង្កេត ដើម្បីប៉ាន់ប្រមាណផលប៉ះពាល់នៃវិធានការច្បាប់*

**ចម្លើយ**

ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងកេងប្រវ័ញ្ចផ្លូវភេទបានទាក់ទាញការយកចិត្តទុកដាក់ជាច្រើន ហើយឥទ្ធិពលជាទូទៅៗលើការជួញដូរត្រូវបានអង្គភាពមួយចំនួនធ្វើការពិនិត្យឡើងវិញជារឿយៗ។

- *តើមានការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រអំពីអំពើហិង្សាលើកុមារដែរឬទេ រួមទាំងអំពើហិង្សាទៅលើក្រុមជនងាយរងគ្រោះផងដែរ ? ប្រសិនបើមានសូមបង្ហាញប្រធានបទនៃការសិក្សាស្រាវជ្រាវ ហើយការរកឃើញដោយគម្រោងនេះអាចត្រូវបានពិគ្រោះលម្អិត នៅទីណា?*

**ចម្លើយ**

រាជរដ្ឋាភិបាលកម្ពុជាបានដឹកនាំការធ្វើអង្កេតស្តីពីយុវជនងាយរងគ្រោះជាងគេ (Most At Risk Young People Survey -MARYPS) នៅក្នុងឆ្នាំ២០១០ ដែលបានផ្តល់ទិន្នន័យដ៏មានតម្លៃអំពីភាពងាយរងគ្រោះរបស់កុមារនិងយុវជនចំពោះការប្រើប្រាស់សារធាតុញៀននិងសុរា ឥរិយាបទខាងផ្លូវភេទដ៏ប្រថុយប្រថាន និងហានិភ័យ រួមផ្សំនៃហិង្សានិងមិត្តភក្តិ។

**៥- តើរបាយការណ៍ដែលត្រូវបានបោះពុម្ពផ្សាយជាទៀងទាត់(ដូចជារាល់ឆ្នាំ) មានបានផ្តល់ព័ត៌មានស្តីពីអំពើហិង្សាលើកុមារដែរឬទេ? បើសិនជាមែន សូមផ្តល់ព័ត៌មានលម្អិត និងយោង ឬភ្ជាប់មកជាមួយ**

**៦- សូមបញ្ជាក់អំពីវិធានការដែលបានដាក់ចេញតាំងពីឆ្នាំ២០០៩មក ឬប្រុងនឹងអនុវត្តនៅក្នុងការប្រើប្រាស់សូចនាករ ដែលផ្អែកទៅលើស្តង់ដារដែលបានឯកភាពគ្នាជាអន្តរជាតិអំពីអំពើហិង្សាលើកុមារ ហើយនិងទីភ្នាក់ងារទទួលខុសត្រូវផងដែរៗ**

**ចម្លើយ** (៥+៦)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអភិវឌ្ឍឡើងនូវវិធីសាស្ត្រនៃការប្រមូលទិន្នន័យដែលទាក់ទងទៅនឹងកុមារ។ ក្រសួងបានដាក់ចេញនូវ ក្របខ័ណ្ឌនិងឧបករណ៍ ថ្នាក់ជាតិសម្រាប់តាមដាននិងវាយតម្លៃកុមារកំព្រានិងកុមារងាយរងគ្រោះ (National Monitoring &Evaluation for Orphans and Vulnerable Children Frameworkand Tools) នៅក្នុងឆ្នាំ២០១១ មានអ្នកតំណាងមកពីក្រុមការងារពហុវិស័យស្តីពីកុមារកំព្រានិងកុមារងាយរងគ្រោះ(National Multi-Sectoral Orphans and Vulnerable Children Task Force-NOVCTF)ក្រសួងព័ត៌មាន ក្រសួងផែនការ SCA, UNICEF, UNAIDS, និងអ្នកពាក់ព័ន្ធដទៃទៀតៗ ការសាកល្បងនេះមានបំណងចង់កំណត់រកសូចនាករដើម្បីធ្វើបច្ចុប្បន្នភាពប្រព័ន្ធប្រមូលទិន្នន័យទាំងអស់របស់ក្រសួង។

**៧- តើមានរបៀបវារៈនៅក្នុងការស្រាវជ្រាវអំពើហិង្សាលើកុមារ តាមទីកន្លែងនានាដែរឬទេ? តើគេបានដោះស្រាយបញ្ហាកុមារងាយរងគ្រោះយ៉ាងដូចម្តេច?**

**ចម្លើយ**

ក្រសួងនានា និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានដាក់បញ្ចូលរបៀបវារៈនៃការសិក្សាស្រាវជ្រាវ និងការសិក្សាស្រាវជ្រាវអាទិភាព ទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ជាក់ស្តែងដូចជាក្រសួងអប់រំ យុវជន និងកីឡា មាននាយកដ្ឋានស្រាវជ្រាវគរុកោសល្យមួយ[៦៣] ជាដើម។ បើទោះជាយ៉ាងណាក្តី សមត្ថភាពនៅក្នុងការធ្វើការសិក្សាស្រាវជ្រាវ និងមូលនិធិ នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយ នៅកម្ពុជា។

**៨- តើមានការអតិវឌ្ឍការសិក្សាថ្នាក់ជាតិអំពីអំពើហិង្សាលើកុមារជាទូទៅ ឬនៅក្នុងទីកន្លែងដោយឡែកណាមួយ អ្វីដែរឬទេ ?**

**(ក្នុងគ្រួសារនិងក្នុងផ្ទះ នៅសាលារៀន នៅតាមស្ថាប័នថែទាំ ស្ថាប័នយុត្តិធម៌អនីតិជន កន្លែងធ្វើការ និងសហគមន៍)?**

**ចម្លើយ**

សូមអានចម្លើយខាងលើ។

## អនុសាសន៍ទី ១២: ពង្រឹងការប្តេជ្ញាចិត្តជាអន្តរជាតិ

**១. ដរាបណាប្រទេសរបស់អ្នកមិនទាន់បានផ្តល់សច្ចាប័នលើលិខិតុបករណ៍ដូចខាងក្រោម សូមបង្ហាញពីជំហានដែលបានប្រកាន់យក ឬដែលបានប្រមើលមើល ចំពោះការផ្តល់សច្ចាប័នលើលិខិតុបករណ៍ដូចខាងក្រោម ៖**

- *អនុសញ្ញាសិទ្ធិកុមារ*
- *ពិធីសារបន្ថែមស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាស*
- *ពិធីសារបន្ថែមស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ*
- *អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប និងពិធីបន្ថែមនៃអនុសញ្ញានេះ*
- *អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងពិធីបន្ថែម*
- *អនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមា សម្រាប់ការចូលធ្វើការងារ*
- *អនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ*
- *ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង*
- *លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។*

**២. សូមបង្ហាញថា តើមានឧបម្រុងទុកណាមួយ ដែលបានដាក់នៅពេលផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមត្រូវបានដកចេញដែរឬទេ? ឬថាតើមានជំហានណាមួយដែលបានប្រកាន់យក ឬត្រូវបានប្រមើលមើលក្នុងការដកចេញនូវឧបម្រុងទុកនេះដែរឬទេ?**

**ចម្លើយ**

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងអស់ក្នុងបញ្ជីនេះជាពិសេសគឺបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែមពីរដោយមិនមានឧបម្រុង។

[៦៣] អង្គការយូនីសេហ្វ ការវិភាគស្ថានភាពស្ត្រីនិងកុមារនៅកម្ពុជា ឆ្នាំ២០០៩ ទំព័រ១៦៩ លេខយោង៤៨៣។

៣. សូមបង្ហាញពីសកម្មភាពណាមួយ ដែលបានអនុវត្តដោយមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ននៃអនុសញ្ញាដែលមានក្នុងបញ្ជីដូចខាងក្រោមនិងការឆ្លើយតបណាមួយដែលបាន ផ្តល់ទៅនឹងអនុសាសន៍នានា ដោយមានឧទាហរណ៍ច្បាស់លាស់ពីវិធីនៃសកម្មភាពទាំងនេះប៉ះពាល់ដល់ការលុបបំបាត់នៅថ្នាក់ជាតិនៃអំពើហិង្សាលើកុមារ ។

- *គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ*

**ចម្លើយ**

ចាប់តាំងពីពេលដែលការសិក្សាស្តីពីអំពើហិង្សារបស់អង្គការសហប្រជាជាតិត្រូវបានផ្សព្វផ្សាយនៅឆ្នាំ២០០៦មក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានសហការជាមួយនឹងអង្គការយូនីសេហ្វ និងដៃគូផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់គណៈកម្មាធិការ រួចបានរៀបចំរបាយការណ៍ជាទៀងទាត់ ដែលមានលម្អិតរាល់សកម្មភាពដែលបានធ្វើ។ នៅក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនរបាយការណ៍ផ្គួបគ្នាលើកទី២និងទី៣ របស់កម្ពុជា ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឆ្នាំ២០០០-២០០៧ ។ នៅក្នុងឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនរបាយការណ៍ ស្តីពីការអនុវត្តន៍សេចក្តីសម្រេចលេខ ២០០៩/២៦ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមកិច្ច ស្តីពីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងថ្នាក់ជាតិ និងអន្តរជាតិ នៅក្នុងកំណែទម្រង់យុត្តិធម៌កុមារ ។ នៅឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនចម្លើយតបនឹងបញ្ជីសំណួររបស់គណៈកម្មការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍លើកទី២ និងទី៣ ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនបានបញ្ជូនរបាយការណ៍ជាតិលើកទី១ និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ ឆ្នាំ២០០២-២០១០ និងរបាយការណ៍ជាតិលើកទី១និងទី២ ស្តីពីការអនុវត្តពិធីសារបន្ថែមនៃអនុសញ្ញាសិទ្ធិកុមារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារឆ្នាំ២០០២-២០១០។

- *គណៈកម្មាធិការសិទ្ធិមនុស្ស*
- *គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌*

**ចម្លើយ**

របាយការណ៍ដំបូងត្រូវបានបញ្ជូននៅក្នុងឆ្នាំ២០០៨។

- *គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម*

**ចម្លើយ**

រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនរបាយការណ៍ដំបូងនៅក្នុងឆ្នាំ១៩៩៧ ហើយបានទទួលសេចក្តីសង្កេត និងអនុសាសន៍រួចហើយ។ របាយការណ៍លើកទី២ ត្រូវបានបញ្ជូននៅក្នុងឆ្នាំ២០០៩ ។

- *គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍(CERD)*

**ចម្លើយ**

របាយការណ៍ដំបូងត្រូវបានបញ្ជូននៅក្នុងឆ្នាំ១៩៨៥ បន្ទាប់មករបាយការណ៍ផ្គួបគ្នាពីលើកទី២ ដល់ទី៧ ត្រូវបានបញ្ជូននៅក្នុងឆ្នាំ១៩៩៧ ។ របាយការណ៍ផ្គួបគ្នាលើកទី៨ដល់ទី១៣ត្រូវបានបញ្ជូននៅក្នុងឆ្នាំ២០០៩ ហើយរបាយការណ៍បន្ទាប់នឹងត្រូវបញ្ជូននៅក្នុងឆ្នាំ២០១២។

- *គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ(CEDAW)*

**ចម្លើយ**

របាយការណ៍ផ្តួបគ្នាលើកទី១ ទី២និងទី៣ ត្រូវបានបញ្ជូននៅក្នុងឆ្នាំ២០០៤។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនចម្លើយទៅនឹងបញ្ជីសំណួរនៅក្នុងឆ្នាំ២០០៦ ហើយរបាយការណ៍តាមកាលកំណត់លើកទី៤ ត្រូវដល់ក្នុងឆ្នាំ២០០៩។

- *គណៈកម្មាធិការស្តីពីកម្មករទេសន្តប្រវេសន៍*
- *គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ*
- *គណៈកម្មាធិការអង្គការពលកម្មអន្តរជាតិនៃអ្នកជំនាញត្រួតពិនិត្យលើការអនុវត្តអនុសញ្ញាអង្គការពលកម្មអន្តរជាតិ លេខ ១៣៨ និង ១៨២*

**៨. សូមបង្ហាញពីសកម្មភាពណាមួយដែលបានអនុវត្ត ឬបានប្រមើលមើលដើម្បីលើកស្ទួយការអនុវត្តអនុសាសន៍នៃការសិក្សារបស់ អ.ស.ប រួមទាំងធនធានដែលបានបម្រុងទុក-តាមរយៈកិច្ចសហប្រតិបត្តិការជាមួយដៃគូ នៅ*ថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ថ្នាក់ទ្វេភាគី?***

**ចម្លើយ**

ការអង្កេតស្តីពីអំពើហិង្សាលើកុមាររបស់អង្គការយូនីសេហ្វ នឹងត្រូវចាប់អនុវត្តនៅក្នុងឆ្នាំ២០១២ ហើយគេរំពឹងថានឹងទទួលបានលទ្ធផលនៅក្នុងឆ្នាំ២០១៣ ។ ប្រទេសដែលចូលរួមមានចិន វៀតណាម ថៃ ឡាវ និង មីយ៉ាន់ម៉ា ។ ចំពោះប្រទេសកម្ពុជា ការអង្កេតនេះនឹងត្រូវដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានិងក្រសួងកិច្ចការនារី ។ រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងទ្វេភាគី និងកិច្ចព្រមព្រៀងថ្នាក់តំបន់ (សូមអានខាងក្រោម) ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងបានធ្វើវិភាជន៍ធនធានមនុស្សនិងហិរញ្ញវត្ថុទៅក្នុងការរៀបចំគោលនយោបាយតាមព្រំដែន និងគាំទ្រដល់ការវិលត្រលប់មកប្រទេសវិញ និងសមាហរណកម្មជនរងគ្រោះ។

**៩. សូមបញ្ជាក់ថាតើកន្លងមកមានការសម្របសម្រួលទ្វេភាគី ពហុភាគី ឬនៅថ្នាក់តំបន់អ្វីទេ ដើម្បីបង្ការទប់ស្កាត់និងឆ្លើយតបទៅនឹងអំពើហិង្សាលើកុមារ។**

**ចម្លើយ**

រាជរដ្ឋាភិបាលកម្ពុជាសកម្មខ្លាំងណាស់នៅក្នុងការកសាងទំនាក់ទំនងថ្នាក់តំបន់ និងទ្វេភាគី ដើម្បីបង្ការទប់ស្កាត់ការជួញដូរមនុស្សនៅអាស៊ីភាគអគ្នេយ៍ និងនៅក្នុងកម្ពុជា ហើយបានចុះហត្ថលេខាលើ ៖

- អនុសញ្ញាបត្យាប័នជាមួយប្រទេសព្រះរាជាណាចក្រថៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋកូរ៉េ ។
- កិច្ចព្រមព្រៀងសហការក្នុងទេសចររបស់អាស៊ាន នៅក្នុងការប្រជុំកំពូលអាស៊ានលើកទី៨ នៅភ្នំពេញក្នុងឆ្នាំ២០០២ ដែលនឹងទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនូវកេរ្តិ៍តំណែលវប្បធម៌ និងធនធានធម្មជាតិរបស់តំបន់
- អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងអូស្ត្រាលី ក្នុងឆ្នាំ២០០៣ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ
- អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងរាជរដ្ឋាភិបាលថៃ ក្នុងឆ្នាំ២០០៣

ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះនៃការជួញដូរ ។ រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារមួយឡើងនៅក្នុងឆ្នាំ២០០៤ សម្រាប់ការអនុវត្តន៍អនុស្សរណៈនេះ។

- សន្និសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកនៅក្នុងរឿងព្រហ្មទណ្ឌឆ្នាំ២០០៤ នៅក្នុងក្របខណ្ឌអាស៊ាន
- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងរដ្ឋាភិបាលវៀតណាម ក្នុងឆ្នាំ២០០៥ ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះនៃការជួញដូរ ហើយនិងកិច្ចព្រមព្រៀងសហការគ្នារាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងរដ្ឋាភិបាលវៀតណាមស្តីពីនីតិវិធីប្រតិបត្តិការក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារការជួញដូរ
- អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងបណ្តាប្រទេសនៅក្នុងមហាអនុតំបន់មេគង្គ (Greater Mekong Sub-RegionGMS) ស្តីពីកិច្ចសហការប្រឆាំងនឹងការជួញដូរមនុស្សក្នុងឆ្នាំ២០០៤ ហើយក្រុមការងារមួយរបស់កម្ពុជាត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៥សម្រាប់ឱ្យអនុវត្តអនុស្សរណៈនេះ ។ ក្រុមការងារបានរៀបចំបង្កើតផែនការសកម្មភាព ២០០៤-២០០៧ ។ នៅក្នុងឆ្នាំ២០០៦ ក្រុមការងារពីប្រទេសទាំង៦នៅក្នុងមហាអនុតំបន់មេគង្គ បានអនុម័តផែនការសកម្មភាពរួមគ្នាសម្រាប់រយៈពេល៣ឆ្នាំឡើង ដែលរដ្ឋមន្ត្រីរបស់ប្រទេសទាំង៦បានចុះហត្ថលេខានៅក្នុងសេចក្តីប្រកាសរួមគ្នាមួយ ស្តីពីគំនិតផ្តួចផ្តើមសម្របសម្រួលថ្នាក់រដ្ឋមន្ត្រីក្នុងអនុមហាតំបន់មេគង្គប្រឆាំងនឹងការជួញដូរមនុស្ស (Coordinated Mekong Ministerial Initiative against Trafficking-COMMIT)។
- អនុស្សរណៈនៃការយោគយល់គ្នាមួយ ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះនៃការជួញដូរកំពុងត្រូវបានពិភាក្សាគ្នារវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងរដ្ឋាភិបាលម៉ាឡេស៊ី។

## សន្និដ្ឋាន

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឯកភាពលើគោលការណ៍ដែលមានក្នុងការសិក្សាស្តីពីអំពើហិង្សាលើកុមារដែលបានបញ្ជាក់ថា អំពើហិង្សាលើកុមារជាអំពើមិនត្រឹមត្រូវទេ ហើយជាអំពើដែលអាចបង្ការទប់ស្កាត់បាន ហើយចំណុចនេះជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្តល់សេវាផ្សេងៗដល់កុមារដើម្បីធានាថាកុមារទទួលបានសិទ្ធិរបស់ខ្លួន និងរដ្ឋ ក៏ទទួលខុសត្រូវការពារមិនឱ្យមានអំពើហិង្សាលើកុមារ និងចាប់ជនល្មើសឱ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ពីភាពងាយរងគ្រោះពិសេសរបស់កុមារមួយចំនួន ដែលតម្រូវឱ្យមានកិច្ចការពារបន្ថែមទៀត ។

របាយការណ៍នេះ បានរៀបរាប់លម្អិតអំពីច្បាប់និងលិខិតបទដ្ឋាន ដែលបានរួមចំណែកក្នុងការគ្របដណ្តប់គ្រប់ទីកន្លែង និងគ្រប់រូបភាពនៃអំពើហិង្សា ដែលកុមារកំពុងតែប្រឈមមុខ។ បច្ចុប្បន្ន ក្របខណ្ឌច្បាប់ទាំងនេះ បាននិងកំពុងអនុវត្តន៍ ដែលជាកម្លាំងជំរុញដល់ការរស់នៅរបស់កុមារនៅតាមភូមិឃុំ និងសង្កាត់ ដ៏មានសុវត្ថិភាព។

# Bibliography


- Amnesty International, *Breaking the Silence-Sexual Violence in Cambodia,* 2010
- Cambodia Centre for Human Rights, *Human Trafficking Trials in Cambodia,* July 2010
- Gourley, Steve, NGOCRC ,*the Middle Way, bridging the Gap between Cambodian Culture and Children's Rights*, 2009
- GDC, *A Qualitative Exploration of Gender Norms, Masculinity and Domestic Violence,* 2010
- Human Rights Watch. *Off the Street; Arbitrary Detention and Other Abusesagainst Sex Workers in Cambodia* 2010.
- Human Rights Watch, *Skin on the Cable,* 2010,
- Kim, Jane, *An Assessment of the Law Enforcement against Sexual Abuse, Sexual Exploitation and Trafficking of Children (LEASETC) Project,* July 2010
- NGO Joint Statistics Database *Report on Trafficking and Rape in Cambodia* 2009 and 2010
- Miles, Glenn and Blanche Heather, *What About Boys? An initial exploration of sexually exploited boys in Cambodia*, September 2011
- Plan International Cambodia, *Orphans and Vulnerable Children in Cambodia: A Situation Analysis in Four Provinces*, May 2011
- RGC, *The Guidelineon the Organization and Establishment of the Committee for Women and Children for all Commune/sangkat in Country* 2007
- RGC, *2nd and 3rd Report on the Implementation of Convention on the Rights of the Child in Cambodia* 2000-2007,
- RGC, CNCC, *1st and 2nd Report on The Implementation of Optional Protocol to the UN Convention on the Rights of the Child on the Involvement of Children in Armed Conflicts* 2002-2010
- RGC, CNCC, 1st and 2nd*Report on the Implementation of the Optional Protocol to the Convention on the Rights of the Child on the Sale of Children, Child Prostitution and Child Pornography* 2002-2010
- RGC, Council for Legal and Judicial Reform, *Legal Aid in Cambodia: practices, Perceptions and Needs, A Study based on a National Survey*, 2006.
- RGC, MoJ, *Pathways to Justice,* 2006
- RGC, MoWA, *A Fair Share for Women, Cambodia Gender Assessment, 2008*
- *in Cambodia*, 2008
- RGC, *National Development Strategy Plan update* 2009-2013
- RGC, *Report on the Implementation of Resolution No. 2009/26 of the Economic and Social Council On Supporting National and International Efforts for Child Justice Reform* July 2010
- RGC, *Reply to the List of Issues raised by the UN Committee on the Rights of the Child related to the consideration of the combined second and third report of the Kingdom of Cambodia on the Implementation of the Convention on the Rights of the Child,*April 2011
- RGC, *DRAFT Gap Analysis of Child Protection Legislation in Cambodia,* 2011
- RGC, MoSVY, *Special Centres: Assessment of the policies, procedures and practices in the referral, placement, management, rehabilitation and reintegration of children, women and vulnerable persons at social affairs, youth rehabilitation and drug rehabilitation centres under the authority of MoSVY*September 2011
- RGC, MOWA, *Report on the Data Collection and Monitoring of Violence Against Women in Cambodia*, 2010.
- RGC, *Report on the Implementation of Resolution No. 2009/26 of the Economic and Social Council On Supporting National and International Efforts for Child Justice Reform,* July 2010
- RGC, MOI, *Law Enforcement Advancing Protection of Children and Vulnerable*

*Persons (LEAP) A Strategic Framework*, 2010.
- RGC, MOSVY, *Most At Risk Young People Survey* Cambodia, 2010
- RGC, MOSVY, *DRAFT With Best Intentions: A Summary of Attitudes Towards Residential Care in Cambodia,* 2011
- SRSG: *Report of the independent expert for the United Nations study on violence against children* 2006
- Save the Children Norway, *Child participation research: values beliefs and cultural practices which effect child participation in the life of Cambodian children,* 2008
- Woods, Lisa Nicol, *Sound the Alarm: Reporting Violence Against Children*,UCW *Towards eliminating the worst forms of child labour in Cambodia by 2016,* May 2009
- UNICEF *Situational Assessment on Women and Children* 2009
- UNICEF *Programme of Operations* 2011-2015
- The World Bank, *Managing Risk and Vulnerability in Cambodia: An assessment and strategy for social protection,* 2006
- World Vision Cambodia, *As if they were watching my body: pornography and the development of attitudes towards sex and sexual behavior amongst Cambodian Youth* , 2006.

# Annexes

1. *RGC, 2nd and 3rd Report on the Implementation of Convention on the Rights of the Child in Cambodia 2000-2007 (CNCC to provide)*
2. RGC, CNCC,*1st and 2nd Report on The Implementation of Optional Protocol to the UN Convention on the Rights of the Child on the Involvement of Children in Armed Conflicts* 2002-2010 (CNCC to provide)
3. RGC, CNCC, 1st and 2nd*Report on the Implementation of the Optional Protocol to the Convention on the Rights of the Child on the Sale of Children, Child Prostitution and Child Pornography* 2002-2010 (CNCC to provide)
4. RGC, *Reply to the List of Issues raised by the UN Committee on the Rights of the Child related to the consideration of the combined second and third report of the Kingdom of Cambodia on the Implementation of the Convention on the Rights of the Child, April 2011 (CNCC to provide)*
5. RGC, CNCC, 1st and 2nd *Report on the Implementation of the Optional Protocol to the Convention on the Rights of the Child on the Sale of Children, Child Prostitution and Child Pornography,* 2002-2010 (CNCC to provide)
6. RSC, *National Strategic Development Plan Update* 2009-2013 (CNCC to provide)
7. Services Directory for Vulnerable people 2010 (**Sophy has hard copy)**
8. RGC, MoSVY, Minimum Standards on Alternative Care for Children 2008
9. *MoI statistics, Profile of perpetrators 2004-2011* (**Sophy has soft copy)**
10. *MoI statistics, Profile of perpetrators January-October 2011* **(Sophy has soft copy)**
11. *MoI statistics, Profile of victims 2004-2011* **(Sophy has soft copy)**
12. *MoI statistics, Profile of victims January –October 2011* **(Sophy has soft copy)**
13. RGC, MOWA, *Report on the Data Collection and Monitoring of Violence against Women in Cambodia*, 2010 **(CNCC to provide)**
14. RGC, MoWA, *A Fair Share for Women, Cambodia Gender Assessment,* 2008 **(Sophy has hard copy)**
15. RGC, Ministry of Planning, Cambodia Socio-Economic Survey 2009 **(Sophy has hard copy).**

# Justification : Reports requested by the questionnaire

Recommendation 1
Requests the policy framework to prevent and respond to incidents of violence against children. NSPD Update does not address the subject directly but can be annexed.

Recommendation 4
Requests evaluations of programmes on parenting - no relevant reports available

Recommendation 6
Requests reports on services on rehabilitation and reintegration. The Service Directory 2010 can be annexed even though it is only in Khmer as the contact data on service providers is in English.

Recommendation 8
Requests details of complaints mechanisms and third party reporting mechanisms. We can attach the MoSVY Minimum Standards 2008

Recommendation 9
Requests details of statistics on court cases against perpetrators. Annexed are recent figures from the MoI in four pages attached

Recommendation 10
Requests data on vulnerabilities of girls and boys. Suggest:
The Ministry of Planning Socio-Economic Survey 2009
RGC, MoWA, *A Fair Share for Women, Cambodia Gender Assessment,* 2008 Can RGC, MOWA, *Report on the Data Collection and Monitoring of Violence against Women in Cambodia*, 2010

Recommendation 11
Requests details of annual statistical data on VAC - none available.